# របាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៩ ៖ បុព្វកថា

## នីស្នាក់ការលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ

## របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តសិទ្ធិមនុស្ស ឆ្នាំ២០០៩

### ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០

ទស្សន:សិទ្ធិមនុស្សចាប់ផ្តើមដោយការប្តេជ្ញាចិត្តជាមូលដ្ឋានចំពោះការគោរពសេចក្តីថ្លៃថ្នូរ ដែលជាសិទ្ធិពីកំណើតរបស់បុរស ស្ត្រី និងកុមារគ្រប់រូប ។ វឌ្ឍនភាពក្នុងការលើកតម្កើងសិទ្ធិមនុស្សចាប់ផ្តើមដោយស្ថានភាពជាក់ស្តែងទាំងនេះ ហើយក្នុងរយ:ពេល៣៤ឆ្នាំចុងក្រោយនេះ សហរដ្ឋអាមេរិកបានរៀបចំរបាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តសិទ្ធិមនុស្ស ដែលផ្តល់នូវកំណត់ត្រាទូលំទូលាយបំផុត អំពីស្ថានភាព សិទ្ធិមនុស្សនៅជុំវិញពិភពលោក ។

របាយការណ៍ទាំងនេះ គឺជាមធ្យោបាយដ៏មានសារ:សំខាន់សម្រាប់សកម្មជន ដែលតស៊ូយ៉ាងអង់អាចក្លាហាន ដើម្បីការពារសិទ្ធិនៅតាមសហគមន៍នានានៅជុំវិញពិភពលោក  សម្រាប់អ្នកសារព័ត៌មាន និងបញ្ញវន្តដែលចងក្រងឯកសារស្តីពីការរំលោភសិទ្ធិមនុស្ស និងធ្វើរបាយការណ៍អំពីការងាររបស់អ្នកដែលគាំទ្រជនងាយរងគ្រោះ និងសម្រាប់រដ្ឋាភិបាល រួមទាំងរដ្ឋាភិបាលសហរដ្ឋអាមេរិកផ្ទាល់ផងដែរ នៅពេលពួកគេធ្វើការ តាក់តែងយុទ្ធសាស្ត្រដើម្បីជំរុញកិច្ចការពារសិទ្ធិរបស់បុគ្គលកាន់តែច្រើននៅតាមតំបន់កាន់តែច្រើនឡើង ។

គោលការណ៍ដែលបុគ្គលម្នាក់ៗមានគុណតម្លៃសីលធម៌ស្មើគ្នា គឺជាសេចក្តីពិតជាក់ស្តែងដ៏សាមញ្ញមួយ ប៉ុន្តែ ការធ្វើងោយមានពិភពលោកមួយ ដែលមនុស្សទាំងអស់អាចប្រើប្រាស់សិទ្ធិ ដែលជាកម្មសិទ្ធិរបស់ខ្លួនពីធម្មជាតិនោះ គឺជាបញ្ហាប្រឈមដ៏ធំក្នុងការអនុវត្តជាក់ស្តែង ។ ដើម្បីតាក់តែងគោលនយោបាយសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព យើងត្រូវការការវាយតម្លៃដ៏ត្រឹមត្រូវអំពីស្ថានភាពជាក់ស្តែងនៅតាមទីកន្លែងដែលយើងចង់ធ្វើអោយមានការផ្លាស់ប្តូរ ។ យើងត្រូវការការយល់ដឹងប្រកបដោយយុទ្ធសាស្ត្រ និងមានភាពវាងវៃអំពីរបៀបដែលអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងការអភិវឌ្ឍសេដ្ឋកិច្ចអាចរួមចំណែកដល់ការបង្កើតអោយមានបរិយាកាសមួយដែលផ្តល់នូវការការពារសិទ្ធិមនុស្ស ។ យើងត្រូវទទួលស្គាល់ថា លទ្ធិប្រជាធិបតេយ្យដែលការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍដែលគោរពសិទ្ធិមនុស្ស បំពេញបន្ថែមគ្នាទៅវិញទៅមក ។ ហើយយើងក៏ត្រូវការមធ្យោបាយត្រឹមត្រូវ និងដៃគូដ៏ត្រឹមត្រូវ ដើម្បីអនុវត្តគោលនយោបាយរបស់យើងផងដែរ ។

សិទ្ធិមនុស្សគ្មានទីបញ្ចប់នោះទេ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីការពារសិទ្ធិមនុស្ស ត្រូវតែចាក់ឫសអោយបានរឹងមាំចាប់តាំងពីចំណុចនេះ និងពីពេលឥឡូវនេះតទៅ ។ យើងកំពុងស្ថិតនៅក្នុងស្ថានភាពមួយដែលរដ្ឋាភិបាលនៃប្រទេសកាន់តែច្រើនឡើងកំពុងដាក់ការរឹតត្បិតថ្មី និងរារាំងដល់អង្គការមិនមែនរដ្ឋាភិបាលនានាដែលកំពុងធ្វើការដើម្បីការពារសិទ្ធិនិងលើកកម្ពស់គណនេយ្យភាព ។ បច្ចេកវិទ្យាថ្មីៗមានប្រយោជន៍ ចំពោះទាំងអ្នកគាបសង្កត់ និងទាំងអ្នកដែលតស៊ូដើម្បីលាតត្រដាងបរាជ័យ និងភាពកំសាករបស់ពួកអ្នកគាប សង្កត់ ។

ហើយបញ្ហាប្រឈមរបស់ពិភពលោកនាសម័យកាលនេះ ដូចជាសន្តិសុខស្បៀង ការប្រែប្រួល អាកាសធាតុ ជំងឺឆ្លងរាលដាលជាសកល វិបត្តិសេដ្ឋកិច្ច និងភាពជ្រុលនិយមប្រកបដោយភាពហឹង្សាជាដើម ប៉ះពាល់ដល់ការទទួលបានសិទ្ធិមនុស្សនាពេលបច្ចុប្បន្ន ព្រមទាំងធ្វើអោយមានបរិបទនយោបាយសកលលោកមួយ ដែលយើងត្រូវតែលើកស្ទួយសិទ្ធិមនុស្សក្នុងរយៈពេលយូរអង្វែង ។

សិទ្ធិមនុស្សមានលក្ខណៈសកល ប៉ុន្តែបទពិសោធន៍សិទ្ធមនុស្សមានលក្ខណៈទៅតាមមូលដ្ឋាន។ ហេតុដូច្នេះ ទើបយើងប្តេជ្ញាលើកស្ទួយអោយមនុស្សទាំងអស់មានបទដ្ឋានដូចគ្នារួមទាំងសហរដ្ឋអាមេរិកខ្លួនឯងផងដែរ ។ ហេតុដូច្នេះហើយបានជាយើងចងចាំប្រសាសន៍របស់លោកEleanor Roosevelt ថា "សិទ្ធិមនុស្សត្រូវតែមាន ចាប់តាំងពីតំបន់តូចៗជិតផ្ទះឡើងទៅ" ។ នៅពេលយើងធ្វើការដើម្បីធានាសិទ្ធិមនុស្ស មានន័យថាយើងកំពុងតែធ្វើការដើម្បីការពារបទពិសោធន៍ ដែលធ្វើអោយជីវិតមានន័យ ដើម្បីថែរក្សាការពារសមត្ថភាពរបស់បុគ្គលម្នាក់ៗ ដើម្បីបំពេញសក្តានុពលដែលព្រះជាម្ចាស់ប្រទានអោយបុគ្គលម្នាក់ៗ ។ សក្តានុពលរបស់បុគ្គលគ្រប់រូប ដើម្បីរៀន សូត្រ ស្វែងយល់ និងការពារពិភពនៅជុំវិញខ្លួន សក្តានុពលដើម្បីចូលរួមដោយសេរីជាមួយបុគ្គលដទៃទៀត ដើម្បី រៀបចំសហគមន៍របស់ខ្លួន និងសង្គមជាតិរបស់ខ្លួន ដើម្បីអោយមនុស្សគ្រប់រូបអាចរកឃើញការបំពេញបំណង និងឯករាជ្យភាព សក្តានុពលដើម្បីចែករំលែកសោភណភាព និងសោកនាដ្យកម្មនៃជីវិត សំណើច និងទឹកភ្នែក ដល់ មនុស្សដែលខ្លួនស្រឡាញ់ ។

របាយការណ៍ដែលចេញផ្សាយនៅថ្ងៃនេះ គឺជាកំណត់ត្រានៃស្ថានភាពសិទ្ធិមនុស្សបច្ចុប្បន្នរបស់យើង ។ របាយការណ៍ទាំងនេះផ្អែកតាមស្ថានការណ៍ជាក់ស្តែងដែលនឹងផ្តល់ជាព័ត៌មានសម្រាប់គោលនយោបាយការទូត សេដ្ឋកិច្ច និងយុទ្ធសាស្ត្ររបស់សហរដ្ឋអាមេរិកនៅឆ្នាំបន្ទាប់ ។ របាយការណ៍ទាំងនេះមិនមែនសំដៅកំណត់អោយគេត្រូវតែដើរតាមគោលនយោបាយដូចពោលទាំងនេះទេ ប៉ុន្តែផ្តល់ចំណុចទិន្នន័យដ៏មានសារសំខាន់ សម្រាប់អ្នកទាំងឡាយនៅក្នុង រដ្ឋាភិបាលសហរដ្ឋអាមេរិកដែលកំពុងធ្វើការផ្នែកគោលនយោបាយទាំងនេះ ។ ខ្ញុំយល់ឃើញថារបាយការណ៍ទាំង នេះមិនមែនបញ្ចប់តែត្រឹមនេះទេ ប៉ុន្តែគឺជាមធ្យោបាយដ៏សំខាន់ក្នុងការរៀបចំយុទ្ធសាស្ត្រផ្នែកសិទ្ធិមនុស្សមាន លក្ខណៈជាក់ស្តែង និងប្រកបដោយប្រសិទ្ធភាព ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ នេះជាដំណើរការមួយដែលខ្ញុំមានការប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅដើម្បីសម្រេចអោយបាន ។

គោលការណ៍គ្មានទីបញ្ចប់ ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាតារានាំផ្លូវ ដែលត្រួសត្រាយមាគ៌ារបស់យើងឆ្ពោះទៅរកពិភពលោកមួយដែលយើងចង់រស់នៅ៖ ពិភពលោកមួយប្រកបដោយ យុត្តិធម៌ ដូចដែលលោកប្រធាធិបតី Obama បានមានប្រសាសន៍ថា សន្តិភាពស្ថិតនៅលើ "សិទ្ធិ និងសេចក្តីថ្លៃថ្នូរពីកំណើតរបស់បុគ្គលគ្រប់រូប" ។ ដោយក្តាប់បាននូវហេតុការណ៍ទាំងនេះនៅក្នុងដៃ និងដោយមានគោលដៅច្បាស់លាស់នៅក្នុងចិត្ត និងនៅក្នុងខួរក្បាល យើងប្តេជ្ញាបន្តខិតខំធ្វើការដើម្បីធ្វើអោយសិទ្ធិមនុស្សក្លាយជាការពិត ។

http://www.state.gov/g/drl/rls/hrrpt/2009/frontmatter/135934.htm

***ដោយជំនាវ Hillary Rodham Clinton***

***រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក***

ការិយាល័យព័ត៌មានអេឡិចត្រូនិចនៃទីចាត់ការកិច្ចការសាធារណៈ ទទួលបន្ទុកគ្រប់គ្រងវែបសាយត៍នេះ ក្នុងនាមជាគេហទំព័រសម្រាប់ផ្តល់ព័ត៌មានអំពីក្រសួងការបរទេសសហរដ្ឋអាមេរិក ។ រាល់ការបង្ហាញអំពីអាសយដ្ឋាន ទំនាក់ទំនងខាងក្រៅទៅកាន់វែបសាយត៍ដទៃទៀត មិនត្រូវបានចាត់ទុកថាជាការគាំទ្រចំពោះទស្សនៈ ឬគោលនយោបាយស្តីពីភាពឯកជនដែលមាននៅក្នុងវែបសាយត៍នេះឡើយ ។

# របាយការណ៍ស្តីពីសិទ្ធិមនុស្ស ឆ្នាំ២០០៩ ៖ ប្រទេសកម្ពុជា

## នីស្នាក់ការលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ

## របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តសិទ្ធិមនុស្ស

## ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០

ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបរាជានិយមអាស្រ័យធម្មនុញ្ញ ដែលមានរដ្ឋាភិបាលមួយតាមរយៈការបោះឆ្នោត និងមានប្រជាជនប្រមាណជា ១៤លាននាក់ ។ នៅក្នុងការបោះឆ្នោតកាលពីពេលថ្មីៗនេះ ដែលរៀបចំធ្វើឡើងនៅខែកក្កដា ឆ្នាំ២០០៨ គណបក្សប្រជាជនកម្ពុជា (CPP) ដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឈ្នះចំនួន ៩០អាសនៈ ក្នុង ចំណោមអាសនៈរដ្ឋសភាចំនួន១២៣ អាសនៈ ។ អ្នកសង្កេតការណ៍ភាគ ច្រើនបានវាយតម្លៃថា ដំណើរការបោះឆ្នោតនេះមានភាពប្រសើរជាងការបោះឆ្នោតកាលពីពេលកន្លងទៅ ប៉ុន្តែមិនទាន់បំពេញតាមបទដ្ឋានអន្តរជាតិទាំងស្រុងនៅឡើយទេ ។ គណបក្សប្រជាជនកម្ពុជាបានប្រមូលការ គ្រប់គ្រងលើផ្នែកទាំងបីនៃរដ្ឋាភិបាល និងស្ថាប័នជាតិដទៃទៀត ដែលអំណាចភាគច្រើនបំផុតត្រូវប្រមូលផ្តុំនៅក្នុង កណ្តាប់ដៃរបស់លោកនាយករដ្ឋមន្ត្រី ។ ទោះបីជាអាជ្ញាធរស៊ីវិលជាធម្មតាត្រូវគ្រប់គ្រងដោយ កងកម្លាំងសន្តិសុខ ក៏ដោយក៏ក្នុងករណីជាច្រើនកម្លាំងសន្តិសុខធ្វើសកម្មភាពក្រោមការបញ្ជារបស់ថ្នាក់ដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ។

កំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋាភិបាលនៅតែមានលក្ខណៈទន់ខ្សោយដដែល ។ កម្លាំងសន្តិសុខធ្វើឃាតក្រៅប្រព័ន្ធតុលាការ ហើយបានធ្វើសកម្មភាពដោយនិទ្ទណ្ឌភាព ។ ជនជាប់ឃុំទទួលរងការរំលោភបំពានជារឿយៗ ដើម្បីគាបសង្កត់អោយសារភាព ចំណែកស្ថានភាពពន្ធនាគារមានលក្ខណៈយ៉ាប់ខ្លាំង ។ អ្នកតាមដានស្ថានភាព សិទ្ធិមនុស្សបានរាយការណ៍អំពីការចាប់ខ្លួនដោយបំពាន និងការឃុំខ្លួនមុនពេលជំនុំជម្រះក្តីមានរយៈពេលយូរ បង្ហាញអោយឃើញពីប្រព័ន្ធតុលាការទន់ខ្សោយ និងការបដិសេធសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ វិវាទដីធ្លី និង ការបណ្តេញចេញដោយបង្ខំគឺជាបញ្ហាមួយផងដែរ ។ រដ្ឋាភិបាលបានរឹតត្បិតសេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មានតាមរយៈបណ្តឹងបរិហារកេរ្តិ៍ និងបណ្តឹងស្តីពីការផ្សព្វផ្សាយព័ត៌មានមិនពិត ហើយជួនកាលរំខាន ដល់សេរីភាពក្នុងការជួបប្រជុំទៀតផង ។ អំពើពុករលួយមានលក្ខណៈរីករាលដាល ។ អំពើហឹង្សាក្នុងគ្រួសារ និងការរំលោភបំពានកុមារបានកើតមានឡើង ការអប់រំកុមារមិនគ្រប់គ្រាន់ និងការជួញដូរស្ត្រី និងកុមារ នៅតែបន្តកើតមាន ឥតឈប់ឈរ ។ រដ្ឋាភិបាលបានផ្តល់ជំនួយឧបត្ថម្ភបន្តិចបន្តួចតែប៉ុណ្ណោះដល់

ជនពិការ ។ ការប្រឆាំងនឹងសកម្មភាព សហជីពកម្មករដោយនិយោជក និងការពង្រឹងច្បាប់ការងារដែលមានលក្ខណៈទន់ខ្សោយ នៅតែបន្តកើតមាន ចំណែកឯពលកម្មកុមារនៅក្នុងវិស័យក្រៅផ្លូវការនៅតែជាបញ្ហាដដែល ។

## ការគោរពសិទ្ធិមនុស្ស

### ផ្នែកទី១ ៖ ការគោរពសុចរិតភាពរបស់បុគ្គល រួមទាំងសេរីភាពរួចផុតពី ៖

### ក. ការដកហូតជីវិតដោយបំពារបំពាន និងខុសច្បាប់

ពុំមានរបាយការណ៍បញ្ជាក់ថារដ្ឋាភិបាល និងភ្នាក់ងាររដ្ឋាភិបាលបានធ្វើឃាតដោយមូលហេតុនយោបាយឡើយ ទោះជាយ៉ាងនេះក្ដី មានការរាយការណ៍ថាកងកម្លាំងសន្តិសុខបានធ្វើឃាតក្រៅប្រព័ន្ធតុលាការ គ្រាន់តែមានចំនួន តិចជាងឆ្នាំកន្លងទៅ ។

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (ADHOC) បានរាយការណ៍អំពីការធ្វើឃាតដោយរំលោភ បំពានចំនួន ១៨ករណី ក្នុងនោះ តាមការចោទប្រកាន់មានចំនួន ៧ករណីធ្វើឡើងដោយក្រុមនគរបាល ៣ករណី ដោយមន្ត្រីកងរាជអាវុធហត្ថ និង ៧ ករណីទៀតដោយមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ។ ក្រុមនគរបាលបានចាប់ខ្លួន ជនសង្ស័យយ៉ាងហោចណាស់ ៤ករណី ។

នៅថ្ងៃទី០៤ ខែមីនា តាមរបាយការណ៍ឈ្មោះ អ៊ិន ភាង ដែលមន្ត្រីជាយោធាម្នាក់នៅក្នុងកងវរសេនាតូចលេខ ៦១៧ បានបាញ់សម្លាប់សកម្មជនគណបក្សប្រឆាំង សម រង្ស៊ី (SRP) ម្នាក់ឈ្មោះ ម៉ាង រ៉ិត នៅក្នុងវិវាទមួយនៅ ស្រុកមេមត់ ខេត្តកំពង់ចាម ។ ប្រភពផ្សេងៗបានឯកភាពថា លោក ម៉ាង រ៉ិត បានស្រវឹងស្រានៅពេលកើតហេតុ ហើយបុរសទាំងពីរបានទាស់ទែងពាក្យសម្ដីគ្នាមុនពេលឈ្មោះ អ៊ិន ភាង ចាប់ផ្ដើមធ្វើការបាញ់ប្រហារ ។ យោធា រូបនេះបានធ្វើការដោះស្រាយជាមួយគ្រួសារជនរងគ្រោះនៅក្រៅប្រព័ន្ធតុលាការ ។

នៅថ្ងៃទី១៨ ខែមិថុនា ឈ្មោះ អ៊ូ ប៊ុនថន ដែលជាមន្ត្រីយោធាម្នាក់នៅក្នុងកងពលតូចអន្តរាគមន៍ទី ១៤ នៅខេត្ត ពោធិ៍សាត់បានសម្លាប់ជនស៊ីវិលម្នាក់ឈ្មោះ លឿង សារឿន ។ តាមរបាយការណ៍ ជនរងគ្រោះរូបនេះ បានធ្វើការ អោយឈ្មោះ អ៊ូ ប៊ុនថន ក្នុងនាមជាផ្នែកមួយនៃអាជីវកម្មជួញដូរសត្វព្រៃខុសច្បាប់ ។ តុលាការយោធា បានចេញ ដីកាចាប់ខ្លួនឈ្មោះ អ៊ូ ប៊ុនថន ដែល នៅលាក់ខ្លួនរហូតដល់ដំណាច់ឆ្នាំ ។

នៅថ្ងៃទី០៦ ខែមិថុនា មន្ត្រីកងរាជអាវុធហត្ថរាជធានីភ្នំពេញ ឈ្មោះ កែប ប្រុស ដែលជាកងអង្គរក្សរបស់ អភិបាលរាជធានីភ្នំពេញ បានបាញ់សម្លាប់ឈ្មោះ សយ សុខន នៅអំឡុងពេលមានវិវាទមួយ ។ រហូតដល់ ដំណាច់ឆ្នាំ ជនល្មើសនេះពុំទាន់ត្រូវបានចាប់ខ្លួននៅឡើយទេ ។

មានករណីសង្ស័យអំពីការសម្លាប់មួយចំនួន នៅពេលជនរងគ្រោះត្រូវស្ថិតក្នុងការឃាត់ខ្លួនរបស់រដ្ឋាភិបាល ឬ នគរបាល ។ នៅ ថ្ងៃទី២៣ ខែមិនា មានអ្នកនេសាទម្នាក់ឈ្មោះ ម៉ៅ សុខ បានស្លាប់នៅពេលស្ថិតក្នុងការឃាត់ខ្លួនរបស់មន្ទីរនេសាទខេត្តតាកែវ ។ គ្រួសារជនរងគ្រោះបាននិយាយថាសាកសពមានបង្ហាញអំពីសញ្ញានៃការធ្វើទារុណកម្ម ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរខេត្តថ្លែងថា ឈ្មោះ ម៉ៅ បានធ្វើអត្តឃាតនៅក្នុងបន្ទប់ឃាត់ខ្លួន ហើយអាជ្ញាធរខេត្តពុំបានធ្វើការស៊ើបអង្កេតឡើយ ។ គ្រួសារជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ខេត្ត ប៉ុន្តែព្រះរាជអាជ្ញាខេត្តបានបដិសេធបណ្តឹងនោះ ។ គ្រួសារ នេះបានដាក់ពាក្យបណ្តឹងទៅសាលាឧទ្ធរណ៍ រហូតមកដល់ដំណាច់ឆ្នាំនេះ សាលាឧទ្ធរណ៍ពុំទាន់ចាត់វិធានការអ្វីឡើយ ។

នៅថ្ងៃទី០១ ខែមេសា ឈ្មោះ គង់ ឡា បានស្លាប់នៅក្នុងការឃាត់ខ្លួនរបស់នគរបាលស្រុកមោងឫស្សីខេត្តបាត់ដំបង ។ គ្រួសារជនងរងគ្រោះបានរាយការណ៍ថាសាកសពមានបង្ហាញសញ្ញានៃការវាយដំ ។ អធិការនគរបាលស្រុកបានថ្លែងថាឈ្មោះ គង់ ទទួលរងរបួសធ្ងន់ធ្ងរនៅពេលគាត់ដួលសន្លប់នៅក្នុងការឃាត់ខ្លួន ហើយមេឃុំបានអះអាងថាឈ្មោះ គង់ បានធ្លាក់ពីលើម៉ូតូនៅពេលរើបម្រាស់ក្នុងពេលចាប់ខ្លួន ។ អាជ្ញាធរដែនដីបានផ្តល់ប្រាក់ដល់គ្រួសារឈ្មោះ គង់ ហើយគ្រួសារនេះក៏មិនបានដាក់ពាក្យបណ្តឹងផ្លូវការឡើយ ។

អង្គការមិនមែនរដ្ឋាភិបាល (NGO) បានរាយការណ៍អំពីការធ្វើឃាតសកម្មជននយោបាយចំនួនបីនាក់នៅអំឡុងឆ្នាំ នេះ ប៉ុន្តែការស៊ើបអង្កេតរបស់អង្គការទាំងនេះមិនអាចបញ្ជាក់ថាការស្លាប់នេះបណ្តាលមកពីមូលហេតុនយោបាយ ឡើយ ។

គ្មានការវិវឌ្ឍក្នុងករណីដូចខាងក្រោមនេះឡើយ ៖ មរណភាពកាលពីខែមេសា ឆ្នាំ២០០៨ របស់លោក បឿន សុខស៊ីណា ដែលត្រូវបាននគរបាលបាញ់ស្លាប់នៅអំឡុងពេលប្រដេញម៉ូតូមួយនៅខេត្តព្រះវិហារ មរណភាពកាលពី ខែមេសា ឆ្នាំ២០០៨ របស់អ្នកភូមិម្នាក់ដែលបានស្លាប់ក្រោយពីទទួលរងរបួសធ្ងន់ត្រង់ក្បាល ដោយសារការវាយដំ របស់កងកម្លាំងសន្តិសុខ ដែលខ្លួនទទួលរងការចោទប្រកាន់នៅអំឡុងពេលបណ្តេញចេញនៅខេត្តព្រះវិហារ មរណភាពកាលពីខែតុលា ឆ្នាំ២០០៨ របស់អ្នកឈរមើលហេតុការណ៍ម្នាក់ដែលតាមរបាយការណ៍ត្រូវសម្លាប់នៅ ពេលមន្ត្រីកងរាជអាវុធម្នាក់បើកការបាញ់ប្រហារទៅលើហ្វូងមហាជន ។

ហើយក៏គ្មានការវិវឌ្ឍផងដែរនៅក្នុងករណីធ្វើឃាតដោយជនមិនស្គាល់អត្តសញ្ញាណខាងក្រោមនេះ ៖ មរណភាព កាលពីខែឧសភា ឆ្នាំ២០០៨ របស់អតីតសកម្មជនគណបក្សប្រជាជនមួយរូបលោក ឈាង សន និងអនុប្រធាន គណបក្សនរោត្តមរណឫទ្ធិ លោក សុខ រុន និងមរណភាពកាលពីខែកក្កដា ឆ្នាំ២០០៨ របស់អ្នកសារព័ត៌មាន ឃឹម សំបូរ និងកូនប្រុសរបស់លោក ។

គ្មានការវិវឌ្ឍនៅក្នុងមរណភាពនៅឆ្នាំ២០០៧ របស់ព្រះសង្ឃខ្មែរកម្ពុជាក្រោមព្រះនាម អៀង សុខធឿន សកម្មជនគណបក្ស សមរង្ស៊ីឈ្មោះ ជា សូវីន អនុប្រធានឃុំគណបក្សសមរង្ស៊ី ឈ្មោះ ភ្លែប អ៊ិន ។

គ្រាប់មីនពីសម័យជម្លោះឥណ្ឌូចិន និងសម័យខ្មែរក្រហមនៅតែបង្កគ្រោះថ្នាក់ជាច្រើន ។ យោងតាមប្រព័ន្ធព័ត៌មាន ជនរងគ្រោះដោយសារគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះកាលពីខែមករា ដល់ខែវិច្ឆិកា គ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បង្កអោយមនុស្សស្លាប់ចំនួន ៤០នាក់ ពិការចំនួន ៥៤នាក់ និងរបួសផ្សេងៗចំនួន ១២២ករណី ។

នៅថ្ងៃទី០៩ ខែកុម្ភៈ តាមការចោទប្រកាន់ មានបុរសប្រាំពីរនាក់បានធ្វើឃាតឈ្មោះហង្ស ហឿន ដែលក្រុម នេះបានចោទថាជាអាបធ្មប់នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ ។ អាជ្ញាធរខេត្តបានចាប់ខ្លួនបុរសទាំងប្រាំពីរនាក់ ហើយបានចោទប្រកាន់ពីបទមនុស្សឃាតដោយគិតទុកជាមុន ។ រហូតដល់ដំណាច់ឆ្នាំ ជនល្មើសស្ថិតនៅក្នុងការឃុំខ្លួនមុនពេលជំនុំជម្រះក្តី ហើយកាល បរិច្ឆេទសម្រាប់ជំនុំជម្រះក្តីពុំទាន់ត្រូវបានកំណត់នៅឡើយ ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនានាបានរាយការណ៍អំពីការធ្វើឃាតក្នុងហ្វូងមហាជនចំនួនពីរករណី នៅក្នុង រយៈពេល ៦ខែដំបូង ។ ករណីមួយពាក់ព័ន្ធនឹងបទប្លន់ និងករណីមួយទៀតទាក់ទងនឹងបទប៉ុនប៉ងរំលោភសេពសន្ថវៈ ។

គ្មានការវិវឌ្ឍនៅក្នុងការធ្វើឃាតក្នុងហ្វូងមហាជនពីរកណីដែលបានរាយការណ៍នៅឆ្នាំ២០០៨ ឬការធ្វើឃាតក្នុងហ្វូងមហាជនចំនួនប្រាំករណី នៅឆ្នាំ២០០៧ឡើយ ។

**ខ. ការបាត់ខ្លួន**

គ្មានរបាយការណ៍អំពីការបាត់ខ្លួនដោយមូលហេតុនយោបាយទេ នៅអំឡុងឆ្នាំនេះ ។

នៅថ្ងៃទី០៤ ខែមេសា ព្រះសង្ឃខ្មែរកម្ពុជាក្រោម ព្រះនាមទឹម សាខន បានវិលត្រឡប់មកស្រុកកំណើតរបស់ព្រះអង្គវិញ នៅខេត្តតាកែវ ក្រោយពីត្រូវបានដោះលែងពីការឃុំខ្លួននៅក្នុងផ្ទះនៅប្រទេសវៀតណាម ។ ក្រោយពី ការព្យាយាមសុំឯកសារបញ្ជាក់អត្តសញ្ញាណសញ្ជាតិខ្មែរមិនបានទទួលជោគជ័យរួចមក ព្រះអង្គបានឆ្លងដែនទៅ កាន់ប្រទេសថៃនៅថ្ងៃទី១២ ខែមេសា ។ នៅខែកក្កដា ព្រះអង្គបានទទួលឋានៈជាជនភៀសខ្លួន និងបានទទួល យកការតាំងទីលំនៅថ្មីនៅប្រទេសទីបី ។

គ្មានការវិវឌ្ឍជុំវិញការបាត់ខ្លួននៅឆ្នាំ២០០៧ របស់យោធាកងឯកភាពការពារព្រំដែនជើងគោកលេខ ៥០៤ ឈ្មោះ អ៊ឹម ប៊ុននី នោះទេ ។

**គ. ទារុណកម្ម ការប្រព្រឹត្ត ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកដទៃទៀត**

រដ្ឋធម្មនុញ្ញហាមឃាត់ចំពោះទង្វើដូចពោលទាំងនេះ ទោះជាយ៉ាងណាក៏ដោយ ការវាយដំ និងការប្រព្រឹត្ត មិនគប្បី លើរូបរាងកាយក្នុងទម្រង់ដទៃទៀតចំពោះជនដែលត្រូវឃាត់ខ្លួនដោយនគរបាល និងអ្នកជាប់ពន្ធនាគារ នៅតែ មានជាបន្តទោះបីចំនួនឧប្បត្តិហេតុបានថយចុះយ៉ាងច្រើនពីឆ្នាំកន្លងទៅក៏ដោយ ។

មានរបាយការណ៍ដែលអាចទុកចិត្តបានជាច្រើនថាមន្ត្រីកងរាជអាវុធហត្ថនិងនគរបាលស៊ីវិលបាន ប្រើប្រាស់ទារុណ កម្មលើរាងកាយ និងផ្លូវចិត្តហើយមានពេលខ្លះវាយដុំយ៉ាងធ្ងន់ធ្ងរទៅលើជនដែលត្រូវឃុំខ្លួន ដោយសារបទព្រហ្មទណ្ឌ ទៀតផង ជាពិសេសនៅអំឡុងពេលសួរចម្លើយ ។ នៅអំឡុងឆ្នាំនេះ អង្គការមិនមែន រដ្ឋាភិបាលបានរាយការណ៍ថា អាជ្ញាធរត្រូវបានចោទ ប្រកាន់ថាបានធ្វើទារុណកម្មយ៉ាងហោចណាស់ទៅលើអ្នក ជាប់ពន្ធនាគារចំនួន ១១៨នាក់ ៖ ១០០នាក់នៅក្នុងការឃាត់របស់នគរបាល និង១៨ នាក់ទៀតនៅក្នុងពន្ធនាគារ ។ ការទាត់ធាក់ ការដាល់ និងការវាយវាត់ដោយកាំភ្លើងខ្លីគឺជាវិធីរំលោភបំពានលើរូបរាងកាយដែលកើតមានឡើង ច្រើនបំផុត ប៉ុន្តែបច្ចេកទេស ធ្វើទារុណកម្មនេះក៏មានបញ្ចូលការឆក់ខ្សែភ្លើង ការធ្វើអោយថប់ដង្ហើម ការច្រកចូល ក្នុងថង់សាំង និងការវាយនឹង ខ្សែភ្លើងផងដែរ ។ អង្គការ NGO នានា រាយការណ៍ថាជារឿងធម្មតាដែល នគរបាលធ្វើទារុណកម្មលើជនសង្ស័យ ដែលត្រូវឃុំខ្លួនរហូតទាល់តែអ្នកទាំងនេះសារភាពថាបានប្រព្រឹត្ត បទឧក្រិដ្ឋណាមួយ ។ តុលាការប្រើប្រាស់ការ សារភាពដោយបង្ខំធ្វើជាភស្តុតាងស្របច្បាប់នៅអំឡុងពេលជំនុំ ជម្រះក្តី ទោះបីមិនត្រូវបានអនុញ្ញាតអោយប្រើប្រាស់ តាមច្បាប់ក៏ដោយ ។

នៅថ្ងៃទី៣១ ខែមករា ប្រជាជនប្រាំនាក់មកពីភូមិទំនប់ទឹក បានរាយការណ៍ថា មានកងរាជអាវុធហត្ថមក ពីស្រុកបាវិល ខេត្តបាត់ដំបង បានវាយដុំ ទាត់ធាក់ និងឆក់ខ្សែភ្លើងដើម្បីទាមទារចម្លើយសារភាពចំពោះបទប្លន់ មួយ ដែលខ្លួនអះអាងថាមិនបានប្រព្រឹត្ត ។

នៅថ្ងៃទី២៧ ខែកុម្ភៈ ឈ្មោះ ជា លី និងប្រពន្ធរបស់គាត់ ឈ្មោះ ឈួន អេង បានរាយការណ៍ថា ទាហានបានវាយដុំ ពួកគាត់ក្រោយពីប្តីប្រពន្ធរូបនេះបដិសេធមិនបង់ប្រាក់សំណូកនៅចំណុចត្រួតពិនិត្យស្រុក ព្រៃនប់ ។ ទាហានទាំង នេះស្ថិតនៅក្នុងកងវរសេនាតូចលេខ១ នៅខេត្តព្រះសីហនុ ។

នៅថ្ងៃទី២៥ ខែឧសភា ឈ្មោះប៉ុក អ៊ុន បានរាយការណ៍ថាកងរាជអាវុធហត្ថស្រុកអូរជ្រៅខេត្ត បន្ទាយមានជ័យបាន វាយដុំ និងទាត់ធាក់រូបលោក នៅពេលឃុំខ្លួនលោកក្នុងករណីសង្ស័យពីបទចោរកម្ម។

នៅអំឡុងឆ្នាំនេះ អង្គការ ADHOC បានធ្វើការកត់សម្គាល់ថាការបង្ករបួសស្នាមចំនួន ១០០ករណី ទៅលើជន ស៊ីវិលដោយអាជ្ញាធរដែនដី ភ្នាក់ងាររដ្ឋាភិបាល ឬអង្គរក្សឯកជន ដែលធៀបនឹងឆ្នាំ២០០៨ មានចំនួន ១១០ករណី ។

នៅខែធ្នូ អាជ្ញាធរជាតិគ្រប់គ្រងគ្រឿងញៀនបានតម្រូវអោយអ្នកញៀនគ្រឿងញៀនចំនួន២១នាក់ចូលរួម នៅក្នុង ការសាកល្បងលើខ្លួនមនុស្សនូវទឹកឱសថឈើព្រៃហៅថាសារធាតុបង់សែន ដែលត្រូវបានប្រើប្រាស់ជាច្រើនឆ្នាំនៅ ប្រទេសវៀតណាមសម្រាប់បន្សាបអ្នកញៀនគ្រឿងញៀន ។ មន្ត្រីទាំងនោះអះអាងថាមានអ្នកស្ម័គ្រចិត្តចំនួន២១នាក់ ប៉ុន្តែមានប្រភពព័ត៌មានអះអាងថា អ្នកញៀនគ្រឿងញៀនជាច្រើនត្រូវបានផ្តល់ជម្រើសអោយចូលរួមក្នុងសិក្សា នេះ បើពុំដូច្នោះទេត្រូវជាប់ពន្ធនាគារ ។ យោងតាមអង្គការសុខភាពពិភពលោក គ្មានការពិនិត្យផ្នែកក្រមសីលធម៌ ទៅលើផែនការប្រើប្រាស់សារធាតុនេះឡើយ ហើយក៏មិនត្រូវបានចុះបញ្ជីជាឱសថតាមគោលការណ៍ណែនាំរបស់ ក្រសួងសុខាភិបាលផងដែរ ។ មានព័ត៌មានតិចតួច ឬគ្មានព័ត៌មានអំពីប្រសិទ្ធភាពការហាមប្រាម ឬផលប៉ះពាល់ របស់សារធាតុបង់សែនឡើយមុនពេលធ្វើពិសោធន៍ ។ ក្នុងចំណោមអ្នកចូលរួមសាកល្បង ចំនួន ២១នាក់ នោះ មាន៨នាក់ មានផ្ទុកមេរោគអេដស៍ ហើយពីរនាក់ទៀតកំពុងប្រើប្រាស់ថ្នាំប្រឆាំងមេរោគ (ថ្នាំពន្យាជីវិត) នៅពេល "សាកល្បងព្យាបាល" ដោយសារធាតុបង់សែននោះ ។ ភាគច្រើននៃជនទាំង ២១នាក់បានរាយការណ៍ថា មានប្រតិកម្មអាក្រក់ចំពោះសារធាតុនេះ រួមទាំងជំងឺនៅអំឡុងពេលសាកល្បងផងដែរ ។ ក្រោយពីការសាកល្បង រយៈពេល ១០ថ្ងៃ អាជ្ញាធរគ្មានគម្រោង ឬធ្វើការតាមដានអ្នកជំងឺឡើយ ។ យោងតាមសេចក្តីថ្លែងការណ៍របស់ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនានា យ៉ាងហោចណាស់មាន ១៧នាក់ ក្នុងចំណោម ២១នាក់នេះបានបន្តការ ប្រើប្រាស់គ្រឿងញៀនក្នុងរយៈពេលពីរថ្ងៃនៃការសាកល្បង ។

គ្មានការវិវឌ្ឍអ្វីទាំងអស់នៅក្នុងករណីរបស់មន្ត្រីកងរាជអាវុធហត្ថ ឈ្មោះប្រាក់ វុត្ថា នៅខេត្តកំពង់ស្ពឺ ដែលកាលពី ឆ្នាំ២០០៧ ត្រូវបានរាយការណ៍ថា បានចាប់ខ្លួន និងវាយដុំបុរសម្នាក់ឈ្មោះ សុខ សឿន អោយសន្លប់ ។

ជាការឆ្លើយតបចំពោះរបាយការណ៍ឆ្នាំ២០០៨ ដែលថានគរបាល និងឆ្មាំសន្តិសុខរបស់ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា (MOSAVY) មន្ត្រីបានដោះលែងអ្នកជាប់ឃុំទាំងអស់នោះនៅមជ្ឈមណ្ឌលស្តារនីតិសម្បទាចំនួន ២ ។ នៅដំណាច់ឆ្នាំនេះ មជ្ឈមណ្ឌលមួយនៅបិទទ្វារនៅឡើយ ចំណែកឯមជ្ឈមណ្ឌលមួយទៀតកំពុងតែត្រូវបានប្រើប្រាស់ដើម្បីផ្តល់ជាទី ជម្រក និងស្តារនីតិសម្បទាគ្រួសារដែលគ្មានផ្ទះសម្បែង ។ មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានធ្វើការស៊ើបអង្កេតស្ថានភាពនៅ មជ្ឈមណ្ឌល ទាំងនោះ ប៉ុន្តែមិនបានចេញសេចក្តីសន្និដ្ឋាន ឬ របាយការណ៍អ្វីឡើយ ។ ឆ្មាំ និងនាយរងនៃមជ្ឈមណ្ឌលដែល មើលការខុសត្រូវមជ្ឈមណ្ឌលនោះនៅតែរក្សា តំណែងរបស់ខ្លួនដដែល ។

## ស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំខ្លួន

ស្ថានភាពពន្ធនាគារមិនសមស្របតាមបទដ្ឋានអន្តរជាតិឡើយ ។ ស្ថានភាពជាច្រើននៅតែមានលក្ខណៈយ៉ាប់ខ្លាំង ហើយតែងតែបង្កការគម្រាមកំហែងដល់អាយុជីវិតទៀតផង ។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីកែលម្អស្ថានភាពពន្ធនាគារ នៅតែបន្តជួបឧបសគ្គដោយសារកង្វះថវិកា និងការពង្រឹងច្បាប់មានភាពទន់ខ្សោយ ។

អង្គការសិទ្ធិមនុស្សនានាបានលើកឡើងអំពី បញ្ហាធ្ងន់ធ្ងរមួយចំនួនរួមមានដូចជាស្ថានភាពចង្អៀតណែនខ្លាំងពេក បញ្ហាសុខភាព ព្រមទាំងអនាម័យបរិស្ថាន កង្វះចំណីអាហារ និងទឹក កង្វះអាហារូបត្ថម្ភ និងសន្តិសុខមិនល្អ ។

យោងតាមនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ (MOI) មានអ្នកទោស និងអ្នកជាប់ពន្ធនាគារចំនួន ១៣.៣២៤នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ៨០២នាក់ និងកុមារចំនួន ៨៤០នាក់ ។ មានពន្ធនាគារចំនួន ២៥ កន្លែងនៅទូទាំងប្រទេសដែលបានបង្កើតឡើងដើម្បីដាក់អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំពី ៨.០០០នាក់ និង ១១.០០០នាក់ ។ រដ្ឋាភិបាលកំពុងសាងសង់ពន្ធនាគារថ្មី ដើម្បីដាក់អ្នកជាប់ពន្ធនាគារចំនួន ២.៥០០នាក់បន្ថែមទៀត ។ មានរបាយការណ៍ដែលលើកឡើងថា នៅក្នុងពន្ធនាគារមួយចំនួន បន្ទប់ ដែលមានទំហំ ៤០ គុណនឹង ២០ហ្វីត បានដាក់អ្នកជាប់ពន្ធនាគាររហូតដល់ទៅ ១១០នាក់ ។ នៅមជ្ឈមណ្ឌលអប់រំកែប្រែ ១កន្លែង បន្ទប់ពន្ធនាគារដែលមានទំហំ ២៦គុណនឹង២៦ ហ្វីតដាក់អ្នកជាប់ពន្ធនាគារជាមធ្យមចំនួន ៥០នាក់ ។ នៅពន្ធនាគារខ្លះ អាជ្ញាធរបានប្រើប្រាស់ ខ្នោះជើង និងដាក់អ្នកជាប់ពន្ធនាគារនៅក្នុងបន្ទប់តូចងងឹត ធ្វើជាទម្រង់ទណ្ឌកម្មធ្ងន់ធ្ងរ ។ មានរបាយការណ៍ថា យ៉ាងហោចណាស់មានអ្នកជាប់ពន្ធនាគារចំនួន ៥៨នាក់បានស្លាប់នៅក្នុងការឃុំខ្លួននៅតាមពន្ធនាគារចំនួន ១៨កន្លែង នៅក្នុងខេត្តចំនួន ១៣ក្នុងអំឡុងឆ្នាំនេះ ។

ការស៊ើបអង្កេតមួយនៅតែបន្តធ្វើរហូតដល់ខែវិច្ឆិកា ឆ្នាំ២០០៨ ជុំវិញករណីមរណភាពរបស់លោក ហេង ទូច ដែលបានស្លាប់ក្រោយពីទទួលរងរបួសនៅក្នុងពន្ធនាគារក្នុងស្ថានភាពគួរអោយសង្ស័យ ។ នៅខែមីនា តុលាការរាជធានីភ្នំពេញបានកោះហៅគ្រួសារជនរងគ្រោះ មន្ត្រីពន្ធនាគារពីរនាក់ និងវេជ្ជបណ្ឌិតពន្ធនាគារម្នាក់ដើម្បីស៊ើបសួរ ប៉ុន្តែរហូតមកដល់ដំណាច់ឆ្នាំពុំមានការចោទប្រកាន់អ្វីឡើយ ។

ពុំមានការវិវឌ្ឍអ្វីទាំងអស់នៅក្នុងករណីដូចតទៅនេះ ៖ មរណភាពរបស់ឈ្មោះ ប៊ុន វណ្ណរឹទ្ធ ក្រោយពីត្រូវបាននាំចេញពីមន្ទីរពេទ្យទៅកាន់កន្លែងឃាត់ខ្លួនរបស់នគរបាល មរណភាពរបស់អ្នកជាប់ពន្ធនាគារ យ៉ាន់ សុខគា ដែលតាមរបាយការណ៍គឺ បណ្ដាលមកពីជំងឺគ្រុនក្ដៅខ្លាំង ក្រោយពីមានការចោទប្រកាន់ថាទទួលការព្យាបាលយឺតយ៉ាវ ឬមរណភាពរបស់ស្ត្រីជរាម្នាក់ ដែលត្រូវបានបង្ខាំងនៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយពុំបាន ទទួលការថែទាំសុខភាព ។

របបឧបត្ថម្ភរបស់រដ្ឋាភិបាលសម្រាប់ទិញស្បៀងអាហារជាប្រចាំសម្រាប់អ្នកជាប់ពន្ធនាគារត្រូវបានលួចលាក់ដកទុក និងមិនគ្រប់គ្រាន់ដែលបង្កអោយមានកង្វះអាហារូបត្ថម្ភនិងជំងឺជាដើម ។ អង្គការមិនមែនរដ្ឋាភិបាលមួយបានអះអាងថា ក្នុងករណីខ្លះអាជ្ញាធរពន្ធនាគារ បានដកទុកស្បៀងអាហារ ឬសម្ភារៈចំនួនពី ២០ទៅ ៣០ភាគរយដែលគ្រួសារអ្នកជាប់ពន្ធនាគារយកមកអោយអ្នកជាប់ពន្ធនាគារ។ អង្គការសិទ្ធិមនុស្សបានអះអាងថាគ្រួសារត្រូវផ្ដល់សំណូកដល់មន្ត្រី ពន្ធនាគារដើម្បីសួរសុខទុក្ខអ្នកជាប់ពន្ធនាគារឬផ្ដល់ស្បៀងអាហារ និងរបស់របរចាំបាច់ដទៃទៀត ។ អង្គការមិនមែនរដ្ឋាភិបាលនានាក៏បានអះអាងចំពោះដំណើររឿងទាំងនេះដែរថាអ្នកជាប់ពន្ធនាគារដែល

គ្រួសាររបស់ខ្លួនបានផ្តល់ សំណូកដល់អាជ្ញាធរពន្ធនាគារបានទទួលការអនុគ្រោះ រួមមានដូចជាអាចជួបអ្នកមកសួរសុខទុក្ខ  ការផ្ទេរទៅក្នុងបន្ទប់ប្រសើរជាងមុននិងឱកាសចាកចេញពីក្នុងបន្ទប់នៅពេលថ្ងៃជាដើម។

មានរបាយការណ៍គួរអោយជឿទុកចិត្តបានថាជាញឹកញាប់ មន្ត្រីបានទាមទារប្រាក់សំណូកមុននឹងអនុញ្ញាតអោយអ្នកជាប់ពន្ធនាគារចូលរួមការជំនុំជម្រះក្តី ឬសវនការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ពន្ធនាគារដែលបានបញ្ចប់អាណត្តិជាប់ពន្ធនាគាររបស់ខ្លួនពេញលេញហើយនោះ ។

ក្នុងពន្ធនាគារភាគច្រើនបំផុត ពុំមានការបំបែកអ្នកជាប់ពន្ធនាគារជាមនុស្សពេញវ័យ និងកុមារ បុរស និងស្រី អ្នកដែលជាប់ទោសព្រហ្មទណ្ឌធ្ងន់ធ្ងរ និងអ្នកដែលត្រូវជាប់ឃុំដោយសារតែបទល្មើសស្រាលឡើយ ។ អ្នកជាប់ឃុំមុនពេលជំនុំជម្រះក្តីជាធម្មតា ត្រូវឃុំខ្លួនជាមួយអ្នកជាប់ពន្ធនាគារដែលបានជំនុំជម្រះក្តីរួចហើយ ។ យោងតាមស្ថិតិរបស់រដ្ឋាភិបាល អ្នកជាប់ពន្ធនាគារប្រមាណជា ៣២ភាគរយ ដែលជាប់ឃុំនៅក្នុងពន្ធនាគារក្រុង ឬខេត្តគឺជាអ្នកជាប់ឃុំមុនពេលជំនុំជម្រះក្តី ។

ជាទូទៅរដ្ឋាភិបាលនៅបន្តអនុញ្ញាតអោយក្រុមសិទ្ធិមនុស្សអន្តរជាតិ និងក្នុងស្រុករួមមានដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ចូលមើលពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ឆ្មាំពន្ធនាគារដដែល ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថាជួនកាលកិច្ចសហការពីអាជ្ញាធរដែនដីនៅមានកម្រិតដែលធ្វើអោយមានការលំបាកសម្រាប់ទាក់ទងអ្នកជាប់ឃុំមុនពេលជំនុំជម្រះក្តី។ ក្រសួងមហាផ្ទៃនៅតែបន្តតម្រូវអោយមេធាវីអ្នកត្រួតពិនិត្យសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀតសុំការអនុញ្ញាតមុននឹងទៅសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ។ ក្រសួងមិនព្រមផ្តល់ការ អនុញ្ញាតនេះទេនៅក្នុងករណីរសើបផ្នែកនយោបាយ។ ក្នុងករណីជាក់ស្តែងខ្លះមន្ត្រីនៅតែបន្តអនុញ្ញាតិអោយអង្គការ មិនមែនរដ្ឋាភិបាលធ្វើការសម្ភាសន៍អ្នកជាប់ពន្ធនាគារជាលក្ខណៈឯកជន ។ ចំណែកឯអង្គការ UNHCHR វិញបាន រាយការណ៍មកថា ជាធម្មតាខ្លួនមានលទ្ធភាពជួបជាលក្ខណៈឯកជននៅពេលសម្ភាសន៍អ្នកជាប់ពន្ធនាគារណាម្នាក់ដែលគួរអោយចាប់អារម្មណ៍។

## ឃ. ការចាប់ខ្លួន ឬការឃុំខ្លួនដោយបំពាន

ច្បាប់ហាមឃាត់ការចាប់ខ្លួន និងការឃុំខ្លួនដោយបំពានឡើយ ទោះជាយ៉ាងណាក៏ដោយ មានកាលៈទេសៈជាច្រើន ដែលរដ្ឋាភិបាលមិនគោរពបម្រាមទាំងនេះឡើយ ។ ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតអោយមានការឃុំខ្លួនមុនពេល ជំនុំជម្រះក្តីរហូតដល់រយៈពេល ៦ខែសម្រាប់បទមជ្ឈិម និង ១៨ខែសម្រាប់បទឧក្រិដ្ឋ ។ អ្នកជាប់ឃុំម្នាក់ក្នុង ចំណោម ១០នាក់នៅក្នុងការឃុំខ្លួនមុនពេលជំនុំជម្រះក្តី ត្រូវជាប់ឃុំលើសពីអាជ្ញាយុកាលជួនកាលដោយគ្មាន តំណាងផ្នែកច្បាប់ (មេធាវី) ឬការជំនុំជម្រះក្តីឡើយ ។ ក្រសួងមហាផ្ទៃបានរាយការណ៍ថា

មានមនុស្សចំនួន ៤២៨នាក់ស្ថិតនៅក្នុងការឃុំខ្លួនមុនពេលជំនុំជម្រះក្តីដែលលើសពីអាជ្ញាយុកាលអនុញ្ញាតចំពោះបទល្មើសដែលបាន ចោទប្រកាន់ ។

ជាងនេះទៅទៀត តុលាការមួយចំនួនបានបាត់ឯកសាររឿងក្តីនៅក្នុងអំឡុងពេលជាប់ឃុំមុនពេលជំនុំជម្រះក្តី ដែល ជាកត្តាធ្វើអោយនីតិវិធីតុលាការមានការយឺតយ៉ាវ ។ នៅថ្ងៃទី២២ ខែកក្កដា សារព័ត៌មានក្នុងស្រុកមួយបានរាយការណ៍អំពីករណីឈ្មោះ រឿង សុភា ដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យអស់រយៈពេល ៣៧ខែ កំពុងរង់ចាំការជំនុំជម្រះលើការចោទប្រកាន់អំពីការជួញដូរគ្រឿងញៀន ។ ឈ្មោះ រឿន នេះបានជាប់ពន្ធនាគារជាមួយកូនស្រីដែលជាទារិកាកាលពីពេលចាប់ខ្លួន ។ ក្រោយពេលតុលាការរកឃើញឯកសារដែលដាក់ខុសទីតាំងនោះនៅថ្ងៃទី០៥ ខែសីហាចៅក្រមបានកាត់ទោស ឈ្មោះ រឿន ពីបទចោទប្រកាន់នោះ រួចផ្តន្ទាទោសត្រឹមរយៈពេល ដែលបានជាប់ពន្ធនាគារ ។

អង្គការ ADHOC បានរាយការណ៍អំពីការចាប់ខ្លួន ឬការឃុំខ្លួនខុសច្បាប់យ៉ាងហោច ១០៣ករណីនៅអំឡុងឆ្នាំ នេះ ។ អង្គការ ADHOC បានថ្លែងថាជនរងគ្រោះនៅក្នុងករណីឃុំខ្លួនខុសច្បាប់៤៣ករណី ក្រោយមកត្រូវបាន ដោះលែងអោយមានសេរីភាពបន្ទាប់ពីមានការប្តឹងតវ៉ារបស់ជនជាប់ឃុំ អន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាល ផ្នែកសិទ្ធិមនុស្ស ឬការបង់ប្រាក់សំណូក ។ អង្គការ ADHOC មានជំនឿថាចំនួនជាក់ស្តែងនៃការចាប់ខ្លួន និង ការឃុំខ្លួនដោយបំពានមានកំណើនខ្ពស់ បន្តិចដោយសារជនរងគ្រោះមួយចំនួននៅតំបន់ជនបទមិនបានដាក់បណ្តឹង តវ៉ា ដោយសារមានការលំបាកក្នុងការធ្វើដំណើរទៅកាន់ការិយាល័យអង្គការមិនរដ្ឋាភិបាល ឬដោយសារភ័យខ្លាច ចំពោះសន្តិសុខគ្រួសារ ។ ដោយយោងតាមអង្គការ ADHOC អាជ្ញាធរមិនបានចាត់វិធានការតាមផ្លូវច្បាប់ ឬ វិន័យចំពោះជនដែលទទួលខុសត្រូវចំពោះការឃុំខ្លួនខុសច្បាប់នេះឡើយ ។

នៅអំឡុងឆ្នាំនេះ អាជ្ញាធរសាលាក្រុងភ្នំពេញបានចាប់ខ្លួនមនុស្សរាប់សិបនាក់ ដែលអ្នកទាំងនោះជាធម្មតាជាអ្នក គ្មានផ្ទះសម្បែង អ្នកមានជំងឺផ្លូវចិត្ត អ្នកប្រើប្រាស់គ្រឿងញៀន ឬអ្នកបម្រើសេវាផ្លូវភេទ នៅអំឡុងពេលបោសសម្អាតដងវិថីជាលក្ខណៈប្រព័ន្ធរបស់ខ្លួន ។ អ្នកជាប់ឃុំតែងតែបាត់បង់ប្រាក់កាស និងកម្មសិទ្ធិទាំងអស់នៅពេលបោសសម្អាតនោះ យ៉ាងហោចណាស់នៅក្នុងករណីស្ត្រីផ្ទុកមេរោគអេដស៍ម្នាក់បានបាត់បង់ថ្នាំរបស់ខ្លួនហើយ អាជ្ញាធរមិនបានផ្តល់ឱសថជំនួសឡើយ ។ អាជ្ញាធរចាត់ទុកថាការបោសសម្អាតដងវិថីគឺជាផ្នែកមួយនៃដំណើការ “កែលម្អសោភ័ណភាព” នៅក្នុងក្រុងទាំងមូល ហើយបាននាំយកអ្នកជាប់ឃុំទាំងអស់នៅក្នុងកន្លែងស្តារនីតិសម្បទា ដែលដំណើរការដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានចម្ងាយ១៥ម៉ៃល៍ពីក្រុងភ្នំពេញ ។ អ្នកជាប់ឃុំទាំងនោះបានទទួលព័ត៌មានថាខ្លួនមានសេរីភាពអាចចាកចេញបាន ប៉ុន្តែនឹងមិនទទួលបានមធ្យោបាយធ្វើដំណើរឡើយ ប្រសិនបើខ្លួនចាកចេញពីមជ្ឈមណ្ឌលស្តារនីតិសម្បទានោះ ។

## តួនាទីរបស់នគរបាល និងយន្តការសន្តិសុខ

អគ្គស្នងការនគរបាលជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ គ្រប់គ្រងអង្គភាពនគរបាលស៊ីវិល ។ កម្លាំង នគរបាលត្រូវបែងចែកជាកម្លាំងដែលមានអំណាចដើម្បីធ្វើការចាប់ខ្លួន កម្លាំងដែលគ្មានអំណាចចាប់ខ្លួន និងនគរបាលយុត្តិធម៌ ។ កងរាជអាវុធហត្ថទទួលបានការអនុញ្ញាតអោយចាប់ខ្លួនជនស៊ីវិល ប្រសិនបើមន្ត្រីទាំងនោះបំពេញលក្ខខណ្ឌការបណ្តុះបណ្តាល និងបទពិសោធន៍ ដើម្បីបំពេញការងារជានគរបាលយុត្តិធម៌ ប្រសិនបើជនស៊ីវិលប្រើប្រាស់ទ្រព្យសម្បត្តិយោធា ឬក្នុងករណីទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ។

មន្ត្រីនគរបាលបានធ្វើឃាតប្រជាពលរដ្ឋ និងប្រព្រឹត្តអំពើរំលោភបំពានផ្សេងៗដោយមាននិរទណ្ឌភាព ហើយក្នុងករណីភាគច្រើនបំផុត រដ្ឋាភិបាលបានចាត់វិធានការបន្តិចបន្តួចឬពុំមានចាត់វិធានការអ្វីឡើយ ។ មានរបាយការណ៍ជាច្រើនដែលលើកឡើងថានគរបាលព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះបានទទួលសំណូកពីម្ចាស់អាជីវកម្មខុសច្បាប់ ។

ច្បាប់តម្រូវអោយនគរបាល ព្រះរាជអាជ្ញា និងចៅក្រមធ្វើការស៊ើបអង្កេតរាល់ពាក្យបណ្តឹងទាំងអស់ រួមទាំងបណ្តឹងអំពីការរំលោភបំពានរបស់នគរបាលផងដែរ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង ចៅក្រម និងព្រះរាជអាជ្ញាកម្រធ្វើការស៊ើបសួរដោយឯករាជ្យដែលជាផ្នែកមួយនៃដំណើរការជំនុំជម្រះក្តីជាសាធារណៈណាស់។ ចៅក្រមជំនុំជម្រះ ជាធម្មតា ចេញសាលក្រមផ្អែកតាមតែរបាយការណ៍ជាលាយលក្ខណ៍អក្សរដែលទទួលបានមកពី នគរបាល និងសក្ខីកម្មរបស់សាក្សីតែប៉ុណ្ណោះ។ ជាទូទៅ នគរបាលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តិចបន្តួច តែប៉ុណ្ណោះ ។ នគរបាលដែលមិនបានទប់ស្កាត់ ឬឆ្លើយតបចំពោះអំពើហឹង្សានៅក្នុងសង្គម កម្រនឹងត្រូវបានដាក់ វិន័យណាស់ ។

នៅថ្ងៃទី២២ ខែមីនា នគរបាលឃុំម្នាក់ឈ្មោះ ធឿន ហុក បានបើកការបាញ់ប្រហារទៅលើហ្វូងអ្នកភូមិនៅឃុំជីក្រែង ខេត្តសៀមរាប បណ្តាលអោយអ្នកភូមិពីរនាក់រងរបួស ។ មន្ត្រីនគរបាលមិនស្គាល់ឈ្មោះម្នាក់ ទៀតបានបាញ់ប្រហារធ្វើអោយរបួសអ្នកភូមិទីបី ។ អភិបាលខេត្តបានបញ្ជូនកងកម្លាំងប្រដាប់អាវុធចម្រុះ រួមមាននគរបាលស្រុក កងរាជអាវុធហត្ថ និងទាហាន ដើម្បីបណ្តេញអ្នកភូមិចេញពីដីកសិដ្ឋានដែលមានវិវាទមួយកន្លែង។ ជាដំបូងអាជ្ញាធរខេត្តបានឃុំខ្លួនអ្នករងរបួស ប៉ុន្តែបន្ទាប់មកបាននាំអ្នកទាំងនោះទៅកាន់មន្ទីរពេទ្យ ប្រមាណជាបីម៉ោងក្រោយពីការបាញ់ប្រហារបានកើតឡើង ។ នៅថ្ងៃទី១៨ ខែសីហា ហើយនៅក្នុងព្រឹត្តិការណ៍ពីលើកក្រោយមកទៀត ក្រសួងយុត្តិធម៌បានចេញលិខិតមួយច្បាប់ផ្ញើជូនអាជ្ញាធរខេត្ត ដោយស្នើអោយចាត់វិធានការក្នុងករណីនេះ ប៉ុន្តែបទបញ្ជាទាំងនោះមិនត្រូវបានអនុវត្តឡើយ ។

នៅថ្ងៃទី២២ ខែមិថុនា ពលបាលត្រីនៃនគរបាលខេត្តម្នាក់បានបាញ់អោយរបួសអ្នកភូមិម្នាក់នៅខេត្តរតនៈគិរី នៅអំឡុងពេល ការតវ៉ាអំពីដីសម្បទានសេដ្ឋកិច្ចមួយកន្លែងដែលត្រូវបានជួលទៅអោយក្រុមហ៊ុនឯកជនមួយ ។ ពលបាលត្រីនោះត្រូវបានឃាត់ ខ្លួនទុកនៅស្នងការនគរបាលខេត្តដើម្បីចាត់វិធានការវិន័យ ។ មានទាហានជាច្រើន

រូបត្រូវបានរាយការណ៍ថាបានធ្វើអោយអ្នក ភូមិម្នាក់ទៀតរងរបួសនៅក្នុងជម្លោះវាយតប់គ្នាមួយ ហើយបានបាញ់កាំភ្លើងជាច្រើនលើក ប៉ុន្តែពុំមានបំណង ឬបង្ករបួសស្នាម ដល់អ្នកភូមិណាម្នាក់ឡើយ ។

ពុំមានការវិវឌ្ឍនៅក្នុងករណីរបស់លោកវរសេនីយត្រី មឿ បូរ៉ា នៃកងពលតូចលេខ៧០ នៅខែកក្កដា ឆ្នាំ២០០៨ ដែលតាម របាយការណ៍ នាយទាហានរូបនេះបានវាយដុំបុរសពីរនាក់ក្រោយពីមានគ្រោះថ្នាក់ចរាចរណ៍បន្តិចបន្តួច ឬនៅក្នុងករណីកាលពីខែកញ្ញា ឆ្នាំ២០០៨ អំពីអង្គរក្សរដ្ឋាភិបាលដែលរងការចោទប្រកាន់ថាបានបាញ់សម្លាប់ស្ត្រីម្នាក់នៅក្នុងរង្គសាលមួយនោះ ។

## នីតិវិធីចាប់ខ្លួន និងការប្រព្រឹត្តនៅពេលឃុំខ្លួន

ច្បាប់តម្រូវអោយនគរបាលសុំដីកាពីចៅក្រមស៊ើបសួរមុនពេលធ្វើការចាប់ខ្លួនប៉ុន្តែនគរបាលអាចចាប់ខ្លួនដោយគ្មានដីកាចំពោះជនណាដែលត្រូវបានប្រទះឃើញកំពុងប្រព្រឹត្តបទឧក្រិដ្ឋ។ ច្បាប់អនុញ្ញាតអោយនគរឃាត់ខ្លួនបុគ្គលណាម្នាក់ រួចធ្វើការស៊ើបសួរក្នុងរយៈពេល២៤ម៉ោងដោយមិនរាប់បញ្ចូលរយៈពេលចុងសប្តាហ៍និងថ្ងៃឈប់សម្រាកផ្លូវការមុននឹងធ្វើការចោទប្រកាន់ ។ ក្នុងករណីបទឧក្រិដ្ឋក្នុងស្ថានភាពពិសេសដែលចែងដោយច្បាប់នគរបាលអាចឃុំខ្លួនជនសង្ស័យរយៈពេល ២៤ម៉ោងបន្ថែមដោយមានការឯកភាពពីព្រះរាជអាជ្ញា។ ទោះជាយ៉ាងនេះក្តី ជាទម្លាប់អាជ្ញាធរតែងតែឃុំខ្លួនមនុស្សហួសរយៈពេលកំណត់មុននឹងធ្វើការចោទប្រកាន់ ។ អ្នកជាប់ពន្ធនាគារជាច្រើន ជាពិសេសអ្នកដែលគ្មានតំណាងផ្នែកច្បាប់ឬមេធាវី គ្មានឱកាសស្វែងរកការដោះលែងដោយការធានាអោយនៅក្រៅឃុំឡើយ ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទ អាចត្រូវបានចាប់ខ្លួន និងឃុំខ្លួនរយៈពេល ២៤ម៉ោង មុននឹងទទួលបានលទ្ធភាពស្វែងរកប្រឹក្សាផ្នែកច្បាប់ ប៉ុន្តែអ្នកជាប់ពន្ធនាគារជាធម្មតាត្រូវជាប់ឃុំជាច្រើនថ្ងៃមុននឹងទទួលបានមេធាវី ឬជួបសមាជិកគ្រួសារ ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនយូរអង្វែងនេះភាគច្រើនបណ្តាលមកពីសមត្ថភាពមានកម្រិតរបស់ប្រព័ន្ធតុលាការ។

នៅថ្ងៃទី២២ ខែមេសា តុលាការខេត្តកំពតបានផ្តន្ទាទោសនគរបាលម្នាក់ឈ្មោះ ព្រាប ពៅ ដោយកាត់ក្តីកំបាំងមុខអោយជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ ។ នគរបាលសណ្តាប់ធ្នាប់រាជធានីភ្នំពេញបានឃុំខ្លួន ឈ្មោះ ព្រាប ពៅ អស់រយៈពេលប្រាំពីរសប្តាហ៍កាលពីខែកុម្ភៈ ឆ្នាំ២០០៨ ដោយត្រូវបានចោទពីបទចូលរួមនៅក្នុងវិវាទដីធ្លីនៅក្រុងកែប ។ ឈ្មោះ ព្រាប ពៅ បានប្តឹងឧទ្ធរណ៍ចំពោះការសម្រេចនោះ ហើយនៅតែបន្តលាក់ខ្លួននៅឡើយនៅដំណាច់ឆ្នាំនេះ ។

នៅដំណាច់ឆ្នាំនេះ ពុំមានការកំណត់ពេលវេលាសម្រាប់ជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដោយមនុស្ស ៦នាក់ដែលបានផ្តន្ទា ទោសនៅឆ្នាំ២០០៧ ដោយតុលាការរាជធានីភ្នំពេញពីបទរៀបចំផែនការបំផ្ទុះគ្រាប់បែកក្នុងអំឡុងពិធីបុណ្យអុំទូក នៅឆ្នាំ២០០៦ ឡើយ ។

ក្នុងករណីឆ្នាំ២០០៧ យុវជនជនជាតិភាគតិចចារ៉ាយម្នាក់អាយុ១៣ឆ្នាំត្រូវបានផ្តន្ទាទោសរយៈពេល៨ខែ និង ១០ថ្ងៃទោះបីជាកុមារនេះស្ថិតក្រោមអាយុអប្បបរមាដែលត្រូវដាក់ពន្ធនាគារនៅពេលចាប់ខ្លួនក៏ដោយ ។ មេធាវីរបស់យុវជននេះបានអះអាង អំពីការដោះលែងយុវជននេះ ដោយបណ្តឹងឧទ្ធរណ៍កាលពីឆ្នាំ២០០៧ ។

## ការលើកលែងទោស

ព្រះមហាក្សត្រអាចប្រទានការលើកលែងទោសក្នុងករណីមួយចំនួន ដែលជារឿយៗ ព្រះអង្គធ្វើឡើងនៅអំឡុង ពិធីបុណ្យព្រះពុទ្ធសាសនាសំខាន់ៗ និងថ្ងៃបុណ្យជាតិ ។ ក្រសួងមហាផ្ទៃបានរាយការណ៍ថា ព្រះបាទនរោត្តម សីហមុនីបានប្រទានការ លើកលែងទោសដល់មនុស្ស៧៥នាក់ នៅអំឡុងឆ្នាំនេះ ។

## ខ. ការបដិសេធមិនអោយទទួលបានការជំនុំជម្រះក្តីជាសាធារណៈដោយយុត្តិធម៌

រដ្ឋធម្មនុញ្ញបានចែងថាតុលាការមានភាពឯករាជ្យ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលជាទូទៅមិនគោរពឯករាជ្យភាពរបស់តុលាការឡើយ ។ តុលាការស្ថិតក្រោមឥទ្ធិពល និងអន្តរាគមន៍របស់អង្គនីតិប្រតិបត្តិ ហើយកើត មានអំពើពុករលួយយ៉ាងរីករាលដាលក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ។

ប្រព័ន្ធតុលាការ រួមមានសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ រដ្ឋធម្មនុញ្ញក៏មានការបែងចែងអំណាច អោយក្រុមប្រឹក្សាធម្មនុញ្ញមួយផងដែរ ដែលមានអំណាចពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ និងឧត្តមក្រុមប្រឹក្សា អង្គចៅក្រមដែលជាអ្នកតែងតាំង ត្រួតពិនិត្យ និងដាក់វិន័យដល់ចៅក្រម និងព្រះរាជអាជ្ញា ។ សមាសភាព របស់ក្រុមប្រឹក្សាទាំងពីរនេះមានភាពលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជាយ៉ាងខ្លាំង ។

មានប្រព័ន្ធតុលាការយោធាដាច់ដោយឡែក ដែលទទួលរងនូវការខ្វះខាតស្រដៀងគ្នាទៅនឹងប្រព័ន្ធតុលាការស៊ីវិល ដែរ ។ ទោះបីជាជនស៊ីវិលអាចស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការយោធាក្នុងករណីមួយចំនួនក៏ដោយ ក៏ការ បែងចែកផ្នែកច្បាប់រវាងតុលាការយោធា និងតុលាការស៊ីវិល ជួនកាលមិនត្រូវបានយកចិត្តទុកដាក់នៅក្នុងការ អនុវត្តជាក់ស្តែងឡើយ ។

នៅថ្ងៃទី២៣ ខែវិច្ឆិកា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) បានបើកសវនការស្តាប់ការវែកញែក បិទសំណុំរឿង លោកកាំង ហ្កេចអៀវ (ហៅឌុច) អតីតប្រធានមន្ទីរធ្វើទារុណកម្ម ស២១ (ទួលស្លែង) ដែលត្រូវ ចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ (ឧក្រិដ្ឋកម្មសង្គ្រាម) ឃាតកម្មដោយចេតនា និងទារុណកម្ម ។ សាលក្រមត្រូវចេញនៅដើមឆ្នាំ២០១០ ។ ECCC បន្តស៊ើបសួរចំពោះករណីមេដឹកនាំខ្មែរក្រហមស្ថិតក្នុងការឃុំខ្លួនចំនួន ៤រូបទៀត ដែលត្រូវចោទប្រកាន់ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងប្រល័យពូជសាសន៍ ។ នៅថ្ងៃទី០២ ខែ

កញ្ញា ការិយាល័យសហព្រះរាជអាជ្ញាអន្តរជាតិបានប្រគល់បញ្ជីឈ្មោះជន ៥នាក់បន្ថែមទៀត អោយសហចៅក្រម ស៊ើបសួរពិនិត្យ និងអាចត្រូវកាត់ទោសនៅពេលអនាគត ។

## នីតិវិធីជំនុំជម្រះក្តី

ការជំនុំជម្រះក្តីធ្វើឡើងជាសាធារណៈ ។ គណៈវិនិច្ឆ័យមិនត្រូវបានប្រើប្រាស់ឡើយ ដោយចៅក្រមជំនុំ ជម្រះ មានអំណាច ចេញសាលក្រមបាន ។ ចុងចោទមានសិទ្ធិចូលរួមសវនការ និងពិគ្រោះយោបល់ជាមួយមេធាវី ប្រឈមមុខ និងសួរនាំសាក្សីប្រឆាំងនឹងខ្លួន ព្រមទាំងបង្ហាញសាក្សី និងភស្តុតាងក្នុងនាមខ្លួនផ្ទាល់ ។ ក្នុងករណី ព្រហ្មទណ្ឌ ប្រសិនបើចុងចោទមិនអាចរកមេធាវីម្នាក់បាន តុលាការត្រូវផ្តល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃ ដល់ ចុងចោទ ទោះជាយ៉ាងណាក៏ដោយជារឿយៗ តុលាការតែងតែខ្វះធនធានដើម្បីផ្តល់ប្រឹក្សាផ្នែកច្បាប់ ហើយ ចុងចោទភាគច្រើនបំផុតស្វះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬត្រូវឡើងតុលាការដោយគ្មានតំណាង ផ្នែកច្បាប់ ។ ការជំនុំជម្រះក្តីផ្អែកតាមប្រព័ន្ធក្រមស៊ីវិល ជាតួយ៉ាង ធ្វើឡើងគ្រាន់តែ បង្គ្រប់កិច្ច ចំណែកការពិនិត្យ ផ្ទៀងផ្ទាត់អោយបានគ្រប់ជ្រុងជ្រោយ ជាធម្មតា មិនបានកើតមានឡើយ ។ ចុងចោទ និងមេធាវី របស់ខ្លួន មាន សិទ្ធិពិនិត្យមើលភស្តុតាងដែលរដ្ឋាភិបាលរក្សាទុក ទាក់ទងនឹងរឿងក្តីរបស់ខ្លួន ទោះជាយ៉ាងណាក៏ដោយ ក្នុង កាលៈទេសៈដ៏កម្រ មានការពិបាកនឹងទទួលបានលទ្ធភាពដូចពោលនេះណាស់ជាពិសេស ប្រសិនបើសំណុំរឿង នោះពាក់ព័ន្ធនឹងរឿងនយោបាយ ឬពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ឬសមាជិកឥស្សរជនដែលមានខ្សែរយៈរឹង មាំ ។

តាមច្បាប់ ចុងចោទទទួលបានសិទ្ធិសន្មតថាជាជនស្លូតត្រង់ និងមានសិទ្ធិឧទ្ធរណ៍ ប៉ុន្តែដោយសារអំពើ ពុករលួយ រីករាលដាលនោះ ជារឿយៗចុងចោទត្រូវសូកចៅក្រម ដើម្បីទទួលបានសាលក្រមដែលមានលក្ខណៈ អនុគ្រោះ ។ សិទ្ធិឧទ្ធរណ៍របស់ប្រជាពលរដ្ឋ ជួនកាល ជួបឧបសគ្គដោយសារមានការលំបាកក្នុងការផ្ទេរអ្នកជាប់ ពន្ធនាគារពី ពន្ធនាគារខេត្តទៅកាន់សាលាឧទ្ធរណ៍នៅភ្នំពេញ ។ ជាលទ្ធផល ជាងពាក់កណ្តាលនៃបណ្តឹងឧទ្ធរណ៍ ទាំងអស់ ត្រូវបានបើកសវនការដោយកំបាំងមុខចុងចោទ ។

នៅថ្ងៃទី១៦ ខែកុម្ភៈ សាលាឧទ្ធរណ៍ មានតំកល់ទុកសាលក្រមឆ្នាំ២០០៥ របស់ឈ្មោះថាច់ សារ៉េត ចំពោះករណី ធ្វើឃាតមេដឹកនាំសហជីពកម្មករឈ្មោះ រស់ សុវណ្ណារ៉េត ។ មេធាវីរបស់ឈ្មោះថាច់ សារ៉េត អង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក និងអង្គការពលកម្មអន្តរជាតិ (ILO) បានបន្តរាយការណ៍អំពីភាពមិនប្រក្រតី នៃនីតិវិធីជំនុំ ជម្រះក្នុងរឿងក្តី នេះ និងកង្វះភស្តុតាង ដែលផ្សារភ្ជាប់ ឈ្មោះ ថាច់ សារ៉េត ទៅនឹងបទឧក្រិដ្ឋនេះ ។

កង្វះធនធាន បៀវត្សន៍ទាប និងការបណ្តុះបណ្តាលដែលមានលក្ខណៈទន់ខ្សោយ រួមចំណែកអោយមាន អំពើពុករលួយ និងអប្រសិទ្ធភាពកម្រិតខ្ពស់ នៅក្នុងអង្គតុលាការ ហើយរដ្ឋាភិបាលមិនបានធានាអោយមាន ដំណើរការត្រឹមត្រូវឡើយ ។

អ្នកសង្កេតការណ៍ បានរាយការណ៍ថា មានរឿងក្តីជាច្រើនមិនទាន់បានជំនុំជម្រះ ដោយសារខ្វះចៅក្រម និងបន្ទប់ សវនាការ ។ អ្នកសង្កេតការណ៍ ក៏បានសង្ស័យថា មន្ត្រីតុលាការអាចផ្តោតទៅលើរឿងក្តីណាដែលខ្លួនអាចទទួល ផលប្រយោជន៍ហិរញ្ញវត្ថុ ។

នៅតែមានកង្វះខាតយ៉ាងធ្ងន់ធ្ងរនូវមេធាវីដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ជាពិសេសនៅតំបន់ក្រៅ ទីក្រុងភ្នំពេញ ។ អ្នកដែលគ្មានមធ្យោបាយស្វែងរកប្រឹក្សាច្បាប់ ជារឿយៗ ត្រូវបានបដិសេធសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ។ យោងតាមគណៈមេធាវី មេធាវីចំនួនប្រមាណ ៣០ ភាគរយក្នុងចំណោមមេធាវីចំនួន ៧១២នាក់ដែលមាននៅទូទាំងប្រទេស បានផ្តល់ប្រឹក្សាផ្នែកច្បាប់ ដល់ជនក្រីក្រ ដោយឥតគិតថ្លៃ ដែលមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីធានាសិទ្ធិស្របច្បាប់ជាមូលដ្ឋានរបស់ជនក្រីក្រទាំងអស់នៅក្នុងប្រទេសឡើយ ។

សម្បថជាលាយលក្ខណ៍អក្សររបស់សាក្សី និងជនជាប់ចោទ ជាធម្មតា គឺជាភស្តុតាងតែមួយមុខគត់ដែលត្រូវបានបង្ហាញនៅពេលជំនុំជម្រះ ។ សេចក្តីថ្លែងរបស់ជនត្រូវចោទ ជួនកាលត្រូវបានធ្វើឡើងដោយបង្ខំតាមរយៈការវាយដំ ឬការគម្រាមកំហែង ហើយជារឿយៗចុងចោទដែលមិនចេះអក្សរ មិនបានដឹងអំពីខ្លឹមសារសារភាពជាលាយលក្ខណ៍អក្សរដែលពួកគេត្រូវបង្ខំអោយចុះហត្ថលេខាឡើយ ។ ក្នុងករណីពាក់ព័ន្ធនឹងបុគ្គលិកយោធា ជារឿយៗ មន្ត្រីយោធាតែងតែដាក់សម្ពាធទៅលើចៅក្រមតុលាការព្រហ្មទណ្ឌស៊ីវិល អោយដោះលែងចុងចោទដោយគ្មានការជំនុំជម្រះ ។

ការយឺតយ៉ាវ និងអំពើពុករលួយរបស់តុលាការ ជារឿយៗ បណ្តោយអោយជនជាប់ចោទគេចផុតពីការកាត់ទោស ។ មន្ត្រីរដ្ឋាភិបាល ឬសមាជិកគ្រួសាររបស់មន្ត្រីរដ្ឋាភិបាលដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជារឿយៗត្រូវបានលើកលែង ទោស ។

ក្នុងរឿងក្តីព្រហ្មទណ្ឌជាច្រើន ចុងចោទដែលមានទ្រព្យសម្បត្តិ ឬអំណាច រួមទាំងសមាជិកកងកម្លាំងសន្តិសុខ ផងដែរ ជាធម្មតាបង់ប្រាក់ទៅអោយជនរងគ្រោះ និងអាជ្ញាធរ អោយបោះបង់ការចោទប្រកាន់រឿងព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកទាំងនោះ ។ អាជ្ញាធរល្បីខាងបង្ខំអោយជនរងគ្រោះ ឬក្រុមគ្រួសាររបស់អ្នកទាំងនោះទទួលយក សំណងជាប្រាក់ ជាថ្នូរនឹងការបោះបង់ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬជាថ្នូរនឹងការមិនបង្ហាញខ្លួនជាសាក្សី ។

នៅថ្ងៃទី១៧ ខែសីហា សាលាឧទ្ធរណ៍បានបើកសវនាការថ្មីមួយក្នុងរឿងក្តី ប៊ិន សំណាង និង សុខ សំអឿន ដោយបានរកឃើញថារឿងក្តីនេះគួររក្សាទុកនៅសាលាឧទ្ធរណ៍ ដើម្បីធ្វើការស៊ើបអង្កេតឡើងវិញ និងរង់ចាំការជំនុំ ជម្រះឡើងវិញ ។ បុរសទាំងពីរបានចំណាយពេលជិត៥ឆ្នាំ នៅក្នុងពន្ធនាគារ ចាប់តាំងពីពេលត្រូវ

ចាប់ខ្លួនកាលពីឆ្នាំ ២០០៤ និងត្រូវកាត់ទោសចំពោះឃាតកម្មលើប្រធានសហជីពកម្មករ ឈ្មោះ ជា វិជ្ជា មុននឹងតុលាការកំពូលបាន បញ្ជាអោយមានការជំនុំជម្រះឡើងវិញ នៅខែធ្នូ ឆ្នាំ២០០៨ ហើយត្រូវបានដោះលែងអោយនៅក្រៅឃុំ ។ មក ដល់ដំណាច់ឆ្នាំនេះ ជនទាំងពីរនៅតែមានសេរីភាពនៅក្រៅឃុំដដែលរង់ចាំការចាត់ការជាបន្តរបស់សាលាឧទ្ធរណ៍ ។

## អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយ

ពុំមានរបាយការណ៍អំពីអ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយឡើយ ។

## នីតិវិធីតុលាការស៊ីវិល និងដំណោះស្រាយ

ប្រទេសកម្ពុជាមានអង្គតុលាការមួយសម្រាប់បណ្តឹងរដ្ឋប្បវេណីហើយប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្តឹងស្វែងរកសំណងការខូចខាតសម្រាប់ការរំលោភសិទ្ធិមនុស្ស ។ ជាទូទៅ មានទាំងដំណោះស្រាយផ្នែករដ្ឋបាល ព្រមទាំង ដំណោះស្រាយផ្នែកតុលាការ ។ ការអនុវត្តសាលដីកាតុលាការសម្រាប់រឿងក្តីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ជារឿយៗ តែងតែមានបញ្ហា ។ ជួនកាល បុគ្គលបែរទៅរកយុត្តិធម៌អប្បមាទទៅវិញ ។

## ច. ការរំខានដោយបំពានទៅលើភាពឯកជន គ្រួសារ គេហដ្ឋាន ឬការទំនាក់ទំនង

ច្បាប់មានចែងអំពីភាពឯកជននៃការរស់នៅ និងការទំនាក់ទំនង ព្រមទាំងហាមឃាត់ចំពោះការឆែកឆេរខុសច្បាប់ ទោះជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍បានរាយការណ៍ថា ជាទម្លាប់នគរបាលធ្វើការឆែកឆេរ និងការរឹបអូស ដោយគ្មានដីកា ។

នៅតែបន្តមានរបាយការណ៍យ៉ាងច្រើនអំពីអាជ្ញាធរចូលក្នុងផ្ទះ និងដីធ្លីឯកជន ដោយគ្មានការអនុញ្ញាតពី តុលាការ ។ ដោយសារមានការប្រមូលផ្តុំដោយបង្ខំនៅអំឡុងសម័យខ្មែរក្រហម និងការវិលត្រឡប់នៃជនភៀស ខ្លួនរាប់សែននាក់ កម្មសិទ្ធិដីធ្លី ជារឿយៗមានលក្ខណៈមិនច្បាស់លាស់ ។ ច្បាប់ភូមិបាលឆ្នាំ២០០១ ចែងថា បុគ្គល ណាដែលបានកាន់កាប់ដីធ្លី ឯកជន ឬដីធ្លីឯកជនរបស់រដ្ឋ (មិនមែនដីធ្លីសាធារណៈរបស់រដ្ឋ) ដោយគ្មានការជំទាស់ រយៈពេល៥ឆ្នាំ មុនពេលប្រកាសអោយប្រើច្បាប់ភូមិបាលឆ្នាំ២០០១ មានសិទ្ធិស្នើសុំកម្មសិទ្ធិផ្តាច់មុខលើដីធ្លីនោះ។ ប្រជាជនក្រីក្រក្នុងប្រទេសភាគច្រើនបំផុតនៅតែបន្តខ្វះខាតឯកសារផ្លូវការទាក់ទងនឹងកម្មសិទ្ធិដីធ្លីនៅឡើយ ។

ការិយាល័យសុរិយោដីខេត្ត និងស្រុក នៅតែបន្តអនុវត្តតាមនីតិវិធីចុះបញ្ជីដីធ្លីមុនឆ្នាំ២០០១ ដែលពុំមានការវាស់វែងដីត្រឹមត្រូវ និងឱកាសសម្រាប់សុំយោបល់ពីសាធារណជន ។ គណៈកម្មការសុរិយោដីមិនបានអនុវត្តការកំណត់អត្តសញ្ញាណ និងកំណត់ព្រំដីរបស់រដ្ឋដែលនាំអោយមានទំនាស់ដីធ្លីជាច្រើន ការបណ្តេញដោយបំពាន និងការអភិវឌ្ឍរបស់រដ្ឋដោយគ្មានការត្រួតពិនិត្យ ការកំណត់ច្បាស់លាស់ ។ ការកេងចំណេញពីដីធ្លី ជារឿយ ជាទម្រង់ដីសម្បទាននៅតែបន្តជំរុញអោយមានទំនាស់នៅគ្រប់ខេត្ត ហើយនាំអោយមានភាពតានតឹងកាន់តែខ្លាំងរវាង

សហគមន៍ជនបទ និងឈ្មួញដីធ្លី ។ សហគមន៍តាមទីក្រុង ប្រឈមមុខនឹងការបណ្តេញចេញដោយបង្ខំដើម្បី បើកផ្លូវអោយគម្រោងអភិវឌ្ឍពាណិជ្ជកម្មនានា ប៉ុន្តែដីធ្លីដែលបានបោសសម្អាតមួយចំនួននៅពុំឃើញមានការ អភិវឌ្ឍអ្វីឡើយមកដល់ដំណាច់ឆ្នាំនេះ ។

គណ:កម្មការសុរិយោដីនៅតែបន្តបំពេញមុខងាររបស់ខ្លួនយ៉ាងយឺតយ៉ាវដដែល ។ តុលាការនៅតែជាអ្នកទទួល ខុសត្រូវដោះស្រាយវិវាទក្នុងករណីដីត្រូវបានចុះបញ្ជី ឬអ្នកជំទាស់មានប័ណ្ណកម្មសិទ្ធិដីធ្លី ។ អាជ្ញាធរជាតិដោះ ស្រាយវិវាទដីធ្លី គ្មានប្រសិទ្ធភាព ហើយមានការច្រឡំគ្នាកើតមានឡើងអំពីយុត្តាធិការរបស់អាជ្ញាធរនេះ ដែល ជាន់ការងារគ្នាជាមួយគណ:កម្មការសុរិយោដីជាតិ និងខេត្ត ។ ទោះបីជាមានការអំពាវនាវពីមន្ត្រីរដ្ឋាភិបាលនានា អោយបង្កើនសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាពលរដ្ឋគ្មានដីធ្លីយ៉ាងណាក៏ដោយក៏ការអនុវត្តនៅតែមានកម្រិតដដែល។

នៅថ្ងៃទី០៤ ខែកញ្ញា រដ្ឋាភិបាលបានលុបចោលជំនួយពីធនាគារពិភពលោកសម្រាប់កម្មវិធីគ្រប់គ្រង និងរដ្ឋបាលដី របស់ខ្លួនដែលបញ្ជាក់អំពី "ស្ថានភាពស្មុគស្មាញ" សម្រាប់ការបញ្ជាក់កម្មសិទ្ធិដីធ្លី ។ ធនាគារពិភពលោក បានវាយតម្លៃកម្មវិធីនេះ នៅខែសីហា ហើយបានរកឃើញថារដ្ឋាភិបាលមិនបានអនុវត្តតាមលក្ខខ័ណ្ឌតម្រូវ សម្រាប់ក្របខ័ណគោលនយោបាយតាំងទីលំនៅជាថ្មីឡើយ ។ រដ្ឋាភិបាលបានបន្តកម្មវិធីនេះដោយខ្លួនឯង ។

ករណីអ្នកស្រុកត្រូវបានបណ្តេញអោយផ្លាស់ប្តូរទីលំនៅ នៅតែបន្តកើតមាន នៅពេលមន្ត្រី ឬអាជីវករឃុបឃិតគ្នា ជាមួយអាជ្ញាធរ ទោះជាយ៉ាណាក៏ដោយចំនួនបានធ្លាក់ចុះយ៉ាងច្រើនកាលពីឆ្នាំ២០០៨ ។ មានបុគ្គលមួយចំនួន ក៏បានប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីបំភិតបំភ័យប្រជាជនក្រីក្រ និងជនងាយរងគ្រោះ អោយដោះដូរដីធ្លីរបស់ខ្លួន យកសំណងដែលទាបជាងតម្លៃទីផ្សារដែរ ។ អង្គការ ADHOC បានរាយការណ៍ថា ខ្លួនបានទទួលករណី ទាក់ ទងនឹងដីធ្លីចំនួន ១៨៦ករណីនៅអំឡុងឆ្នាំនេះ ។ នៅអំឡុងពេលនេះដែរ អង្គការ មិនមែនរដ្ឋាភិបាលមួយផ្សេង ទៀតបានទទួលបណ្តឹងទាក់ទងនឹងបញ្ហាដីធ្លីចំនួន ១១៥ករណីនៅភ្នំពេញ និង១៤ខេត្ត ដែលប៉ះពាល់ដល់ប្រជាជន ចំនួន ៨.៨០៦គ្រួសារ ។ ជារឿយៗ ប្រជាជនក្រីក្រគ្មានឯកសារស្របច្បាប់ដើម្បី បញ្ជាក់អំពីការទាមទារដីធ្លី របស់ខ្លួនឡើយ ហើយខ្វះជំនឿទៅលើប្រព័ន្ធយុត្តិធម៌ ។ ប្រជាជនមួយចំនួនដែលត្រូវ បណ្តេញចេញដោយ ជោគ ជ័យបានតវ៉ាចំពោះវិធានការទាំងនេះនៅក្នុងតុលាការ ប៉ុន្តែករណីភាគច្រើននៅក្នុង តុលាការកំពុងស្ថិតក្នុង ដំណើរ ការដោះស្រាយនៅឡើយ ។

នៅថ្ងៃទី២៤ ខែមករា នគរបាល កងរាជអាវុធហត្ថ អាជ្ញាធររាជធានី និងនិយោជិតក្រុមហ៊ុនសំណង់ 7NG បាន បណ្តេញដោយបង្ខំនូវប្រជាជនរស់នៅសហគមន៍ដីក្រហមនៅក្នុងតំបន់ទន្លេបាសាក់ ក្រុងភ្នំពេញ ។ នៅអំឡុង ពេល បណ្តេញដោយមិនបានប្រកាសអោយដឹងនោះ អ្នករស់នៅទីនោះបានចរចាសុំកញ្ចប់សំណងជាមួយសាលា រាជធានី ភ្នំពេញ និងក្រុមហ៊ុន 7NG ។ នគរបាលបាញ់ឧស្ម័នបង្ហូរទឹកភ្នែក និងគ្រាប់កាំភ្លើងជ័រទៅរកក្រុមអ្នក តវ៉ាមួយក្រុម ក្នុងបំណងជំរុញការបណ្តេញចេញនោះ ធ្វើអោយមានអ្នករងរបួសចំនួនយ៉ាងហោច ១៦នាក់ នៅ

ពេលនោះ និយោជិតរបស់ក្រុមហ៊ុន 7NG បានរុះរើផ្ទះ សម្បែងរបស់អ្នករស់នៅទីនោះចោល ។ គ្រឿងចក្រឈូសឆាយ របស់ក្រុមហ៊ុន 7NG បានបុកកំទេចផ្ទះសម្បែងមួយចំនួន ដែលមានមនុស្សនៅក្នុងនោះនៅឡើយ ហើយធ្វើអោយ មនុស្សពីរនាក់រងរបួសយ៉ាងធ្ងន់ធ្ងរ ។ អាជ្ញាធររាជធានី និងនិយោជិតរបស់ក្រុមហ៊ុន 7NG បាននាំអ្នកដែលត្រូវ បណ្តេញចេញទាំងនោះទៅកាន់កន្លែងតាំងទីលំនៅថ្មីដែលបានកំណត់ជាស្រេច នៅក្នុងសហគមន៍ដំណាក់ត្រយឹង មានចំណាយប្រមាណជា ១០ម៉ៃល៍ខាងលិចក្រុងភ្នំពេញ ដែលខ្វះផ្ទះល្វែងគ្រប់គ្រាន់សម្រាប់ សហគមន៍ ដែលបានតាំងទីលំនៅ និងបរិក្ខារប្រើប្រាស់ជាមូលដ្ឋានដូចជាទឹក និងប្រព័ន្ធបង្ហូរទឹកជាដើម ។ ក្រោយពី ព្រឹត្តិការណ៍នោះភ្លាម អ្នកដែលត្រូវបណ្តេញចេញទាំងនោះ រស់នៅក្រោមតង់តាមដងផ្លូវជាប់នឹងសហគមន៍ដំណាក់ ត្រយឹង និងពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាល ដើម្បីទទួលបានការគាំទ្រផ្នែកមនុស្សធម៌ជាមូលដ្ឋាន ។ មក ដល់ដំណាច់ឆ្នាំនេះ ទើបក្រុមគ្រួសារ ទាំងអស់ដែលត្រូវបានទទួលស្គាល់ដោយសាលាក្រុង និងក្រុមហ៊ុន 7NG ថាជាម្ចាស់ដីនៅតំបន់ដីក្រហមនោះ បានទទួលផ្ទះល្វែងនៅសហគមន៍ដំណាក់ត្រយឹង ។ អាជ្ញាធរសាលាក្រុង និង ក្រុមហ៊ុន 7NG បានដេញអតីតអ្នកជួលដីនៅតំបន់ដីក្រហមទៅកាន់ដីឡូត៍ទទេ ដែលគ្មានហេដ្ឋារចនាសម្ព័ន្ធ មូលដ្ឋាននៅក្នុងខេត្តកណ្តាលដែលនៅជិតខាងនោះ ។ ទោះបីជារដ្ឋាភិបាលអះអាងថាទីតាំងដីក្រហម ត្រូវតែ សម្អាតចេញជាបន្ទាន់ ដើម្បីបើកផ្លូវសម្រាប់ការអភិវឌ្ឍក៏ដោយ ក៏ទីតាំងនោះនៅតែបន្តនៅទំនេរដដែលរហូត មកដល់ដំណាច់ឆ្នាំនេះ ។

នៅខែមិថុនា អាជ្ញាធរសាលាក្រុងភ្នំពេញបានបណ្តេញគ្រួសាររងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ជាង ៤០ គ្រួសារពីសហគមន៍បុរីកីឡាក្រុងភ្នំពេញទៅកាន់តំបន់តាំងទីលំនៅថ្មី ដែលមានចម្ងាយប្រមាណជា ១៥ម៉ៃល៍ពីទីក្រុង ទោះបីជាគ្រួសារមួយចំនួនមានសិទ្ធិតាំងទីលំនៅជាថ្មីនៅក្នុងបុរីកីឡាតាមផែនការដីសម្បទានសង្គមកិច្ច ក៏ដោយ ។ ក្រុមគ្រួសារនៅតំបន់តាំងទីលំនៅជាថ្មីនៅទួលសំបូរ បានរស់នៅក្នុងជម្រកដំបូលប្រក់ស័ង្កសីពណ៌បៃតងដែលមានកំដៅក្តៅខ្លាំងនៅពេលថ្ងៃ ហើយធ្វើអោយការទុកដាក់ថ្នាំពន្យាជីវិតមានការលំបាក ។ ដូចជាតំបន់តាំងទីលំនៅជាថ្មីជាច្រើនទៀតដែរ ទួលសំបូរមិនត្រូវបានបំពាក់អោយមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ដើម្បីគាំទ្រដល់សហគមន៍ឡើយហើយទីតាំងដាច់ស្រយាល ជាឧបសគ្គដល់លទ្ធភាពទទួលបានឱកាសប្រកបរបរចិញ្ចឹមជីវិត និងតំហែទាំសុខភាព ។ រហូតមកដល់ដំណាច់ឆ្នាំនេះ កម្មវិធីរួមគ្នារវាងអង្គការមិនមែនរដ្ឋាភិបាល និង អង្គការសហប្រជាជាតិ មានផែនការកែលម្អទីលំនៅនៅទួលសំបូរ និងដើម្បីផ្តល់ការគាំទ្រដល់ជីវភាពរស់នៅដែលនៅមានកម្រិត ។

នៅខែមេសា ព្រះរាជអាជ្ញាតុលាការខេត្តរតនៈគិរី បានបដិសេធបណ្តឹងព្រហ្មទណ្ឌទាំងពីរទាក់ទងនឹងវិវាទដីធ្លីរវាងអ្នកភូមិ ជនជាតិភាគតិច និងឈ្មោះគាត កុលណើ និងជនជាតិចារ៉ាយមកពីភូមិកុង យូ និងកូធំ ។ អ្នកភូមិបានដាក់បណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងឈ្មោះ គាត កុលណើ ដោយចោទប្រកាន់ឈ្មោះ គាត កុលណើ ពីបទប្រើល្បិចអោយអ្នកទាំងនោះផ្តិតមេដៃលើឯកសារផ្ទេរដីទំហំ ១.១១២ អេឃើ នៅឃុំប៉ាត ស្រុកអូរយ៉ាដាវ ខេត្តរតនៈគិរី នៅឆ្នាំ២០០៤ ។ មេធាវីរបស់ឈ្មោះ គាត កុលណើ បានដាក់ បណ្តឹងតបវិញនៅឆ្នាំ២០០៧ ។ មកដល់ដំណាច់ឆ្នាំ

នេះ បណ្តឹងរដ្ឋប្បវេណីរបស់សហគមន៍ប្រឆាំងនឹងឈ្មោះ គាត កុលណើ នៅមិនទាន់ជំនុំជម្រះក្តីនៅឡើយទេ ។ អ្នកភូមិបានរាយការណ៍ថា មេឃុំបានគម្រាមកំហែងធ្វើការចោទប្រកាន់មិនច្បាស់លាស់ប្រឆាំងពួកគេវិញ ប្រសិនបើអ្នកទាំងនោះពុំព្រមដកពាក្យបណ្តឹងរដ្ឋប្បវេណីនោះទេ ។ នៅខែធ្នូ អ្នកភូមិបានដាក់ពាក្យបណ្តឹងទៅក្រសួងមហាផ្ទៃប្រឆាំងនឹងមេឃុំពីបទបង្ខំពួកគេអោយផ្តិតមេដៃលើឯកសារផ្ទេរដីទៅអោយឈ្មោះ គាត កុលណើ ។ មេធាវីរបស់អ្នកភូមិបានប្តឹងសុំអោយដកចៅក្រមស៊ើបសួរក្នុងរឿងក្តីនេះឈ្មោះ ធរ សារុន ដោយពុំបានចាត់ការលើសំណុំរឿងនេះ ។ តុលាការខេត្តរតនៈគិរី បានចាត់តាំងអោយចៅក្រមឈ្មោះ ធរ សារុន អោយចាត់ការសំណុំរឿងនេះ នៅខែកញ្ញា ឆ្នាំ២០០៨ ។ មានរបាយការណ៍ថាក្រុមហ៊ុន គាត កុលណើ កំពុងតែឈូសឆាយដីនៅក្នុងដែនដីមានវិវាទនោះ ទោះបីមានកិច្ចព្រមព្រៀងបញ្ឈប់ការអភិវឌ្ឍនោះ នៅអំឡុងពេលដំណើរការក្តីរបស់តុលាការក៏ដោយ ។

ជាមួយគ្នានេះដែរ នៅខែមេសា ក្នុងករណីអ្នកភូមិដែលត្រូវបណ្តេញចេញពីភូមិអន្លង់ក្អែងលេងនៅខេត្តកំពត លោកនាយករដ្ឋមន្ត្រីបានប្រកាសអោយចែកដីដែលរឹបអូសបានទៅអោយប្រជាជនប្រមាណជា៩០គ្រួសារ ។ មានអង្គការមិនមែនរដ្ឋាភិបាល បានរាយការណ៍ថាគ្មានគ្រួសារណាមួយដែលបានទទួលដីនោះ ជាអ្នកមកពីភូមិអន្លង់ក្អែងលេងឡើយ ។
នៅថ្ងៃទី២៨ ខែមេសា អាជ្ញាធរបានចាប់ខ្លួន និងដោះលែងឈ្មោះ ជា សំអាត អោយនៅក្រៅឃុំវិញ ដែលជននេះត្រូវបានចោទប្រកាន់ពីបទតាំងខ្លួនជាមេភូមិ ហើយបញ្ជាអោយទាហានបាញ់ប្រហារលើអ្នកភូមិដែលកំពុងតែតវ៉ានឹងការបណ្តេញចេញនៅស្រុកម៉ាល័យ ខេត្តបន្ទាយមានជ័យនៅខែមីនា ឆ្នាំ២០០៨ ។ មកដល់ដំណាច់ឆ្នាំ ការស៊ើបអង្កេតនៅបន្តធ្វើនៅឡើយ ។

គ្មានការវិវឌ្ឍអ្វីឡើយនៅក្នុងករណីកាលពីខែកុម្ភៈ ដែលអាជ្ញាធរត្រូវបានរាយការណ៍ថា វាយដុំអ្នកភូមិនៅអំឡុងពេលបណ្តេញចេញពីខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ពុំមានការវិវឌ្ឍនៅក្នុងករណីបណ្តេញចេញនៅខែមិថុនា ឆ្នាំ២០០៨ ដែលធ្វើឡើងដោយទាហាននៅតំបន់អន្លង់ក្រោម ខេត្តកំពតឡើយ ។

នៅករណីបណ្តេញចេញនៅខែមេសាឆ្នាំ២០០៨ របស់ក្រុមទី៧៨ នៃសហគមន៍ទន្លេបាសាក់នៅថ្ងៃទី២០ ខែមេសា សាលាក្រុងភ្នំពេញ បានចេញលិខិតជូនដំណឹងអំពីការបណ្តេញលើកទី៦ របស់ខ្លួនទៅកាន់អ្នករស់នៅក្នុងក្រុមទី៧៨ ។ បន្ទាប់មកសហគមន៍បានដាក់សំណើប្រឆាំងនឹងសេចក្តីជូនដំណឹងអំពីការបណ្តេញចេញនោះ ។ ទោះបីជាអាជ្ញាធរអះអាងថា ដីនោះជាទ្រព្យសម្បត្តិរដ្ឋក៏ដោយ ក៏រដ្ឋាភិបាលមិនបានផ្តល់ឯកសារបញ្ជាក់ថាពិតជាទ្រព្យរបស់រដ្ឋឡើយ ហើយដីនោះមិនត្រូវនឹងនិយមន័យនៃដីសាធារណៈរបស់រដ្ឋតាមច្បាប់ភូមិបាលឆ្នាំ២០០១ ឡើយ ។

នៅថ្ងៃទី១៧ ខែកក្កដា នគរបាលរាជធានីបាន បណ្តេញប្រជាជនចំនួន ៨៦គ្រួសារ ដែលពុំព្រមទទួលយកកញ្ចប់សំណងរបស់សាលាក្រុង ។

នៅថ្ងៃទី១៣ ខែកុម្ភៈ តុលាការកំពូលបានតំកល់ការសម្រេចរបស់តុលាការខេត្តសៀមរាប និងសាលាឧទ្ធរណ៍ ទាក់ទងនឹង បណ្តឹងឆ្នាំ២០០៦ របស់លោក សុន ឆ័យ សមាជិកសភាមកពីគណបក្សសម រង្ស៊ី ។ លោក សុន ឆ័យ ត្រូវបញ្ជាអោយលក់ដីរបស់គាត់ទំហំ ៧,៨អេឃឺ (acres) ទៅអោយទីភ្នាក់ងាររដ្ឋាភិបាល ដែលតាមរបាយការណ៍ ក្នុងតម្លៃមួយទាបជាតម្លៃទីផ្សារ ។ លោក សុន ឆ័យ បានស្នើសុំអោយជំនុំជម្រះក្តីជាថ្មី ដោយសារគាត់អវត្តមាន នៅអំឡុងពេលសវនការរបស់តុលាការកំពូល ប៉ុន្តែការជំនុំជម្រះក្តីជាថ្មី ពុំបានកើតមានឡើយ ។ នៅថ្ងៃទី១៨ ខែធ្នូ តុលាការខេត្តសៀមរាបបានចេញដីការបញ្ជាប់អោយ លោកសុន ឆ័យ ចាកចេញពីដីនោះ ក្នុងរយៈពេល ១៥ថ្ងៃ ចាប់ពីថ្ងៃបានទទួលដីការ ។

## ផ្នែកទី២ ៖ ការគោរពសេរីភាពពលរដ្ឋ រួមមាន

### ក. សេរីភាពបញ្ចេញមតិ និងសារព័ត៌មាន

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបញ្ចេញមតិ និងសារព័ត៌មាន ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្ត ជាក់ស្តែង សិទ្ធិទាំងនេះមិនត្រូវបានគោរពជានិច្ចកាលឡើយ ។

រដ្ឋធម្មនុញ្ញកំណត់ថាការបញ្ចេញមតិដោយសេរី មិនត្រូវប៉ះពាល់ដល់សន្តិសុខសាធារណៈឡើយ ។ រដ្ឋធម្មនុញ្ញ ក៏ប្រកាសផងដែរថា ព្រះមហាក្សត្រ “មិនអាចរំលោភបាន” ហើយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ អនុលោម តាមច្បាប់បរិហាកេរ្តិ៍បញ្ជាក់បន្ថែមអំពីដែនកំណត់ទាំងនេះ រួចហើយហាមប្រាមមិនអោយអ្នកបោះពុម្ព និងនិពន្ធ នាយកផ្សព្វផ្សាយរឿងណា ដែលប្រមាថ និងបរិហាកេរ្តិ៍ថ្នាក់ដឹកនាំ និងស្ថាប័នរដ្ឋាភិបាលឡើយ ។

ច្បាប់ស្តីពីសារព័ត៌មានឆ្នាំ១៩៩៥ ហាមប្រាមមិនអោយមានការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយ ឬទោសជាប់ ពន្ធនាគារចំពោះការសម្តែងមតិឡើយ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលនៅតែបន្តប្រើប្រាស់ច្បាប់ចាស់កាល ពីសម័យអាជ្ញាធរ អន្តរកាលរបស់អង្គការសហប្រជាជាតិ (UNTAC) នៅកម្ពុជាដើម្បីចោទប្រកាន់អ្នកសារព័ត៌ មាន និងអ្នកដទៃទៀតពីបទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិត ។ វិសោធនកម្មឆ្នាំ២០០៦ ចំពោះច្បាប់ អន្តរកាលនេះ បានលុបទោសជាប់ពន្ធនាគារចំពោះករណីបរិហារកេរ្តិ៍ ប៉ុន្តែនៅរក្សាទុកបទញុះញង់ និងផ្សព្វផ្សាយ ព័ត៌មានមិនពិតដែលត្រូវមានទោសជាប់ពន្ធនាគាររហូតដល់បីឆ្នាំ ។ នៅក្នុងករណីទាំងពីរប្រភេទនេះ ចៅក្រម អាចកាត់សេចក្តីជាការផាកពិន័យ ដែលអាចនាំទៅរកការជាប់ពន្ធនាគារ ប្រសិនមិនបង់ប្រាក់ពិន័យនោះទេ ។

នៅថ្ងៃទី២៧ ខែមេសា សមាជិកសភាគណបក្សប្រឆាំងលោកស្រី មូ សុខហួ បានដាក់ពាក្យបណ្តឹងប្រឆាំងលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ពីបទបរិហារកេរ្តិ៍ ។ លោកនាយករដ្ឋមន្ត្រីបានដាក់ពាក្យបណ្តឹងតបវិញចំពោះលោកស្រីមូ សុខហួ និងមេធាវីរបស់លោកស្រី ដោយលោកថ្លែងថាមតិដែលលោកស្រី មូ សុខហួរ លើកឡើងនៅក្នុងសន្និសីទ សារព័ត៏មាន និងកិច្ចខិតខំប្រឹងប្រែង នៅពេលបន្តបន្ទាប់របស់លោកស្រីដើម្បីទាក់ទាញការគាំទ្រពីអន្តរជាតិ គឺជា ការបរិហារកេរ្តិ៍របលោក ។ នៅថ្ងៃទី១០ ខែមិថុនា តុលាការបានបដិសេធបណ្តឹងរបស់លោកស្រី ។ នៅថ្ងៃទី២២ ខែមិថុនានៅអង្គប្រជុំបិទជិតមួយ សភាជាតិដែលស្ថិតក្រោមគ្រប់គ្រង់ដោយគណបក្សប្រជាជនកម្ពុជាបានបោះ ឆ្នោតដកអភ័យឯកសិទ្ធិសមាជិកសភារបស់លោកស្រីមូសុខហួ ដែលបើកផ្លូវអោយបណ្តឹងតបប្រឆាំងនឹងលោកស្រីមូ សុខហួ របស់លោកនាយរដ្ឋមន្ត្រីមានដំណើរការទៅមុខ ។ ជាមួយគ្នានោះដែរគណៈមេធាវីនៃព្រះរាជាណាចក្រ កម្ពុជា បានដាក់បណ្តឹងអំពីក្រុមសីលធម៌វិជ្ជាជីវៈប្រឆាំងនឹងមេធាវីរបស់លោកស្រី មូ សុខហួ ដែលរៀបចំឡើង ដោយមេធាវីរបស់លោកនាយករដ្ឋមន្ត្រីចំពោះមូលហេតុបរិហារកេរ្តិ៍ដូចគ្នានេះ ។ ស្ថិតក្រោមសម្ពាធបណ្តឹងក្រុម សីលធម៌វិជ្ជាជីវៈ  មេធាវីរបស់លោកស្រីមូ សុខហួ បានទទួលកំហុស និងសុំទោសលោកនាយករដ្ឋមន្ត្រី ហើយបាន លាឈប់ជាមេធាវីរបស់លោកស្រីមូ សុខហួ រួចចូលរួមជាមួយគណបក្សប្រជាជនកម្ពុជាវិញ ។ តុលាការបាន ប្រើប្រាស់ការសារភាពរបស់មេធាវីរូបនេះជាភស្តុតាងប្រឆាំងនឹងលោកស្រីមូ សុខហួ នៅក្នុងការជំនុំជម្រះក្តីរបស់ លោកស្រីមូ សុខហួ នៅថ្ងៃទី២៤ ខែកក្កដា ហើយនៅថ្ងៃទី០៤ ខែសីហា តុលាការរកឃើញថាលោកស្រីមូ សុខហួត្រូវមានទោសពីបទបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ប៉ុន្តែបានបដិសេធបណ្តឹងប្រឆាំងនឹងមេធាវីរបស់ លោកស្រីនៅក្នុងសាលក្រមតែមួយ ខណៈពេលដែលគណៈមេធាវីផ្អាកការស៊ើបអង្កេតរបស់ខ្លួនអំពីបណ្តឹងក្រុម សីលធម៌វិជ្ជាជីវៈដោយពុំបានឈានដល់ការសម្រេចចិត្តអ្វីទាំងអស់។ លោកស្រី មូ សុខហួ បានប្តឹងឧទ្ធរណ៍ចំពោះការបដិសេធបណ្តឹងដើមរបស់លោកស្រី និងការកាត់ទោសលោកស្រី ។ នៅថ្ងៃទី១៤ ខែតុលា សាលាឧទ្ធរណ៍ តំកល់ការសម្រេចរបស់តុលាការរាជធានី ដែលបដិសេធបណ្តឹងរបស់លោកស្រីប្រឆាំង នឹងលោកនាយករដ្ឋមន្ត្រី ហើយលោកស្រីមូ សុខហួក៏មិនបានបន្តរឿងក្តីនេះទៀតឡើយ ។ នៅថ្ងៃទី២៨ ខែតុលា សាលាឧទ្ធរណ៍ក៏បាន បដិសេធបណ្តឹងរបស់លោកស្រីអំពីការទទួលខុសត្រូវនៅថ្ងៃទី៤ ខែសីហាចំពោះករណីបរិហារកេរ្តិ៍ ។ ក្រោយមក ទៀត លោកស្រីមូ សុខហួ បានប្តឹងឧទ្ធរណ៍អំពីការសម្រេចនោះទៅកាន់តុលាការកំពូលមកដល់ដំណាច់ឆ្នាំពុំមាន ការកំណត់ពេលវេលាច្បាស់លាស់សម្រាប់ជំនុំជម្រះក្តីនោះឡើយ ។

អាជ្ញាធររដ្ឋាភិបាលបានដាក់បណ្តឹងស្រដៀងៗនេះប្រឆាំងនឹងអ្នករិះគន់ ។ នៅថ្ងៃទី១១ ខែឧសភា លោកឧបនាយក រដ្ឋមន្ត្រី សុខ អាន បានដាក់ពាក្យបណ្តឹងបរិហារកេ្តរិ៍ប្រឆាំងនឹងនាយកសារព័ត៏មានគាំទ្រគណបក្សប្រឆាំង ខ្មែរម្ចាស់ស្រុក លោក ហង្ស ចក្រា ចំពោះអត្ថបទរបស់លោក ដែលចោទប្រកាន់អំពីអំពើពុករលួយក្នុងចំណោម ទីប្រឹក្សា និងបុគ្គលិករបស់លោកឧបនាយករដ្ឋមន្ត្រី ។ នៅថ្ងៃទី២៦ ខែមិថុនា តុលាការរាជធានីភ្នំពេញបានកាត់ ទោសលោកហង្ស ចក្រា ដោយកំបាំងមុខដាក់ពន្ធនាគាររយៈពេលមួយឆ្នាំរួមជាមួយនឹងការផាកពិន័យយ៉ាងច្រើន ។ លោកហង្ស ចក្រា ត្រូវចាប់ខ្លួននៅថ្ងៃដដែលនោះនៅខេត្តបាត់ដំបង រួចហើយត្រូវជាប់

នៅក្នុងពន្ធនាគារ ។ នៅថ្ងៃទី១១ ខែសីហា តុលាការកំពូលមានតំកល់សាលក្រមរបស់ តុលាការរាជធានី លោក ហង្ស ចក្រា មិនបាន ប្តឹងឧទ្ធរណ៍ទៅតុលាការកំពូលទេ ហើយសាលក្រមនោះក៏ចូលជាធរមាន ។ នៅខែកញ្ញា លោកហង្ស ចក្រា បាន ផ្ញើលិខិតសុំទោសលោកឧបនាយករដ្ឋមន្ត្រីសុំអោយដោះលែងខ្លួនដោយសារបញ្ហាសុខភាព ដែលបណ្តាលមកពីការ ជាប់ពន្ធនាគារនោះ ប៉ុន្តែមកដល់ដំណាច់ឆ្នាំលោកពុំបានទទួលការឆ្លើយតបឡើយ ។

នៅក្នុងរយៈពេលជាងបួនថ្ងៃ នៅខែមិថុនា អាជ្ញាធររាជធានីភ្នំពេញ បានចាប់ខ្លួន ចោទប្រកាន់ កាត់ទោស និងផាកពិន័យ លោក សួង សោភ័ណ្ឌ ដែលជាអ្នករស់នៅសហគមន៍បឹងកក់ពីបទបរិហារកេរ្តិ៍រដ្ឋាភិបាល ។ លោក សួង សោភ័ណ្ឌ ដែលជា សមាជិកផ្នែកយុវជនគណបក្សសមរង្ស៊ីបានបាញ់ថ្នាំលើជញ្ជាំងផ្ទះរបស់គាត់តវ៉ានឹងការ បណ្តេញសហគមន៍នៅជុំវិញបឹងកក់យ៉ាងកម្រោលដើម្បីបើកផ្លូវអោយគម្រោងអភិវឌ្ឍរបស់លោក ឡៅ ម៉េងឃិន ជាសមាជិកព្រឹទ្ធសភារបស់គណបក្សប្រជាជនកម្ពុជា ។ នៅថ្ងៃទី០៧ ខែកក្កដា លោកដាំ សិទ្ធិ និពន្ធនាយក សារព័ត៌មាន មនសិការខ្មែរ បានទទួលដីកាកោះហៅអោយចូលខ្លួនមកបំភ្លឺចំពោះការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងញុះញង់ ។ ការចោទប្រកាន់នោះ ទាក់ទងនឹងខ្លឹមសារ អត្ថបទមួយចំនួនដែលបានបោះពុម្ព ផ្សាយរវាងខែកុម្ភៈនិងខែឧសភា ។ លោកដាំ សិទ្ធិ ដែល ធ្លាប់ជាប់ឃុំបណ្តោះអាសន្នកាលពីខែមិថុនា ឆ្នាំ២០០៨ ទាក់ទងនឹងការចោទប្រកាន់ស្រដៀងគ្នានេះដែរនោះបាន សុំទោសលោកនាយករដ្ឋមន្ត្រីជាលាយលក្ខណ៍អក្សរ ព្រមទាំងសន្យាបញ្ឈប់ការបោះពុម្ពផ្សាយសារព័ត៌មាន ។ បណ្តឹងនោះត្រូវបដិសេធ ហើយសារព័ត៌មានបានបញ្ឈប់ ការបោះពុម្ពផ្សាយភ្លាមៗ ហើយនៅបន្តបិទរហូតដល់ដំណាច់ឆ្នាំ ។

នៅដើមខែធ្នូ តុលាការខេត្តស្វាយរៀងបានចោទប្រកាន់មេដឹកនាំគណបក្សប្រឆាំង សម រង្ស៊ី ពីបទ បំផ្លិចបំផ្លាញ ទ្រព្យសម្បត្តិសាធារណៈ និងញុះញង់អោយមានការស្អប់ខ្ពើមពូជសាសន៍/ជាតិសាសន៍ពាក់ព័ន្ធនឹង ឧប្បត្តិហេតុនៅ ថ្ងៃទី២៥ ខែតុលា ដែលក្នុងនោះមានអ្នកភូមិមួយក្រុមបានដកបង្គោលតម្រុយព្រំដែនជាមួយ ប្រទេសវៀតណាម ។ សភាជាតិបានបោះឆ្នោតដកអភ័យឯកសិទ្ធិលោកសម រង្ស៊ី នៅថ្ងៃទី១៦ ខែវិច្ឆិកា ហើយ តុលាការបានកោះហៅ លោកសម រង្ស៊ី អោយបង្ហាញខ្លួនដើម្បីសាកសួរនៅថ្ងៃទី២៨ ខែធ្នូ លោកសម រង្ស៊ី បាន បដិសេធមិនព្រមបង្ហាញ ខ្លួនរួចហើយបានចាកចេញពីប្រទេសនៅខែវិច្ឆិកា ។

នៅខែមេសា ឆ្នាំ២០០៨ លោកហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស បានដាក់បណ្តឹងបរិហារកេរ្តិ៍ ប្រឆាំងនឹង លោកសម រង្ស៊ី នៅថ្ងៃទី២៧ ខែមករា ។ សាលាដំបូងបារាំងបានរកឃើញថាលោក សម រង្ស៊ី និងអ្នក បោះពុម្ពសៀវភៅរបស់លោកមានទោសពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត រួចហើយបញ្ជាអោយ ចុងចោទបង់ប្រាក់សំណងជានិមិត្តរូបចំនួនមួយអឺរ៉ូ (១,៤៣ដុល្លារ) ទៅអោយលោករដ្ឋមន្ត្រីការបរទេស ហោ ណាំហុង ទឹកប្រាក់ចំនួន ៥.៥៥០អឺរ៉ូទៅអោយ រដ្ឋាភិបាលបារាំងជាប្រាក់ប្រដាប់ក្តី និងចំណាយបោះពុម្ពផ្សាយ សាលក្រមនៅ ក្នុងកាសែតបារាំងពីរតាមការជ្រើសរើសរបស់ខ្លួន ។ លោកសម រង្ស៊ី បានប្តឹងឧទ្ធរណ៍ចំពោះការ

សម្រេចនោះ សវនការនៅថ្ងៃទី០៨ ខែសីហា ត្រូវបានលើកពេល និងមិនបានធ្វើការកំណត់ពេលវេលាសម្រាប់ជំនុំជម្រះជាថ្មី នៅដំណាច់ឆ្នាំឡើយ ។

គណបក្សនយោបាយសំខាន់ៗ មានមូលហេតុសមរម្យ និងទៀងទាត់ចំពោះការផ្សព្វផ្សាយព័ត៌មានដែលបានបោះពុម្ព ។ សារព័ត៌មានជាភាសាខ្មែរធំៗទាំងអស់ សុទ្ធតែបានទទួលការគាំទ្រផ្នែកថវិកាពីគណបក្សនយោបាយ ហើយជាប់ពាក់ព័ន្ធនឹងនយោបាយ ។ តាមការប៉ាន់ស្មាន មានសារព័ត៌មានជាភាសាខ្មែរប្រមាណជា ២០ ចេញ ផ្សាយជាទៀងទាត់ ។ នៅឆ្នាំកន្លងទៅ យ៉ាងហោចណាស់មានសារព័ត៌មានសំខាន់ៗបួនគាំទ្រគណបក្សប្រឆាំង ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារមួយផ្នែកមាន ជាប់ពាក់ព័ន្ធនឹងបណ្តឹងបរិហារកេរ្តិ៍ប្រឆាំងនឹងនិពន្ធនាយកសារព័ត៌មានប្រឆាំងនោះ មានតែសារព័ត៌មានប្រឆាំងបីប៉ុណ្ណោះ កំពុងតែបោះពុម្ពផ្សាយនៅដំណាច់ឆ្នាំ ។ ទោះបីជាសារព័ត៌មានដែលចរាចរច្រើនជាងគេទាំងបី ត្រូវចាត់ទុកថាជាសារព័ត៌មាន គាំទ្រគណបក្សប្រជាជនកម្ពុជា ក៏សារព័ត៌មានភាគច្រើនបំផុតរិះគន់រដ្ឋាភិបាល ជាពិសេសទាក់ទងនឹងអំពើពុករលួយ និងការដណ្តើមដីធ្លីដែរ ។ លោកនាយករដ្ឋមន្ត្រី មេដឹកនាំគណបក្សរាជានិយម និងមេដឹកនាំគណបក្សប្រឆាំង ជារឿយៗ បានទទួលរងការវាយប្រហារ ។

រដ្ឋាភិបាល កម្លាំងយោធា គណបក្សនយោបាយកាន់អំណាច បានបន្តគ្រប់ដណ្តប់លើបណ្តាញផ្សព្វផ្សាយ និងមាន ឥទ្ធិពលលើខ្លឹមសារនៃការផ្សព្វផ្សាយ ។ ស្ថានីយ៍ទូរទស្សន៍ក្នុងស្រុកមានចំនួនប្រាំបួន និងស្ថានីយ៍វិទ្យុមានចំនួនប្រមាណជា ៥០ ។ ស្ថានីយ៍ទូរទស្សន៍ និងស្ថានីយ៍វិទ្យុទាំងអស់ ត្រូវគ្រប់គ្រង ឬទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីគណបក្សប្រជាជនកម្ពុជា ទោះជាយ៉ាងណាក៏ដោយក៏មានវិទ្យុមួយចំនួនតូចឯករាជ្យឬពាក់ព័ន្ធជាមួយនឹងគណបក្សដទៃទៀតដែរ ។ នៅខែមិថុនា ក្រសួងមហាផ្ទៃបានផ្តល់ អាជ្ញាប័ណ្ណបើកស្ថានីយ៍វិទ្យុទៅអោយលោក សយ សុភាព ជាម្ចាស់សារព័ត៌មានដើមអំពិលដែលគាំទ្រគណបក្សប្រជាជនកម្ពុជាចេញផ្សាយប្រចាំថ្ងៃ ប៉ុន្តែបានបដិសេធសំណើ ស្រដៀងគ្នាចំពោះស្ថានីយ៍វិទ្យុដែលមិនជាប់ពាក់ព័ន្ធនឹងនយោបាយ ឬប្រតិបត្តិការដោយគណបក្សប្រឆាំង ។

អ្នកសារព័ត៌មាន អ្នកបោះពុម្ពផ្សាយ និងអ្នកចែកចាយ ក៏ត្រូវស្ថិតក្រោមការបៀតបៀន និងការបំភិតបំភ័យជា ទម្រង់ផ្សេងទៀតដែរ ដែលរួមមានដូចជាការគម្រាមកំហែងដោយការបាញ់កាំភ្លើងជាដើម ហើយអ្នករាយការណ៍ ព័ត៌មាន និងអ្នកនិពន្ធ បានសារភាពពីការកាត់បន្ថយខ្លឹមសាររិះគន់មួយចំនួន ដោយសារភ័យខ្លាចការវាយបកពីរដ្ឋាភិបាល ។

នៅខែមករា មន្ត្រីកងរាជអាវុធហត្ថម្នាក់ដែលមិនស្គាល់ឈ្មោះ តាមការចោទប្រកាន់ បានបាញ់កាំភ្លើងបីគ្រាប់លើក្បាលអ្នកសារព័ត៌មានក្នុងស្រុកម្នាក់ឈ្មោះ លីម លីហ៊ាង ដែលបានសរសេររឿងនាំឈើខុសច្បាប់ ដែលកំពុងតែ ដឹកជញ្ជូនទៅកាន់ក្រុងភ្នំពេញ ។ ជាមួយគ្នានេះដែរ នៅខែមករា អ្នកសារព័ត៌មានបរទេសម្នាក់បានរងការ

វាយដំ ដោយមន្ត្រីនគរបាលនៅក្រៅម៉ោងធ្វើការដែលធ្វើការជាឆ្មាំសន្តិសុខនៅក្រៅការិយាល័យក្រុមហ៊ុនសំណង់ 7NG នៅក្រុងភ្នំពេញ ។

ស្ថានីយ៍ទូរទស្សន៍ និងស្ថានីយ៍វិទ្យុដែលគ្រប់គ្រងដោយរដ្ឋាភិបាល បានផ្សាយផ្ទាល់នូវការជំនុំជម្រះដំបូងរបស់សាលាក្តីខ្មែរក្រហម (សូមមើលផ្នែក ១.ង) និងកិច្ចប្រជុំសភាជាតិដែលបានថតសម្លេងទុក ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីជាក់ស្តែងមួយចំនួនការផ្សាយអំពីកិច្ចប្រជុំរបស់រដ្ឋសភាជាតិ មានការកែសម្រួលយ៉ាងច្រើន ។ ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ជាតិ មានផ្សាយពីសិទ្ធិមនុស្សខ្លះ សកម្មភាពសង្គម សុខភាពសាធារណៈ ការអប់រំ និងកម្មវិធីសង្គមស៊ីវិល ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក ។

## សេរីភាពអ៊ីនធើណែត

មានរបាយការណ៍មួយចំនួននិយាយអំពីការរឹតត្បិតរបស់រដ្ឋាភិបាលចំពោះលទ្ធភាពប្រើប្រាស់អ៊ីនធើណែត ។ នៅខែ មីនា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានហាមប្រាមចំពោះវ៉ែបសាយត៍មួយចំនួន ដែលត្រូវក្រសួងកិច្ចការ នារី (MOWA) ចាត់ទុកថាមានដែលមានខ្លឹមសារ “ប្រមាថមើលងាយ” ។ វ៉ែបសាយត៍មួយចំនួនមានផ្សាយរូបស្ត្រីខ្មែរក្រហមអាក្រាតពាក់កណ្តាលខ្លួន ហើយវ៉ែបសាយត៍មួយចំនួនផ្សេងទៀតមានលក្ខណៈទំនើបតំណាងអោយ អ្នករបាំខ្មែរបុរាណដែលស្លៀកពាក់ដូចរូបអ្នករបាំដែលឆ្លាក់នៅលើជញ្ជាំងប្រាសាទអង្គរវត្ត ។ វិចិត្រករនៅតែ អះអាងថាស្នាដៃនោះ មានលក្ខណៈសិល្បៈមិនមែនជារូបភាពអាសគ្រាមទេ ។ ពុំមានរបាយការណ៍ដែលថា រដ្ឋាភិបាលបានពិនិត្យតាមដានអ៊ីមែល ឬបន្ទប់ជជែកកំសាន្តតាម អ៊ីនធើណែតនោះឡើយ ។ បុគ្គល និងក្រុមនានា អាចចូលរួមនៅក្នុងការសម្តែងទស្សនៈដោយសន្តិវិធីតាមរយៈអ៊ីនធើណែត រួមមានដូចជាតាមរយៈអ៊ីមែលជាដើម ។

យោងតាមការអង្កេតឧស្សាហកម្មនៅពេលថ្មីៗបំផុតនោះបង្ហាញអោយឃើញថា ០,៥ភាគរយនៃប្រជាជនសរុបបាន ជាវសេវាអ៊ីនធើណែតភាគច្រើនបំផុតនៅភ្នំពេញនិងសៀមរាប ។ នៅតំបន់ទីក្រុង លទ្ធភាពប្រើប្រាស់អ៊ីនធើណែត មានភាពទូលំទូលាយតាមរយៈហាងអ៊ីនធើណែតនានា ។

## សេរីភាពសិក្សាអប់រំ និងព្រឹត្តិការណ៍វប្បធម៌

ជាទូទៅ ពុំមានឧបសគ្គផ្នែកច្បាប់ចំពោះសេរីភាពសិក្សាអប់រំឡើយ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកសិក្សាទំនងជាមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយ ដោយសារភ័យខ្លាចប៉ះពាល់អ្នកនយោបាយ ។

នៅខែកុម្ភៈ ក្រសួងអប់រំ បានដកលោក ស៊ុន ធន់ ពីតំណែងរបស់លោកជាគ្រូបង្រៀនពលរដ្ឋវិជ្ជានៅវិទ្យាល័យទ្រាល ខេត្តកំពង់ធំ ចំពោះការរិះគន់នាយករដ្ឋមន្ត្រីនៅចំពោះមុខសិស្ស ។ លោក ស៊ុន ធន់ បានថ្លែងថាលោកកំពុងតែ បង្រៀនមេរៀនតាមសៀវភៅអំពីការប្រឆាំងនឹងអំពើពុករលួយ និងលទ្ធិប្រជាធិបតេយ្យ ដែលជាផ្នែកមួយនៃ កម្មវិធីសិក្សាដែលបានអនុម័តរួចហើយ ។ អង្គការមិនមែនរដ្ឋាភិបាល មួយចំនួនបានចោទប្រកាន់ថាការសម្រេច នោះមានហេតុផលនយោបាយពីព្រោះនាយករងសាលានិងមន្ត្រីអប់រំខេត្ត គឺជាសមាជិកគណបក្សប្រជាជនកម្ពុជា ចំណែកឯលោក ស៊ុន ធន់ គឺជាប្រធានប្រចាំខេត្តរបស់សមាគមគ្រូបង្រៀនកម្ពុជា និងជាសមាជិកគណបក្សប្រឆាំង សមរង្ស៊ី ។ ក្រសួងបានផ្តល់តំណែងបង្រៀនដល់លោកស៊ុន ធន់ នៅសាលារៀនផ្សេងដែលមានចម្ងាយរាប់ម៉ៃល៍ ។ នៅខែឧសភា លោក ស៊ុន បានជាប់ឆ្នោតជាក្រុមប្រឹក្សាខេត្ត ហើយបានព្យួរការងារបង្រៀនរបស់លោកដើម្បី បំពេញមុខងារនៅក្នុងក្រុមប្រឹក្សាខេត្ត ។

នៅថ្ងៃទី១០ ខែមីនា លោក ទៀង ណារិទ្ធ ត្រូវបានដោះលែងពីពន្ធនាគារ ក្រោយពីបានបម្រើទោសពេញអាណត្តិរយៈពេល២ឆ្នាំ និង៦ខែ ចំពោះការបង្រៀនអត្ថបទបោះពុម្ពខ្លួនឯងមានខ្លឹមសារប្រឆាំងនឹងរដ្ឋាភិបាល ។

ផ្ទុយពីឆ្នាំកន្លងទៅ រដ្ឋាភិបាលបានរឹតត្បិតព្រឹត្តិការណ៍វប្បធម៌មួយចំនួន ។ នៅថ្ងៃទី១២ ខែមករា គណៈរដ្ឋមន្ត្រីបានហាមការផ្សាយល្ខោនអូប៉េរ៉ាមានចំណងជើងថា “ទីដំរីយំ” ដែលជាល្ខោនរ៉ុក និទានឡើងវិញនូវដំណើររឿងខ្មែរបុរាណដែលនិយាយអំពីជំនាន់ក្រោយខ្មែរក្រហមដែលសម្តេចព្រះសង្ឃរាជអះអាងថាបានប្រមាថព្រះពុទ្ធសាសនា សិល្បករបានយល់ព្រមកែសម្រួលផលិតកម្ម ហើយក្រោយពីការផ្សាយ បានផ្ញើលិខិតមួយច្បាប់ទៅសុំទោសសម្តេច ព្រះសង្ឃរាជ គណៈរដ្ឋមន្ត្រីក៏អនុញ្ញាតអោយផ្សាយផលិតកម្មនោះ ។ នៅខែកុម្ភៈ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានស្នើថានៅពេលអនាគត ស្នាដៃសិល្បៈបង្ហាញអំពីព្រះពុទ្ធសាសនា គួរសុំការអនុញ្ញាតពីក្រសួងធម្មការ និងសាសនាមុននឹងផ្សព្វផ្សាយជាសាធារណៈ ។

នៅថ្ងៃទី០២ ខែសីហា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានហាមឃាត់អ្នករៀបចំជនជាតិណ័រវេស មិនអោយរៀបចំការប្រឡងបវរកញ្ញា ពិការអវៈយវៈដោយសារគ្រាប់មីនឡើយ ។ ក្រសួងបានថ្លែងថាការប្រឡងនេះ “អាចជាការចំអកចំពោះជនរងគ្រោះដោយសារគ្រាប់មីនកម្ពុជា” ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយហៅថាអង្គការជនពិការកម្ពុជា ក៏ដកការគាំទ្ររបស់ខ្លួនចំពោះ ការប្រឡងនោះដែរ ក្រោយពីបាន ទទួល “ដំបូន្មាន” ពីលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ នៅពេលអ្នករៀបចំពិធីដ៏អធឹកអធមនោះ មានបំណងបន្តពិធីដ៏អធឹកអធមនោះនៅបរទេស រដ្ឋាភិបាលបានហាមឃាត់អ្នកចូលរួមទាំង ២០នាក់ មិនអោយចាកចេញពីប្រទេស ។ ពិធីនោះ ត្រូវបានរៀបចំឡើងនៅក្រៅប្រទេសនៅប្រទេសណ័រវេសដោយប្រើប្រាស់រូបថតរបស់បេក្ខជន ។ អ្នករៀបចំពិធីបានមកកាន់ប្រទេសកម្ពុជានៅខែធ្នូ ដើម្បីផ្តល់រង្វាន់ដល់បេក្ខជន ។

## ខ. សេរីភាពជួបជុំ និងបង្កើតអង្គការ/សមាគម

### សេរីភាពជួបប្រជុំ

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពជួបប្រជុំដោយសន្តិវិធី ប៉ុន្តែមានពេលវេលាជាច្រើន ដែលរដ្ឋាភិបាលមិនបាន គោរពសិទ្ធិនេះទេនៅក្នុងការអនុវត្តជាក់ស្តែង ។ រដ្ឋាភិបាលតម្រូវអោយសុំការអនុញ្ញាតជាមុន មុននឹងធ្វើការ ដង្ហែរក្បួន ឬបាតុកម្ម ។ ជាទម្លាប់ រដ្ឋាភិបាល មិនបានផ្តល់ការអនុញ្ញាតដល់ក្រុមដែលរិះគន់គណបក្សកាន់អំណាច ឬប្រទេសដែលរដ្ឋាភិបាលមានទំនាក់ទំនងជាមិត្តឡើយ ។ អាជ្ញាធរតែងតែលើកអំពីភាពចាំបាច់នៃស្ថិរភាព និង សន្តិសុខសាធារណៈសម្រាប់បដិសេធការអនុញ្ញាត ។

នៅខែមិថុនា អាជ្ញាធររាជធានីភ្នំពេញ បានបដិសេធសំណើពីររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ដើម្បីធ្វើវេទិកាសាធារណៈនៅកន្លែងនិយាយអំពីសិទ្ធិមនុស្ស និងការអភិវឌ្ឍ សម្រាប់ប្រជាជនរស់នៅសហគមន៍ បឹងកក់នៅភ្នំពេញ ដែលប្រឈមមុខនឹងការបណ្តេញចេញដើម្បីបើកផ្លូវសម្រាប់គម្រោងអភិវឌ្ឍន៍មួយ ។ សាលា ក្រុងបានអះអាងថាវេទិកាសាធារណៈនោះ អាចធ្វើអោយប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ ។ CCHR បាន រាយការណ៍ថាអាជ្ញាធរដែនដីបានគម្រាមកំហែងម្ចាស់ផ្ទះសំណាក់ដែលយល់ព្រមទទួលរៀបចំវេទិកានោះ ដោយ គម្រាមកំហែងម្ចាស់ផ្ទះសំណាក់ថានឹងបិទផ្ទះសំណាក់នោះ ប្រសិនបើការប្រជុំនោះបន្តដំណើរការទៅមុខ ។ CCHR មិនបានព្យាយាមរៀបចំវេទិកានោះនៅទីសាធារណៈដទៃទៀតទេ ។

នគរបាលបានប្រើកម្លាំងបំបែកក្រុមដែលបានជួបជុំគ្នាដោយគ្មានការអនុញ្ញាត ក្នុងករណីជាក់ស្តែងមួយចំនួនបង្ក អោយមានរបួសស្រាលចំពោះបាតុករមួយចំនួន ។

នៅថ្ងៃទី០៤ ខែសីហា នគរបាលបានព្យាយាមបំបែកការតវ៉ាដែលមិនបានត្រៀមទុកជាមុនរបស់អ្នកគាំទ្រ គណបក្ស ប្រឆាំងក្រោយពីការកាត់ក្តីលោកស្រី មូ សុខហួ ពីបទបរិហារកេរ្តិ៍ (សូមមើលផ្នែកទី ២.ក) ។ នៅតាមចំណុច ផ្សេងៗតាមបណ្តោយដងផ្លូវ នគរបាលបានប៉ះទង្គិចជាមួយអ្នកដើរជាក្បួន នាំអោយមាន របួសស្រាលចំពោះអ្នក តវ៉ាមួយចំនួន ។ បុរសពីរនាក់ ក៏ត្រូវចាប់ខ្លួនផងដែរ ទោះបីជានគរភបាលបានដោះ លែងពួកគេវិញរយៈពេលពីរបី ម៉ោងក្រោយមកដោយគ្មានការចោទប្រកាន់អ្វីក៏ដោយ ។

នៅអំឡុងឆ្នាំនេះ អង្គការ ADHOC បានរាយការណ៍ថាមានបាតុកម្មតវ៉ាចំនួន ១៥៨ ដែលក្នុងចំណោមពួកគេ ភាគច្រើនបំផុតទាក់ទងនឹងវិវាទដីធ្លី និងវិវាទការងារ ។

ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅខែតុលា និងអនុម័តដោយព្រឹទ្ធសភានៅ ថ្ងៃទី១៧ ខែវិច្ឆិកា ហើយត្រូវបានឡាយព្រហស្តលេខាជាច្បាប់ដោយព្រះមហាក្សត្រនៅថ្ងៃទី០៥ ខែធ្នូ ។ ពួកអ្នក រិះគន់បានមើលឃើញកំហុសឆ្គងជាច្រើននៅក្នុងច្បាប់នេះ ដូចជាបទប្បញ្ញត្តិដែលតម្រូវអោយជូនដំណឹងរយៈពេល

៥ថ្ងៃមុនសម្រាប់បាតុកម្មដោយសន្តិវិធី និងបទប្បញ្ញត្តិមួយទៀត តម្រូវអោយជូនដំណឹងរយៈពេល ១២ម៉ោងមុន នឹងចូលរួមប្រមូលផ្តុំដែលមិនបានត្រៀមទុកជាមុន នៅលើទីកន្លែងឯកជន ឬកន្លែងតវ៉ាដោយសន្តិវិធីនៅតាមខេត្ត នីមួយៗ ហើយកម្រិតអោយការប្រមូលផ្តុំនោះ មានអ្នកចូលរួមត្រឹម២០០ នាក់ ។ នៅតែមានក្រឹត្យដើម្បីបញ្ជាក់ អំពី ទស្សនាទានសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ដែលអាចត្រូវប្រើប្រាស់ដោយអាជ្ញាធរដើម្បីអនុញ្ញាត ឬទប់ស្កាត់មិនអោយមានបាតុកម្ម ។ ការដង្ហែរក្បួនតាមដងវិថី និងការជួបជុំដើម្បីគាំទ្រទិវាសិទ្ធិមនុស្សថ្ងៃទី១០ ខែធ្នូ បានបង្ហាញអោយឃើញថា ច្បាប់នេះអាចគាំទ្របាតុកម្មជាសាធារណៈ ។

## សេរីភាពបង្កើតអង្គការ សមាគម

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបង្កើតអង្គការ/សមាគម ហើយរដ្ឋាភិបាលជាទូទៅ បានគោរពសិទ្ធិនេះ នៅក្នុង ការអនុវត្តជាក់ស្តែង ទោះបីជារដ្ឋាភិបាលមិនអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបប្បញ្ញត្តិស្តីពីសេរីភាពបង្កើត អង្គការ/សមគមនៅក្នុងច្បាប់ការងារក៏ដោយ ។

សមាជិកភាពក្រុមខ្មែរក្រហម ដែលបានដឹកនាំប្រទេសពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយដែលបន្ទាប់ពីការដួលរលំ នៃរបបនេះ បានធ្វើការបះបោរប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាល មានលក្ខណៈខុសច្បាប់ ចំណែកឯសមាជិក ភាព ក្រុមនេះនៅក្នុងក្រុមប្រដាប់អាវុធក៏ខុសច្បាប់ដែរ ។

## គ. សេរីភាពសាសនា

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពសាសនា ហើយក្នុងការអនុវត្តជាក់ស្តែងជាទូទៅរដ្ឋាភិបាលបានគោរព សិទ្ធិនេះ ។ រដ្ឋធម្មនុញ្ញក៏ហាមប្រាមផងដែរ ដល់ការរើសអើងផ្នែកសាសនា ហើយចំណែកឯសាសនាភាគតិច ទទួលរងការ រើសអើងបន្តិចបន្តួចប៉ុណ្ណោះ ឬជាផ្លូវការគ្មានការរើសអើងឡើយ ។ ព្រះពុទ្ធសាសនាជាសាសនា របស់រដ្ឋ ហើយប្រជាជនជាង ៩៣ភាគរយ ជាពុទ្ធសាសនិកជន ។ ជាតិពន្ធអ៊ីស្លាមភាគតិច គឺជាផ្នែកដ៏សំខាន់នៃ ចំនួនប្រជាជាជនដែលនៅសល់ ។

ច្បាប់តម្រូវអោយក្រុមសាសនាទាំងអស់ រួមទាំងពុទ្ធសាសនិកជនផងដែរ សុំការអនុញ្ញាតពីក្រសួង ធម្មការ និងសាសនា ដើម្បីសាងសង់កន្លែងគោរពបូជា និងធ្វើសកម្មភាពសាសនា ។ ទោះជាយ៉ាងណាក៏ដោយ ពុំមានទណ្ឌកម្មសម្រាប់ការខកខានមិនបាន ចុះបញ្ជីឡើយ ។ នៅឆ្នាំ២០០៧ សេចក្តីបង្គាប់របស់ក្រសួងធម្មការ និងកិច្ចការសាសនា បញ្ជាក់ជាថ្មីអំពីបទបញ្ជាឆ្នាំ២០០៣ ដែលហាមប្រាមការផ្សព្វផ្សាយសាសនាជាសាធារណៈ នោះនៅតែបន្តអនុវត្តយ៉ាងធូររលុង ។

## ការរំលោភបំពាន និងការរើសអើងក្នុងសង្គម

សាសនាភាគតិចទទួលរងការរើសអើងក្នុងសង្គមបន្តិចបន្តួច ឬគ្មានការរើសអើងឡើយ ។ គ្មាននរណាដឹងថាមានសហគមន៍ ជនជាតិយូដា នៅក្នុងប្រទេសនេះ ឬយ៉ាងណានោះទេ ហើយក៏គ្មានរបាយការណ៍អំពីច្បាប់ប្រឆាំងនឹងសាសនាយូដាដែរ ។

សម្រាប់ការពិភាក្សាលម្អិតបន្ថែម សូមមើល របាយការណ៍ប្រចាំឆ្នាំអំពីសេរីភាពសាសនាអន្តរជាតិ នៅ www.state.gov/g/drl/rls/irf/ .

## ឃ. សេរីភាពដើរហើរ និរន្តរជនផ្ទៃក្នុង ការការពារជនភៀសខ្លួន និងជនគ្មានប្រទេស

ច្បាប់មានចែងអំពីសេរីភាពដើរហើរនៅក្នុងប្រទេស ការធ្វើដំណើរនៅបរទេស និរប្រវេសន៍ និងមាតុភូមិនិវត្តន៍ ហើយជាទូទៅ ក្នុងការអនុវត្តជាក់ស្ដែង រដ្ឋាភិបាលបានគោរពសិទ្ធិទាំងនេះ ។ នៅក្នុងការអនុវត្តជាក់ស្ដែងជាទូទៅរដ្ឋាភិបាល មិនផ្ដល់ កិច្ចការពារ ឬជំនួយដល់និរដ្ឋានជនផ្ទៃក្នុង ជនភៀសខ្លួន ជនភៀសខ្លួនមាតុភូមិនិវត្តន៍ អ្នកស្វែងរកសិទ្ធិជ្រកកោន ជនគ្មានប្រទេស ឬបុគ្គលដែលបង្កក្ដីបារម្ភដទៃទៀតឡើយ ប៉ុន្តែជាទូទៅរដ្ឋាភិបាលអនុញ្ញាតអោយអង្គការមនុស្សធម៌ផ្ដល់កិច្ចការពារ និងជំនួយដូចពោលមកនេះ ។ រដ្ឋាភិបាលបានសហការជាមួយការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ដើម្បីផ្ដល់កិច្ចការ និងជំនួយដល់អ្នកស្វែងរកសិទ្ធិជ្រកកោនរបស់ជនជាតិម៉ុងតាញ៉ា ។ រដ្ឋធម្មនុញ្ញហាមឃាត់ចំពោះការនិរទេសដោយបង្ខំ ហើយរដ្ឋាភិបាលមិនបានប្រើប្រាស់មធ្យោបាយនេះឡើយ ។

## ការការពារជនភៀសខ្លួន

ប្រទេសកម្ពុជាជាភាគីមួយនៃអនុសញ្ញាឆ្នាំ១៩៥១ ទាក់ទងនឹងឋានៈជនភៀសខ្លួន និងពិធីសារឆ្នាំ១៩៦៧ នៃអនុសញ្ញានេះ ។ ច្បាប់ប្រទេសកម្ពុជា មានចែងអំពីការផ្ដល់សិទ្ធិជ្រកកោន និងឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាលបានរៀបចំ ប្រព័ន្ធមួយសម្រាប់ផ្ដល់កិច្ចការពារដល់ជនភៀសខ្លួន ។ នៅថ្ងៃទី១៧ ខែធ្នូ រដ្ឋាភិបាលបានចេញអនុក្រឹត្យមួយ ដោយផ្ដល់ធរមានភាពដល់ការទទួលខុសត្រូវទាំងស្រុងរបស់ខ្លួនចំពោះដំណើរការកំណត់ឋានៈជាជនភៀសខ្លួន ដោយត្រួតពិនិត្យជាចុងក្រោយលើដំណើរ ការដែលគ្រប់គ្រងរួមគ្នាជាមួយអង្គការ UNHCR ចាប់តាំងពីឆ្នាំ ២០០៨ ។ អង្គការ UNHCR បានផ្ដល់ការបណ្ដុះ បណ្ដាល និងជំនួយបច្ចេកទេសដទៃទៀត ដើម្បីសម្រួលដល់ ការផ្ទេរភារកិច្ច ហើយស្ទើរតែពេញមួយឆ្នាំនេះ អង្គការនេះ បាន ចូលរួមក្នុងការសម្ភាសន៍ និងផ្ដល់អនុសាសន៍ដល់ រដ្ឋាភិបាលអំពីករណីការសុំសិទ្ធិជ្រកកោន ។

អនុស្សរណៈនៃការយោគយល់ឆ្នាំ២០០៥ ជាមួយអង្គការ UNHCR និងរដ្ឋាភិបាលវៀតណាមដើម្បីដោះស្រាយ ស្ថានភាពជនជាតិម៉ុងតាញ៉ា ក្រោមកិច្ចការពាររបស់អង្គការ UNHCR ស្ថិតនៅជាធរមាននៅឡើយ

។ អ្នកសុំ សិទ្ធិជ្រកកោនដែលបានមកដល់ការិយាល័យអង្គការ UNHCR នៅភ្នំពេញ ត្រូវរៀបចំដំណើរការដោយមានកិច្ចសហការជាមួយរដ្ឋាភិបាល ។ នៅអំឡុងឆ្នាំនេះ ជនជាតិម៉ុងតាញ៉ាចំនួន ៩នាក់ និងអ្នកមកដល់ថ្មីដទៃទៀតបាន សុំសិទ្ធិជ្រកកោននៅក្នុងប្រទេសកម្ពុជា ។ យោងតាមអង្គការ UNHCR ជនជាតិម៉ុងតាញ៉ាចំនួន ៥០នាក់ និង ជនភៀសខ្លួន ៨នាក់ផ្សេងទៀតបានចាកចេញទៅកាន់ប្រទេសទីបី ខណៈពេលដែលអាជ្ញាធរបានបញ្ជូនអ្នកដែលត្រូវបានបដិសេធសិទ្ធិជ្រកកោនជនជាតិម៉ុងតាញ៉ាចំនួន ១១៦នាក់ទៅប្រទេសវៀតណាមវិញ ហើយជនជាតិម៉ុងតាញ៉ា ៥នាក់ទៀតបានវិលត្រឡប់ទៅប្រទេសដើមរបស់ខ្លួនវិញដោយស្ម័គ្រចិត្ត ។ ទីតាំងការពារពីរកន្លែង ក្នុងចំណោមទីតាំងទាំងបីកន្លែង បានបិទទ្វារនៅអំឡុងឆ្នាំនេះ ហើយមានជនជាតិម៉ុងតាញ៉ាចំនួន ៨៣នាក់ ទៀតស្ថិតនៅក្នុងទីតាំងការពារដែលនៅសល់នៅភ្នំពេញ ។ ទីតាំងការពារជនជាតិម៉ុងតាញ៉ា គឺជាទីតាំងដែលមាន លទ្ធភាពចេញចូលមានកម្រិត ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោនជនជាតិម៉ុងតាញ៉ា ដែលស្ថិតក្រោមកិច្ច ការពាររបស់អង្គការ UNHCR អាចចាកចេញបានលុះត្រាតែមានការអនុញ្ញាត និងការអមដំណើរដោយអង្គការ UNHCR ។ យោងតាមអង្គការ UNHCR នៅអំឡុងឆ្នាំនេះ ពុំមានជនភៀសខ្លួនណាសុំធ្វើសមាហរណកម្មក្នុងស្រុកឡើយ ។

ជាទូទៅរដ្ឋាភិបាលបានផ្តល់កិច្ចការពារប្រឆាំងនឹងការបណ្តេញចេញ និងការបញ្ជូនត្រឡប់ជនភៀសខ្លួនទៅកាន់ ប្រទេសដែលជីវិត ឬសេរីភាពរបស់ពួកគេស្ថិតក្រោមការគម្រាមកំហែងដោយសារពូជសាសន៍ សាសនា សញ្ជាតិ សមាជិកភាព នៅក្នុងក្រុម សង្គមណាមួយ ឬដោយសារទស្សនៈនយោបាយ ។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី១៩ ខែធ្នូ រដ្ឋាភិបាលបានចាប់បញ្ជូន ដោយបង្ខំនូវជនជាតិអ៊ុយហ្គ័រដែលសុំសិទ្ធិជ្រកកោនចំនួន ២០នាក់ ទៅកាន់ប្រទេសចិនវិញ ។ ជនជាតិអ៊ុយហ្គ័រម្នាក់បានមក ដល់ប្រទេសកម្ពុជាដោយស្របច្បាប់នៅខែឧសភា ចំណែកឯសមាជិកផ្សេងទៀត ត្រូវបានលួចនាំចូលមកក្នុងប្រទេសកម្ពុជា កាលពីខែតុលា និងខែវិច្ឆិកា ។ អ្នកទាំងអស់នេះ ស្នើសុំសិទ្ធិជ្រកកោន ចុះបញ្ជីជាជនគួរអោយព្រួយបារម្ភជាមួយអង្គការ UNHCR និងរដ្ឋាភិបាល ។ នៅថ្ងៃទី១៨ ខែធ្នូ នគរបាលបានចូលទៅក្នុងអគារសុវត្ថិភាពរបស់អង្គការ UNHCR ដែលឃុំខ្លួនជនជាតិអ៊ុយហ្គ័រទាំង ២០នាក់ រួចហើយដឹកជញ្ជូនទៅកាន់មជ្ឈមណ្ឌលឃុំខ្លួនរបស់សាលាក្រុងមួយ។ ក្រោយពីរយៈពេលប្រមាណជា ២៧ម៉ោង ពួកគេត្រូវដាក់នៅក្នុងយន្តហោះដួលមួយដែលធ្វើដំណើរមកពីប្រទេសចិន រួចហើយ ត្រូវបានដឹកជញ្ជូនទៅកាន់ប្រទេសចិនវិញ ។ នៅពេលដឹកជញ្ជូននោះ ជនជាតិអ៊ុយហ្គ័រទាំងអស់នោះ កំពុងរង់ចាំ ការសម្រេចអំពីការសុំសិទ្ធិជ្រកកោនរបស់ខ្លួនតាមរយៈដំណើរការកំណត់ឋានៈជាជនភៀសខ្លួនទោះបីជាយ៉ាងណា ក៏ដោយទាំងអង្គការ UNHCR និងរដ្ឋាភិបាលមិនទាន់បានផ្តួចផ្តើមអំពីដំណើរការសម្រេច រួមគ្នានោះទេនៅពេល បញ្ជូនខ្លួននោះ ។ រដ្ឋាភិបាលបានអះអាងថា ជនជាតិអ៊ុយហ្គ័រទាំងនេះ រំលោភច្បាប់អន្តោប្រវេសន៍ ហេតុដូច្នេះត្រូវ តែចាប់បញ្ជូនត្រឡប់ទៅវិញ ។ ការចាប់បញ្ជូននេះ ជួនពេលជាមួយទស្សនកិច្ចផ្លូវរដ្ឋដោយអនុប្រធានាធិបតីចិន និងកិច្ចព្រមព្រៀងផ្តល់ជំនួយទ្វេរភាគី ដែលមានទឹកប្រាក់សរុប ចំនួន ១,២ ពាន់លានដុល្លារជាជំនួយសម្រាប់ ប្រទេសកម្ពុជា ។

ក្រៅពីករណីជនជាតិម៉ុងតាញ៉ា និងជនជាតិអ៊ុយហ្គ័រ មានករណីផ្សេងទៀតដែលបានរាយការណ៍អំពីការរំលោភ បំពាន ការរឹតត្បិតសេរីភាពដើរហើរ ឬការប្រព្រឹត្តមិនគប្បីទៅលើជនភៀសខ្លួន ឬអ្នកសុំសិទ្ធិជ្រកកោនដទៃទៀត ដោយរដ្ឋាភិបាលឡើយ ។

### ជនគ្មានប្រទេស

ប្រទេសកម្ពុជាមានអ្នករស់នៅដែលជាជនគ្មានប្រទេសចំណែកឯរដ្ឋាភិបាលមិនបានអនុវត្តច្បាប់ឬគោលនយោបាយ ប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសដល់ជនទាំងនោះអោយទទួលបានសញ្ជាតិឡើយ ។ តាមច្បាប់សញ្ជាតិ ឋានៈជាពលរដ្ឋ អាចកើតមកពីកំណើតដោយសារម្តាយ និងឪពុកដែលមិនមែនជាតិពន្ធកម្ពុជា ប្រសិនបើអ្នកទាំង ពីរបានកើត និងកំពុងរស់នៅដោយស្របច្បាប់នៅកម្ពុជា ឬប្រសិនបើឪពុក ឬម្តាយបានទទួលឋានៈជាពលរដ្ឋ កម្ពុជា ។ ការសិក្សាមួយនៅឆ្នាំ២០០៧ ដោយអង្គការ UNHCR ប៉ាន់ប្រមាណថាអ្នកដែលអាចគ្មានប្រទេស ជាច្រើនពាន់នាក់បានរស់នៅក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ ការប៉ាន់ស្មាននៃការសិក្សានេះ បាន មកពីភស្តុតាងមិនអាចជឿទុកចិត្តពីអង្គការ NGO នានា ហើយតំណាងរបស់អង្គការ UNHCR នៅក្នុងស្រុក មិនបានចាត់ទុកថាតួលេខទាំងនេះមានលក្ខណៈប្រាកដប្រជាឡើយ ។

អង្គការ UNHCR បានថ្លែងថាប្រជាជនដែលអាចគ្មានប្រទេសនៅក្នុងប្រទេសកម្ពុជា រួមមានភាគច្រើនបំផុត ជាជនជាតិវៀតណាម ។ យោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភស្តុតាងបញ្ជាក់សញ្ជាតិរបស់ខ្លួនជារឿយៗគ្មានលទ្ធភាពទទួលបានការងារផ្លូវការ ការអប់រំ ការចុះសំបុត្រអាពាហ៍ពិពាហ៍ សិទ្ធិឡើងតុលាការ និងកម្មសិទ្ធិដីធ្លីឡើយ ។ ហេតុផលរួមសម្រាប់ភាពគ្មានប្រទេស គឺបណ្តាលមកពីការខ្វះខាតឯកសារត្រឹមត្រូវមកពី ប្រទេសកំណើតខ្លួន ។

## ផ្នែកទី៣ ៖ ការគោរពសិទ្ធិនយោបាយ ៖ សិទ្ធិពលរដ្ឋដើម្បីផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួន

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋដើម្បីផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួនដោយសន្តិវិធីហើយជាទូទៅប្រជាពលរដ្ឋបានប្រើប្រាស់សិទ្ធិនេះនៅក្នុងការអនុវត្តជាក់ស្តែងតាមរយៈការបោះឆ្នោតតាមពេលវេលាជាទៀងទាត់ផ្អែកតាមការបោះឆ្នោតជាសាកល ។ ការបោះឆ្នោតធ្វើឡើងដោយស្ម័គ្រចិត្តសម្រាប់ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ និងលើសពីនេះ ។

### ការបោះឆ្នោត និងការចូលរួមក្នុងជីវិតនយោបាយ

ការបោះឆ្នោតថ្នាក់ជាតិថ្មីៗបំផុត ធ្វើឡើងនៅខែកក្កដា ឆ្នាំ២០០៨ សម្រាប់សភាជាតិ ជារួមមានលក្ខណៈសន្តិភាព ដោយមានដំណើរការមួយ ដែលជាទូទៅត្រូវបានចាត់ទុកមានភាពប្រសើរជាងពេលបោះឆ្នោតកន្លងទៅ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍បានកត់សម្គាល់ថា ការបោះឆ្នោតនេះ មិនត្រូវតាមស្តង់ដារអន្តរជាតិ ពេញលេញឡើយ ។ ទោះបីជាមាន ភាពមិនប្រក្រតីមួយចំនួននៅថ្ងៃបោះឆ្នោតក៏ដោយ ក៏ភាពមិនប្រក្រតីទាំងនោះ មានចំនួនតិច ហើយមិនទំនងជាធ្វើអោយ ប៉ះពាល់ដល់លទ្ធផល ឬខុសពីឆន្ទៈរបស់អ្នកបោះឆ្នោតឡើយ ។

នៅថ្ងៃទី១៥ ខែឧសភា ប្រទេសនេះបានរៀបចំការបោះឆ្នោតអសកល ដើម្បីជ្រើសរើសអាសនៈក្រុមប្រឹក្សាខេត្ត ចំនួន ៣៧៤ និងស្រុក ២.៨៦១ ជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ជាផ្នែកមួយនៃគំនិតផ្តួចផ្តើមវិមជ្ឈការ វិសហមជ្ឈការរបស់ រដ្ឋាភិបាល ។ ការបោះឆ្នោតត្រូវបានកម្រិតអោយមានត្រឹមតែសមាជិកក្រុមប្រឹក្សាឃុំចំនួន ១១.៣៥៣នាក់ដែលបានជាប់ឆ្នោតនៅក្នុងការបោះឆ្នោតឃុំនៅឆ្នាំ២០០៧ ។ គណបក្សប្រជាជនកម្ពុជា បានទទួល អាសនៈថ្នាក់ខេត្តចំនួន ៣០២ និងអាសនៈថ្នាក់ ស្រុកចំនួន ២.២៤៩ ហើយអាសនៈដែលនៅសល់ត្រូវបែងចែក ក្នុងចំណោមគណបក្សរាជានិយម និងគណបក្សប្រឆាំងនានា ។

គណបក្សអាចចុះបញ្ជី ហើយបុគ្គលមានសេរីភាពប្រកាសបេក្ខភាពរបស់ខ្លួនដោយគ្មានការរឹតត្បិត ។ នៅខែមិថុនា គណបក្ស នរោត្តម រណឫទ្ធិ បានក្លាយជាគណបក្សជាតិនិយមជាផ្លូវការក្រោយពីព្រះអង្គម្ចាស់ រណឫទ្ធិដកខ្លួនពី នយោបាយ ។

អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយមួយចំនួន បានចោទប្រកាន់ថាការចូលជាសមាជិក នៅក្នុងគណបក្សប្រជាជនកម្ពុជាដែលនាំមុខគេ ទទួលបានអត្ថប្រយោជន៍ ដូចជាអំណោយ ឬលទ្ធភាព ទទួលជំនួយសង្គ្រោះបន្ទាន់របស់រដ្ឋាភិបាល ។

វប្បធម៌ប្រពៃណី បានកម្រិតតួនាទីរបស់ស្ត្រីនៅក្នុងរដ្ឋាភិបាល ទោះជាយ៉ាងណាក៏ដោយ ស្ត្រីបានចូលរួមនៅក្នុង ការបោះឆ្នោតអសកល ដើម្បីជ្រើសរើសក្រុមប្រឹក្សាខេត្តនិងស្រុក ។ មានស្ត្រីចំនួន ២៧នាក់ បានកាន់កាប់អាសនៈ សភាដែលមានចំនួន ១២៣អាសនៈ និងស្ត្រីចំនួន ៩នាក់នៅក្នុងព្រឹទ្ធសភាដែលមាន ៦១អាសនៈ ។ មានឧបនាយក រដ្ឋមន្ត្រីម្នាក់ជាស្ត្រី និងមានរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងមន្ត្រីគណៈកម្មការរៀបចំ ការបោះឆ្នោត សរុបចំនួន ៤៥នាក់ ។ ស្ត្រីក៏បានបំពេញតួនាទីជាទីប្រឹក្សា និងចៅក្រមចំនួន ២៣នាក់នៅតុលាការរាជធានី និង តុលាការខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូលផងដែរ ។ ទោះបីជាគ្មានអភិបាលខេត្តជាស្ត្រីក៏ដោយ ក៏រដ្ឋា ភិបាលបានតែងតាំងស្ត្រីជាអភិបាលរងខេត្តនៅគ្រប់ខេត្ត និងរាជធានីភ្នំពេញលើកលែងតែខេត្តមួយប៉ុណ្ណោះ។ គណៈកម្មការជាតិរៀបចំការបោះឆ្នោត បានរាយការណ៍ថា ស្ត្រីបានកាន់កាប់ ១៣ភាគរយនៃអាសនៈក្រុមប្រឹក្សា ស្រុក និង ១០ភាគរយនៃអាសនៈក្រុមប្រឹក្សាខេត្ត ។

មានសមាជិកជាជនជាតិភាគតិចំនួន ៥នាក់ បួននាក់ជាជនជាតិឥស្លាមនិងម្នាក់ទៀតជាជនជាតិភាគតិចផ្សេងទៀតនៅក្នុងសភាជាតិ ។ ក៏មានសមាជិកជនជាតិភាគតិចបីរូបផងដែរនៅក្នុងព្រឹទ្ធសភា ។ យ៉ាងហោចណាស់មានមន្ត្រីប្រាំបីរូបកាន់មុខតំណែងជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាលមកពីក្រុមជនជាតិភាគតិច ។

## ផ្នែកទី៤ ៖ អំពើពុករលួយផ្លូវការ និងតម្លាភាពរបស់រដ្ឋាភិបាល

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌសម្រាប់អំពើពុករលួយផ្លូវការ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពឡើយ ហើយមន្ត្រីជាញឹកញាប់តែងតែចូលរួមក្នុងអំពើពុករលួយដោយនិរទណ្ឌភាព ។ ពុំមានច្បាប់ប្រឆាំងនឹងអំពើពុករលួយហ្មត់ចត់ឡើយ ។

អំពើពុករលួយត្រូវចាត់ទុកថាមានលក្ខណៈរីករាលដាល និងទូលំទូលាយនៅគ្រប់ផ្នែកនៃសង្គម រួមទាំងផ្នែកនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការនៃរដ្ឋាភិបាល ។ បទពិសោធន៍សាធារណជនដែលបានរាយការណ៍ទាក់ទងនឹងអំពើពុករលួយមានលក្ខណៈទូលំទូលាយ បញ្ជាក់ថាអំពើពុករលួយជាច្រើនពុំមានលាក់លៀមឡើយ ។ បៀវត្សរ៍មិនគ្រប់គ្រាន់រួមចំណែកអោយមាន “អំពើពុករលួយដើម្បីរស់” ក្នុងចំណោមអ្នកបម្រើការសាធារណៈថ្នាក់ទាបចំណែកវប្បធម៌និរទណ្ឌភាព ធ្វើអោយអំពើពុករលួយអាចរីកសាយក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។ នៅខែមិថុនាមន្ត្រីក្រសួងយុត្តិធម៌ម្នាក់ ត្រូវបានចោទប្រកាន់អំពីការទទួលសំណូក ។ នៅខែកញ្ញា ក្រសួងយុត្តិធម៌បានស៊ើបអង្កេតចៅក្រមតុលាការខេត្តម្នាក់នៅខេត្តរតនៈគិរី ចំពោះឧប្បត្តិហេតុដែលបាន ចោទប្រកាន់ពីបទអំពើពុករលួយមួយចំនួន រួមមានការប្រើប្រាស់ជាប្រយោជន៍ឯកជននូវយានជំនិះដែលរឹបអូសបានជាភស្តុតាង នៅក្នុងរឿងក្តីមួយ ប៉ុន្តែការស៊ើបអង្កេតបានសន្និដ្ឋានថាគ្មានកំហុសអ្វីទាំងអស់ ។ មន្ត្រីសាធារណៈមិនស្ថិតក្រោមច្បាប់ប្រកាសទ្រព្យសម្បត្តិឡើយ ។

នៅដំណាច់ឆ្នាំ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានអនុម័តពង្រាងច្បាប់ប្រឆាំងអំពើពុករលួយ និងត្រៀមបញ្ជូនពង្រាងច្បាប់នេះ ទៅកាន់សភាជាតិដើម្បីពិនិត្យ និងអនុម័ត ។ ម្ចាស់អំណោយ និងអនាគតវិនិយោគិន នៅតែបន្តសម្តែងក្តីបារម្ភអំពីការខ្វះច្បាប់ប្រឆាំងនឹងអំពើពុករលួយ និងអំពីតម្រូវការជាបន្ទាន់ដើម្បីអនុម័តច្បាប់នេះ ។ អង្គការសង្គមស៊ីវិលនៅតែបន្តរង់ចាំការឆ្លើយតបចំពោះញត្តិនៅខែឧសភារបស់ខ្លួន ដែលបានបញ្ជូនទៅកាន់សភាជាតិដោយអំពាវនាវអោយអនុម័តច្បាប់ប្រឆាំងអំពើពុករលួយស្របតាមស្តង់ដារអន្តរជាតិ ។ ញត្តិនេះមានហត្ថលេខា និងស្នាមមេដៃរបស់ប្រជាជនជាង ១,១ លាននាក់ ដែលមានអាយុអាចបោះឆ្នោតបាន ។

ច្បាប់មិនមានបញ្ញត្តិដែលផ្តល់កិច្ចការការពារដល់ជនដែលលាតត្រដាងអំពើពុករលួយក្នុងអង្គភាពឡើយ ។ ស្ថាប័នប្រឆាំងអំពើពុករលួយឯករាជ្យក៏គ្មានដែរ ។ អង្គភាពប្រឆាំងអំពើពុករលួយរបស់គណៈរដ្ឋមន្ត្រីមានភារកិច្ចរៀបចំវិធានការប្រឆាំងអំពើពុករលួយ និងបង្ហាញសំណើជូនរដ្ឋាភិបាល ។ ក្រសួងទំនាក់ទំនងរដ្ឋសភា និងអធិការកិច្ច

មានអាណត្តិស៊ើបអង្កេតការចោទប្រកាន់អំពីអំពើពុករលួយ ។ អាជ្ញាធរជាតិសវនកម្មមានអំណាចធ្វើសវនកម្ម ក្រសួង ស្ថាប័ន និងអង្គភាពដទៃទៀត ។

ច្បាប់ស្តីពីបណ្ណសារជាតិ (National Archives Law) អនុញ្ញាតអោយទទួលឯកសារព័ត៌មានគ្មានកំណត់ នៅក្នុងប័ណ្ណសារសាធារណៈ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះផ្តល់លទ្ធភាពទទួលឯកសាររដ្ឋាភិបាលមិន ជាក់លាក់ ទាល់តែក្រោយរយៈពេល ២០ឆ្នាំ ចំណែកឯឯកសារប៉ះពាល់ដល់សន្តិសុខជាតិ និងរក្សាជីវិត ផ្ទាល់ខ្លួនអាចបញ្ចេញអោយបានលុះត្រាក្រោយរយៈពេល ៤០ឆ្នាំ និង ១២០ឆ្នាំ ។ មាន អង្គការមិនមែនរដ្ឋាភិបាល មួយចំនួនបានរាយការណ៍ថា នៅក្នុងការអនុវត្តជាក់ស្តែង ខ្លួនមានការលំបាកក្នុងការ ទទួលបានព័ត៌មាន រដ្ឋាភិបាលជាញឹកញាប់មិនបាន ឬមិនអាចឆ្លើយតបចំពោះសំណើសុំព័ត៌មានបានឡើយ ។

## ផ្នែកទី៥ ៖ ឥរិយាបថរដ្ឋាភិបាលចំពោះការអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការមិនមែន រដ្ឋាភិបាលអំពីការរំលោភសិទ្ធិមនុស្សដែលបានចោទប្រកាន់

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិផ្សេងៗ ជាទូទៅ ធ្វើប្រតិបត្តិការដោយគ្មានការរឹតត្បិតពីរដ្ឋាភិបាល ឡើយ ក្នុងការស៊ើបអង្កេត និងបោះពុម្ពផ្សាយរបកគំហើញអំពីករណីសិទ្ធិមនុស្សរបស់ខ្លួន ។ ជារឿយៗ មន្ត្រី រដ្ឋាភិបាលបានសហការជាមួយបុគ្គលិកសិទ្ធិមនុស្សក្នុងការស៊ើបអង្កេតរបស់ខ្លួន ទោះជាយ៉ាងណាក៏ដោយ មាន របាយការណ៍ជាច្រើនអំពីកង្វះខាតកិច្ចសហការ ហើយនៅក្នុងករណីមួយចំនួន មានការបំភិតបំភ័ដោយមន្ត្រី រដ្ឋាភិបាលមូលដ្ឋាន ។

មានអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិមនុស្សប្រមាណជា ៤០ នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែ មានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលចូលរួមយ៉ាងសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬស៊ើបអង្កេត ការរំលោភសិទ្ធិមនុស្ស ។

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ ជួបប្រទះការគម្រាមកំហែង និងការធ្វើទុក្ខបុកម្នេញពីមន្ត្រីមូលដ្ឋាន ។ អំពើទាំងនេះ មានលក្ខណៈជាទម្រង់រឹតត្បិត និងការរំខានដល់ការជួបប្រជុំដែលឧបត្ថម្ភដោយអង្គការមិនមែន រដ្ឋាភិបាលនានា ការបំភិតបំភ័យដោយពាក្យសម្តីការគម្រាមចាត់វិធានការផ្លូវច្បាប់និងការរារាំងផ្នែកការិយាល័យ ជាច្រើន ។ មេធាវីបម្រើផលប្រយោជន៍សាធារណៈរបស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវបដិសេធមិនអោយជួប កូនក្តីជាប់ឃុំនៅក្នុងករណីរំលោភសិទ្ធិមនុស្សមួយចំនួន ហើយអង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាមន្ត្រី រដ្ឋាភិបាលបានព្រមានថាតំណាងអង្គការមិនមែនរដ្ឋាភិបាល អាចត្រូវចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និង ការញុះញង់ ប្រសិនបើខ្លួននិយាយទៅកាន់បណ្តាញសារព័ត៌មានអំពីករណីទាំងនោះ ។

នៅខែកក្កដា តុលាការខេត្តរតនៈគិរី បានកោះហៅតំណាងអង្គការ ADHOC ពីរនាក់ មកសាកសួរទាក់ទងនឹងបណ្តឹងដែលថាពួកគេបានញុះញង់អ្នកភូមិនៅក្នុងវិវាទមួយលើដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនមួយ ។ នៅថ្ងៃទី ០៤ ខែសីហា តុលាការនេះបានយល់ព្រមពន្យាពេលការសាកសួរ ដើម្បីអោយផ្តល់ពេលវេលាអោយមេធាវីចុងចោទពិនិត្យមើលករណីនោះ ។ អង្គការ ADHOC បានដកនិយោជិតពីរនាក់របស់ខ្លួនចេញពីខេត្តរតនៈគិរី រួចហើយចាត់តាំងអោយពួកគេបំពេញការងារនៅខេត្តផ្សេង ក្រោយពីការចៅក្រមស៊ើបសួរនៅក្នុងរឿងក្តីនេះឈ្មោះ ធរ សារុន បានស្នើជាសាធារណៈថា ប្រសិនបើ និយោជិតទាំងពីរនាក់នោះ ចាកចេញពីខេត្តនឹងគ្មានការចោទប្រកាន់ចំពោះពួកគេឡើយ ។ នៅដំណាច់ឆ្នាំ និយោជិតអង្គការ ADHOC ម្នាក់បាននៅភ្នំពេញ ចំណែកឯម្នាក់ទៀតបានវិលត្រឡប់ទៅកាន់ខេត្តរតនៈគិរីវិញ ។

ជាមួយគ្នានេះដែរ នៅខែកក្កដា តុលាការខេត្តបន្ទាយមានជ័យ បានចោទប្រកាន់និយោជិតបីនាក់របស់អង្គការក្នុងស្រុកឈ្មោះសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅផ្លូវការនិងសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សសមរង្ស៊ីម្នាក់ រួចហើយឃុំខ្លួនពួកគេបណ្តោះអាសន្ន ។ អ្នកទាំងបួននាក់នេះ ស្ថិតក្នុងចំណោមក្រុមធំដែលមានចំនួន ៣០នាក់ ដែលត្រូវចាប់ខ្លួនពីបទញុះញង់ និងការចោទប្រកាន់ដទៃទៀត បណ្តាលមកពីបាតុកម្មមួយនៅក្នុងវិវាទដីធ្លីមួយនៅក្រុងប៉ោយប៉ែត ។ នៅដំណាច់ឆ្នាំ អ្នកដែលត្រូវចាប់ខ្លួនទាំងអស់ ត្រូវបានដោះលែងអោយនៅក្រៅឃុំ ហើយកំពុងរង់ចាំការជំនុំជម្រះក្តី ទោះជាយ៉ាងណាក៏ដោយគ្មានការកំណត់កាលបរិច្ឆេទសម្រាប់ធ្វើការជំនុំជម្រះឡើយ ។

រដ្ឋាភិបាល បានសហការជាមួយអង្គការរដ្ឋាភិបាលអន្តរជាតិហើយបានអនុញ្ញាតអោយតំណាងអង្គការសហប្រជាជាតិ មកធ្វើទស្សនកិច្ច ។ នៅខែមិថុនា អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅ កម្ពុជា លោក Surya Subedi បានមកធ្វើទស្សនកិច្ចនៅកម្ពុជា ។ នាយករដ្ឋមន្ត្រី និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ដទៃទៀត បានជួបលោក Subedi ដែលជាការផ្ទុយទៅនឹងការបដិសេធសំណើសុំជួបរបស់តំណាងមុនៗ។

រដ្ឋាភិបាលមានស្ថាប័នសិទ្ធិមនុស្សចំនួនបី ៖ គណៈកម្មការទទួលបន្ទុកការពារសិទ្ធិមនុស្ស គណៈកម្មការទទួលពាក្យ បណ្តឹងដាច់ដោយឡែកពីគ្នា និងគណៈកម្មការសិទ្ធិមនុស្សកម្ពុជាដែលរាយការណ៍ទៅកាន់ទីស្តីការគណៈរដ្ឋមន្ត្រី ។ គណៈកម្មការទាំងនេះ មិនជួបប្រជុំទៀងទាត់ ឬមានដំណើរការប្រតិបត្តិការដោយតម្លាភាពឡើយ ។ គណៈកម្មការ នេះ ដាក់ជូនរបាយការណ៍ទៅរដ្ឋាភិបាល
ដើម្បីចូលរួមនៅក្នុងដំណើរការពិនិត្យមើលសិទ្ធិមនុស្សអន្តរជាតិ ដូចជា ការពិនិត្យជាសកលជាទៀងទាត់ ប៉ុន្តែមិនបានធ្វើការស៊ើបអង្កេតអំពីបញ្ហាសិទ្ធិមនុស្សដោយឯករាជ្យឡើយ ។ អង្គការសិទ្ធិមនុស្សបានចាត់ទុកគណៈកម្មការរបស់រដ្ឋាភិបាលនេះថាមានប្រសិទ្ធភាពបន្តួចបន្តួចប៉ុណ្ណោះ ។

រដ្ឋាភិបាលបានទទួលធ្វើជាម្ចាស់ផ្ទះអោយ ECCC ចម្រុះ ដែលត្រូវបានរៀបចំឡើងរួមគ្នា ជាមួយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពាននៅក្នុងសម័យខ្មែរក្រហម ។ គ្មានការចោទប្រកាន់អំពីអំពើពុករលួយនៅក្នុងរដ្ឋបាលតុលាការនេះឡើយ នៅអំឡុងឆ្នាំនេះ ។ អ្នកសង្កេតការណ៍ខ្លះ មានជំនឿថាមតិជាសាធារណៈធ្វើឡើងដោយមេដឹកនាំរដ្ឋាភិបាល លើបញ្ហាទាក់ទងនឹងអាណត្តិគតិយុត្តិរបស់ ECCC គឺជាទម្រង់នៃការជ្រៀតជ្រែកផ្នែកនយោបាយមួយ ទោះជាយ៉ាងណាក៏ដោយ គ្មានភស្តុតាងបញ្ជាក់ថាការងាររបស់តុលាការ ត្រូវបានរារាំងដោយរបៀបណាមួយនោះឡើយ ហើយអាជ្ញាធរជាតិបានបំពេញភារកិច្ចរបស់ខ្លួនដោយជោគជ័យក្នុងការចាប់ខ្លួន និងបញ្ជូនខ្លួនជនដែលត្រូវចោទប្រកាន់ ដោយ ECCC ទាំងអស់ទៅអោយសាលាក្តី ។ ពុំទាន់មានការសម្រេចណាមួយរបស់សាលាក្តីនេះ ធ្វើឡើងចំពោះជនជាប់ចោទឡើយនៅអំឡុងឆ្នាំនេះ ។

## ផ្នែកទី៦ ៖ ការរើសអើង ការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស

រដ្ឋធម្មនុញ្ញហាមប្រាមចំពោះការរើសអើងផ្នែកពូជសាសន៍ ភេទ ពិការភាព ភាសា និងឋានៈសង្គមដទៃទៀត ទោះជាយ៉ាងណាក៏ដោយ ជាទូទៅរដ្ឋាភិបាលមិនបានការពារសិទ្ធិទាំងនេះឡើយ ។

## ស្ត្រី

ច្បាប់ហាមប្រាមចំពោះការរំលោភសេពសន្ថវៈ និងការបំពានលើរូបរាងកាយ ប៉ុន្តែទោះជាយ៉ាណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ បានរាយការណ៍ថា អំពើហឹង្សាលើស្ត្រី រួមមានដូចជាអំពើហឹង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈជាដើមនៅតែកើតមានយ៉ាងច្រើន ។ ការរំលោភសេពសន្ថវៈ គឺជាបទល្មើសព្រហ្មទណ្ឌ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី៥ ទៅ ១០ឆ្នាំ យោងតាមច្បាប់អន្តរកាលរបស់ UNTAC ។ តាមច្បាប់អន្តរកាលរបស់ UNTAC ករណីរំលោភសេព សន្ថវៈដោយប្តី ឬប្រពន្ធ ក៏អាចត្រូវកាត់ទោសជា ករណី "រំលោភសេពសន្ថវៈ" "បង្ករបួសស្នាម" ឬ "បំពានដោយគ្មានសេចក្តីថ្លៃថ្នូរ" ផងដែរ ។ តាមច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារឆ្នាំ២០០៥ ការរំលោភសេពសន្ថវៈដោយប្តី ឬប្រពន្ធ ក៏អាចស្ថិតនៅក្នុងនិយមន័យនៃច្បាប់ប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារដែលរួមមានដូចជា "ការបៀតបៀនផ្លូវភេទ" ជាដើម ។ ការចោទប្រកាន់អំពីករណីរំលោភសេពសន្ថវៈដោយប្តី ឬប្រពន្ធ តាមច្បាប់អន្តរកាលរបស់ UNTAC និងច្បាប់ប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារកម្រឃើញត្រូវបានអនុវត្តណាស់ ។ ច្បាប់ប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារ ចាត់ទុកអំពើហឹង្សាក្នុងគ្រួសារជាទោសឧក្រិដ្ឋ ប៉ុន្តែមិនបានចែងពីទោសបញ្ញត្តិច្បាស់លាស់ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់អន្តរកាលរបស់ UNTAC ស្តីពីការវាយដំ និងការបង្ករបួសស្នាមអាចត្រូវបានប្រើប្រាស់ ដើម្បីដាក់ទោសបទល្មើសហឹង្សាក្នុងគ្រួសារដោយមានទោសជាប់ពន្ធនាគារចាប់ពីពីរខែទៅប្រាំឆ្នាំ ។

យោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយបានអោយដឹងថា មានករណីរំលោភសេពសន្ថវៈចំនួន ៤៣១ករណី និងករណីអំពើហឹង្សាក្នុងគ្រួសារចំនួន ៤៩៧ករណី ត្រូវបានរាយការណ៍គិតមកដល់ខែវិច្ឆិកា ហើយតុលាការបានជំនុំជម្រះតែ ៧១ករណីប៉ុណ្ណោះ ។ មានអង្គការមិនមែនរដ្ឋាភិបាលមួយផ្សេងទៀត បានចងក្រងទុកជាឯកសារនូវអំពើហឹង្សាក្នុងគ្រួសារចំនួន ១២៧ករណី ដែលប៉ះពាល់ដល់ជនរងគ្រោះចំនួន ១៣១នាក់ នៅខេត្តចំនួន ១៤ គិតមកដល់ខែកញ្ញា ។ នៅអំឡុងឆ្នាំនេះ ផ្នែកប្រឆាំង នឹងការជួញដូរមនុស្សរបស់ក្រសួងមហាផ្ទៃបានស៊ើបអង្កេតអំពើហឹង្សាលើស្ត្រី និងកុមារចំនួន ៣៥៥ករណីនាំ អោយមានការចាប់ខ្លួនជនល្មើសចំនួន ៣៩៤នាក់ និងសង្គ្រោះជនរងគ្រោះចំនួន ៤៩៦នាក់ ។ ក្នុងចំណោម អំពើហឹង្សា ៣៥៥ករណី មានចំនួន២៤៩ករណី គឺជាបទល្មើសរំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈ ។ ក្រសួងមហាផ្ទៃ បានរាយការណ៍ថាមានករណីរំលោភសេពសន្ថវៈចំនួនបីករណីបណ្តាលអោយជនរងគ្រោះបួននាក់ស្លាប់ ។ ចំនួនករណីទាំងនេះ អាចនឹងរាយការណ៍មិនអស់អំពីវិសាលភាពនៃបញ្ហានេះឡើយ ដោយសារការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព គ្មានរបាយការណ៍ស្ថិតិស្តីពីបទឧក្រិដ្ឋគ្រប់គ្រាន់ និងការណ៍ដែលស្ត្រីភ័យខ្លាចមិនហ៊ានដាក់ពាក្យបណ្តឹងប្រឆាំងនឹងជនល្មើស ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ការអនុវត្តច្បាប់ប្រឆាំងនឹងអំពើហឹង្សានៅទន់ខ្សោយ អាជ្ញាធរនៅតែបន្តចៀសវាងមិនចូលពាក់ព័ន្ធនឹងវិវាទគ្រួសារ ហើយជាញឹកញាប់ ជនរងគ្រោះស្ទាក់ស្ទើរ នឹងបន្តបណ្តឹងផ្លូវការ ។

តាមរបាយការណ៍ មានស្ត្រីអាយុ ១៩ឆ្នាំម្នាក់ ត្រូវបានរំលោភសេពសន្ថវៈនៅខែវិច្ឆិកាដោយមន្ត្រីនគរបាលម្នាក់ ចំណែកឯមន្ត្រីនគរបាលម្នាក់ទៀតជាអ្នកចាប់នាងផ្តួល ។ មន្ត្រីនគរបាលបានទទួចថាជនល្មើសទាំងនោះត្រូវបញ្ជូន ទៅតុលាការដើម្បីកាត់ទោស ហើយតុលាការបានដោះលែងអោយនៅក្រៅឃុំ ។ មន្ត្រីតុលាការបានទទួចថា ពួកគេបានទទួលបណ្តឹងអំពីករណីនោះ ប៉ុន្តែពុំមានការឃាត់ខ្លួនជនល្មើសទេ ហើយនគរបាលបានដោះលែង ជនល្មើសទាំងនោះ ។ តាមការសន្មត ជនរងគ្រោះបាត់ខ្លួនភ្លាមក្រោយពីបានទទួលប្រាក់មួយលានរៀល (ប្រហែល ២៥០ដុល្លារ) ជាសំណង ។ ការចោទប្រកាន់ក៏លែងបន្តទៅមុខ ចំណែកឯជនល្មើសនៅតែមានសេរីភាពមកដល់ ដំណាច់ឆ្នាំ ។ ក្រសួងមហាផ្ទៃ មិនបានឆ្លើយតបចំពោះសំណើសុំការបញ្ជាក់ដោយសមាជិកសភាជាតិឡើយ ។

នៅខែកុម្ភៈ គណៈរដ្ឋមន្ត្រីបានអនុម័តផែនការបីឆ្នាំ ដើម្បីទប់ស្កាត់អំពើហឹង្សាលើស្ត្រី ។ មានពិធីសម្ពោធចាប់ផ្តើមអនុវត្តផែនការនេះ រៀបចំឡើងដោយក្រសួងកិច្ចការនារី ដែលជាអង្គភាពសំខាន់ទទួលបន្ទុកអនុវត្តផែនការនេះ ។ សៀវភៅប្រមាណជា ២.០០០ក្បាល និយាយអំពីផែនការនេះ ត្រូវបានបោះពុម្ព និងចែកជូនដល់មន្ទីរកិច្ចការនារីខេត្ត និងក្រសួងនានា និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ។

រដ្ឋាភិបាលបានគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការបណ្តុះបណ្តាលសម្រាប់ស្ត្រីងាយរងគ្រោះពីការរំលោភបំពានពីស្វាមី ពេស្យាកម្ម និងការជួញដូរមនុស្ស ។ មជ្ឈមណ្ឌលព័ត៌មានក្នុងស្រុកមួយ អង្គការមិនមែន

រដ្ឋាភិបាល និងក្រសួងកិច្ចការនារីបានផលិតកម្មវិធីទាក់ទងនឹងបញ្ហាស្ត្រី ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនក៏បានផ្តល់ទីជម្រកសម្រាប់ស្ត្រីមានវិបត្តិផងដែរ ។

រដ្ឋធម្មនុញ្ញហាមប្រាមចំពោះពេស្យាកម្ម ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពុំមានច្បាប់ជាក់លាក់ប្រឆាំងនឹងការងារពេស្យាកម្មឡើយ ។ ការជួញដូរស្ត្រី ក្នុងគោលបំណងពេស្យាកម្ម គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ទោះបីមានច្បាប់ប្រឆាំងនឹងការជ្រើសរើស និងចាប់ជម្រិតដើម្បីកេងប្រវ័ញ្ចផ្លូវភេទក៏ដោយ ។ មានរបាយការណ៍ជាច្រើនថា នគរបាលបានរំលោភបំពានផ្លូវភេទលើស្ត្រីជាប់ឃុំ ដោយសង្ស័យពីបទពេស្យាកម្ម និងអនុញ្ញាតអោយសារព័ត៌មានថតរូបពួកគេ ទោះបីពួកគេមិនត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌអ្វីមួយក៏ដោយ ។ ទោះបីជាមានការបង្ក្រាបកើនឡើងក៏ដោយ ក៏ម្ចាស់ផ្ទះបននៅភ្នំពេញ ពេស្យាកម្ម និងការជួញដូរមនុស្ស នៅតែកើតមានដដែល ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ រោគសើស្បែក និងកាមរោគ បានរាយការណ៍ថា មានស្ត្រីប្រហែល ៣.០០០នាក់ កំពុងបម្រើការជាពេស្យាចារដោយផ្ទាល់ និងចំនួន ៣១.០០០នាក់ បម្រើការជាពេស្យាចារ ដោយប្រយោលនៅក្នុងការងារបំរើការសប្បាយ ។ អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ក្លឹបមួយចំនួនបានរាយការណ៍ថាមានការកើនឡើងនូវចំនួនស្ត្រីដែលកំពុងស្វែងរកការងារនៅក្នុងពេស្យាកម្មដោយផ្ទាល់ និងសេវាផ្លូវភេទដោយប្រយោល ដូចជាការងារម៉ាស្សា និងការ៉ាអូខេជាដើម ។ ទេសចរណ៍ផ្លូវភេទ គឺជាបញ្ហាមួយដែលកាន់តែធ្ងន់ធ្ងរដោយសារភាពក្រីក្រដែលរីករាលដាល និងទស្សនទាននិរទន្ឋភាព ។

ច្បាប់ការងារមានចែងពីបទប្បញ្ញត្តិប្រឆាំងនឹងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ប៉ុន្តែ ពុំមានបញ្ជាក់អំពីការពិន័យឡើយ ។

គូស្រករ និងបុគ្គលម្នាក់ៗ អាចសម្រេចអំពីចំនួនកូន ការពន្យាកំណើត និងការកំណត់ពេលវេលាសម្រាប់យកកូន ហើយមានព័ត៌មាន និងមធ្យោបាយដើម្បីធ្វើកិច្ចការនេះ ដោយគ្មានការរើសអើងឡើយ ។ ស្ត្រីមានលទ្ធភាពប្រើប្រាស់មធ្យោបាយពន្យាកំណើត ព្រមទាំងឆ្មបដែលមានជំនាញនៅពេលសម្រាលកូន និងការថែទាំក្រោយពេលសម្រាលកូន ប៉ុន្តែលទ្ធភាពជារឿយៗមានកម្រិតដោយសារប្រាក់ចំណូល និងឧបសគ្គផ្នែកភូមិសាស្ត្រ ។ ស្ត្រីមានលទ្ធភាពស្មើគ្នាក្នុងការទទួលសេវាវិនិច្ឆ័យរោគ និងព្យាបាលជំងឺឆ្លងដោយសារការរួមភេទ ដែលរួមមានដូចជាមេរោគអេដស៍ជាដើម ។

រដ្ឋធម្មនុញ្ញបានចែងអំពីសិទ្ធិស្មើគ្នាសម្រាប់ស្ត្រី ប្រាក់ឈ្នួលស្មើគ្នា និងឋានៈស្មើគ្នានៅក្នុងចំណាងអាពាហ៍ពិពាហ៍ ។ ទោះជាយ៉ាងណាក៏ដោយ មានរបាយការណ៍របស់អង្គការសហប្រជាជាតិមួយបានរិះគន់ចំពោះការបង្រៀនជាបន្តអំពី "ច្បាប់ស្រី" នៅក្នុងកម្មវិធីសិក្សាបឋមសិក្សា ដែលខ្លួនបានអះអាងថាធ្វើអោយតួនាទីរបស់ស្ត្រីនៅក្នុងសង្គមមានភាពអន់ជាង ជាការស្របច្បាប់ ។ ភាគច្រើនបំផុត ស្ត្រីមានសិទ្ធិស្មើគ្នាលើទ្រព្យសម្បត្តិ ឋានៈស្របច្បាប់ស្មើគ្នា ដើម្បីដាក់បណ្តឹងលែងលះ និងមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំ និង

ការងារមួយចំនួន ទោះជា យ៉ាងណាក៏ដោយ ប្រពៃណីវប្បធម៌នៅតែបន្តកម្រិតសមត្ថភាពរបស់ស្ត្រីក្នុងការឈោងចាប់មុខតំណែងខ្ពស់ៗនៅ ក្នុងអាជីវកម្ម និងវិស័យដទៃទៀត ។ ជារឿយៗ ស្ត្រីច្រើនមានការងារដែលទទួលបានប្រាក់ចំណូលទាប ហើយ ភាគច្រើនត្រូវផាត់ចេញពីមុខតំណែងគ្រប់គ្រង ។ បុរសភាគច្រើនបំពេញការងារនៅក្នុងកងយោធា នគរបាល និងមន្ត្រីរាជការស៊ីវិល ។

ក្រសួងកិច្ចការនារី ដែលមានអាណត្តិការពារសិទ្ធិស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គមនោះ បានបន្តកម្មវិធីនារីរតនៈរបស់ខ្លួនតទៅមុខទៀត ។ កម្មវិធីនេះ មានបំណងកែលម្អមុខមាត់ស្ត្រីតាមរយៈការបញ្ជ្រាបយេនឌ័រ បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងជីវភាពសេដ្ឋកិច្ច និងនយោបាយ និងការការពារសិទ្ធិនារី ។ ២២ភាគរយនៃ គ្រូបង្រៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ៣៧កន្លែងដែលគ្រប់គ្រងដោយរដ្ឋាភិបាលគឺជាស្ត្រីភេទ ដែលចំនួននេះកើនពី ១៣ភាគរយនៅឆ្នាំ២០០៥ ។ ស្ថាប័នរដ្ឋាភិបាលចំនួន ១៦ មានផែនការអនុវត្តសកម្មភាព បញ្ជ្រាបយេនឌ័រ ដែលមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងដោយការសហការយ៉ាងជិតស្និទ្ធ ជាមួយ ក្រសួងកិច្ចការនារី។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ឆ្នាំ២០០៦-២០១០ បានប្តេជ្ញាធានាថា ស្ត្រីដែលជា ចំណែកមួយនៅក្នុងការងារដែលបានទទួលប្រាក់ឈ្នួល នឹងបង្កើនអោយបាន ៥០ភាគរយនៅក្នុងផ្នែកកសិកម្ម និងឧស្សាហកម្ម និង ៣៧ភាគរយនៅក្នុងផ្នែកសេវាកម្ម ។

**កុមារ**

តាមច្បាប់ សញ្ជាតិអាចទទួលបានពីកំណើតពីម្តាយ និងឪពុកដែលមិនមែនជាជនជាតិខ្មែរ ប្រសិនបើឪពុកម្តាយទាំងពីរបានកើត និងកំពុងរស់នៅកម្ពុជា ឬប្រសិនបើឪពុក ឬម្តាយបានទទួលសញ្ជាតិខ្មែរ ។ ក្រសួងមហាផ្ទៃបានរៀបចំប្រព័ន្ធចុះសំបុត្រកំណើតបែបទំនើបមួយ ប៉ុន្តែការចុះសំបុត្រកំណើត មិនបានធ្វើឡើងភ្លាមៗបានទាំងអស់នោះទេ ជាចម្បងដោយសារតែភាពយឺតយ៉ាវរបស់ឪពុកម្តាយ ។ ប្រព័ន្ធនេះ មិនបានបញ្ចូលការចុះដល់មូលដ្ឋានជាពិសេសទៅកាន់សហគមន៍ជនជាតិភាគតិចឡើយ ។ ជាងនេះទៅទៀត កុមារដែលកើតពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ជារឿយៗ មិនបានចុះសំបុត្រកំណើតទេ ដោយសាររបបខ្មែរក្រហម/ការកាន់កាប់របស់ប្រទេសវៀតណាម/សង្គ្រាមស៊ីវិល ។ អ្នកដែលគ្មានសំបុត្រកំណើតជាច្រើនទាំងនេះដែលក្រោយមកមានក្រុមគ្រួសាររបស់ខ្លួនផ្ទាល់មិនបានមើលឃើញអំពីភាពចាំបាច់នៃការធ្វើសំបុត្រកំណើតឡើយ។ ជាទូទៅ យុវជនមិនបានចុះសំបុត្រកំណើតឡើយលុះត្រាតែមានការចាំបាច់ ។ ការខកខានមិនបានចុះសំបុត្រកំណើតទាំងអស់គ្នានាំអោយមានការរើសអើង រួមមានដូចជាការបដិសេធមិន អោយទទួលសេវាសាធារណៈជាដើម ។ ការសិក្សាមួយធ្វើឡើងដោយអង្គការ UNHCR អំពីភាពគ្មានប្រទេសនៅកម្ពុជា បានបញ្ជាក់ថាដំណើការចុះសំបុត្រកំណើត ជាញឹកញាប់មិនបានរាប់បញ្ចូលកុមារជនជាតិភាគតិច និងជនគ្មានប្រទេសឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលនានាដែលផ្តល់សេវាទៅដល់សហគមន៍ដែលត្រូវដកហូតសិទ្ធិបោះឆ្នោតឬសិទ្ធិតំណាងបានរាយការណ៍ថាកុមារដែលគ្មានសំបុត្រកំណើត និងសៀវភៅគ្រួសារជាញឹកញាប់ ពុំត្រូវបានផ្តល់លទ្ធភាពទទួលបាន

ការអប់រំ និងការថែទាំសុខភាពឡើយ ។ អង្គការទាំងនោះ បញ្ជាក់ថានៅក្នុងពេលអនាគត បុគ្គលដដែលទាំងនេះ នឹងមិនមានលទ្ធភាពទទួលបានការងារ មានកម្មសិទ្ធិលើទ្រព្យសម្បត្តិ/ដីធ្លី បោះឆ្នោត ឬប្រើប្រាស់ប្រព័ន្ធច្បាប់ឡើយ ។

កុមារទទួលរងឥទ្ធិពលមិនល្អដោយសារប្រព័ន្ធអប់រំមានលក្ខណៈមិនគ្រប់គ្រាន់ ។ ការអប់រំត្រូវបានផ្តល់ជូនដោយឥតបង់ថ្លៃ រហូតដល់ថ្នាក់ទី៩ ប៉ុន្តែមិនមែនចាំបាច់ត្រូវតែរៀនទេ ។ កុមារជាច្រើនបានបោះបង់ការសិក្សា ដើម្បីជួយ ក្រុមគ្រួសាររបស់ខ្លួនក្នុងការងារកសិកម្មដើម្បីចិញ្ចឹមជីវិត ធ្វើការនៅក្នុងសកម្មភាពដទៃទៀត ចាប់ផ្តើមចូលរៀន ហួសអាយុ ឬមិនបានចូលរៀនទាល់តែសោះ ។ រដ្ឋាភិបាលមិនបានបដិសេធកុមារីពីលទ្ធភាពស្មើគ្នាក្នុងការ ទទួលការអប់រំឡើយ ប៉ុន្តែ ក្រុមគ្រួសារដែលមានកម្រិតធនធាន ជាញឹកញាប់ បានផ្តល់អាទិភាពទៅដល់កុមារា ។ យោងតាមរបាយការណ៍របស់ អង្គការអន្តរជាតិ នានា ការចុះឈ្មោះចូលរៀន បានធ្លាក់ចុះយ៉ាងគំហុកចំពោះកុមារី ក្រោយពីបញ្ចប់បឋមសិក្សា ។ សាលារៀន នៅតំបន់ជាច្រើន ស្ថិតនៅដាច់ស្រយាល ហើយការធ្វើដំណើរគឺជា បញ្ហា ។ ជាពិសេសកុមារីដែលរងគ្រោះ ដោយសារការបារម្ភពីសុវត្ថិភាព ក្នុងការធ្វើដំណើរពីផ្ទះទៅសាលារៀន ។

មានជំនឿថាការរំលោភបំពានកុមារកើតមានឡើងជាច្រើន ទោះបីពុំមានស្ថិតិបង្ហាញក៏ដោយ ។ ការរំលោភសេពសន្ថវៈលើកុមារ នៅតែជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍អំពីករណីរំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈចំនួន ៣៥១ករណី ដែលបានប្រព្រឹត្តទៅលើកុមារអាយុក្រោម ១៨ឆ្នាំ ។ មាន ១៨ករណីទាក់ទងនឹងកុមារដែលមានអាយុក្រោម ៥ឆ្នាំ និង ១៤៤ករណី ទាក់ទងនឹងកុមារដែលមានអាយុពី ៥ឆ្នាំដល់១០ឆ្នាំ និង១៨៩ករណីទាក់ទងនឹងកុមារអាយុពី១០ ដល់១៨ឆ្នាំ ។ ការរួមភេទជាមួយកុមារអាយុក្រោម ១៥ឆ្នាំគឺជាអំពើខុសច្បាប់ ទោះជាយ៉ាងណាក៏ដោយពេស្យាចារ និងការជួញដូរកុមារបានកើតមានឡើង ។ នៅអំឡុងឆ្នាំនេះ ការបង្ក្រាបផ្ទះបនបានសង្គ្រោះកុមារមិនទាន់គ្រប់អាយុ ដែលត្រូវបានជួញដូរសម្រាប់ធ្វើពេស្យាចារជាច្រើន ។ ក្រសួងមហាផ្ទៃបានរាយការណ៍អំពីការចាប់ខ្លួនជនរំលោភផ្លូវភេទកុមារជាជនជាតិបរទេស ចំនួន៣១នាក់ នៅអំឡុងឆ្នាំនេះ ។ កុមារមួយចំនួនបានចូលប្រឡូកនៅក្នុងពេស្យាចារដើម្បីចិញ្ចឹមជីវិតដោយគ្មានការពាក់ព័ន្ធពីភាគីទីបីឡើយ ។

នៅខែឧសភា នាយកពន្ធនាគារក្រុងព្រះសីហនុ បានអនុញ្ញាតជនរំលោភផ្លូវភេទកុមារដែលជាប់ទោសឈ្មោះ Alexander Trofimov កំពុងតែជាប់ទោសរយៈពេល១៨ឆ្នាំ ចំពោះការរំលោភបំពានផ្លូវភេទកុមារ អោយចេញពីពន្ធនាគាររយៈពេលមួយថ្ងៃដើម្បីពិនិត្យគម្រោងវិនិយោគនានា ។ មន្ត្រីរដ្ឋាភិបាល បានចេញលិខិតព្រមានមួយទៅកាន់នាយកពន្ធនាគារនោះ ដែលបានរំលោភបទប្បញ្ញត្តិ ប៉ុន្តែមិនបានចាត់វិធានការបន្ថែមទៀតឡើយ រហូតដល់បណ្តាញព័ត៌មានបានរកឃើញដំណើររឿងនោះ ។ បន្ទាប់មក អាជ្ញាធររបស់ក្រសួងមហាផ្ទៃបានធ្វើការស៊ើបអង្កេតឧប្បត្តិហេតុនោះ ចំណែកឯនាយកពន្ធនាគារ ត្រូវបានបញ្ចុះឋានន្តរសក្តិ រួចហើយផ្លាស់មកធ្វើការងារ

រដ្ឋបាលនៅទីក្រុងភ្នំពេញវិញ ។ នៅថ្ងៃទី២២ មិថុនា អាជ្ញាធរបានចោទប្រកាន់មន្ត្រីជាន់ខ្ពស់ក្រសួងយុត្តិធម៌ម្នាក់ ចំពោះការទទួលសំណូកយ៉ាងច្រើន ជាថ្នូរនឹងការព្យាយាមរៀបចំការដោះលែង Trofimov ក្នុងលេសធ្វើបត្យាប័នទៅប្រទេសរុស្ស៊ី ។ តាមរបាយការណ៍ មន្ត្រីរូបនោះ បានក្លែងឯកសារបត្យាប័ន និងបន្លំហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងនាយករដ្ឋមន្ត្រីនៅលើឯកសារនោះ ។ នៅដំណាច់ឆ្នាំ ករណីនេះនៅរង់ចាំការជំនុំជម្រះនៅចំពោះមុខតុលាការ ។

រដ្ឋាភិបាលបានផ្តល់សេវាមានកម្រិតដល់កុមារតាមចិញ្ចើមថ្នល់ នៅឯមជ្ឈមណ្ឌលស្តារនីតិសម្បទាមួយ ប៉ុន្តែសេវាទាំងនោះ មិនមានលក្ខណៈគ្រប់គ្រាន់ឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានប៉ាន់ប្រមាណថាមានកុមារតាមចិញ្ចើមថ្នល់ប្រមាណជា ១.៥០០នាក់ នៅទីក្រុងភ្នំពេញ ដែលគ្មានទំនាក់ទំនងជាមួយគ្រួសារ និងប្រមាណជា១០.០០០នាក់ ទៅ ១៧.០០០នាក់ធ្វើការងារនៅតាមចិញ្ចើមថ្នល់ ប៉ុន្តែត្រឡប់ទៅជាមួយគ្រួសាររបស់ខ្លួនវិញនៅពេលរសៀល ។ មានកុមារប្រមាណជា ៥០០ ទៅ ១.០០០នាក់ដែលរស់នៅជាមួយគ្រួសាររបស់ខ្លួននៅតាមដងវិថីនានានៅទីក្រុងភ្នំពេញ ។

ក្រសួងមហាផ្ទៃបានរាយការណ៍ថា យ៉ាងហោចមានកុមារចំនួន៥៤នាក់ អាយុក្រោម៦ឆ្នាំ កំពុងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ ។ អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកមួយបានរាយការណ៍ថាមានកុមារដូចប្រភេទនេះ ចំនួន ៤០នាក់ហើយបានអះអាងថា កុមារទាំងនេះទទួលរងការប្រព្រឹត្តមិនគប្បីពីសំណាក់ឆ្មាំពន្ធនាគារ និងប្រឈមមុខនឹងគ្រោះថ្នាក់លើរាងកាយពីឧក្រិដ្ឋជនពេញវ័យរួមបន្ទប់របស់ខ្លួន ។ ជាទូទៅកុមារទាំងនេះ ខ្វះអាហារូបត្ថម្ភ និងការអប់រំបានត្រឹមត្រូវ ។

ពលកម្មកុមារ គឺជាបញ្ហាមួយនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ ។

**ការជួញដូរមនុស្ស**

រដ្ឋាភិបាលបានបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្តច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទដែលបានអនុម័តនៅឆ្នាំ២០០៨ ដែលច្បាប់នេះចាត់ទុកគ្រប់ទម្រង់ទាំងអស់នៃការជួញដូរជាបទឧក្រិដ្ឋ ។ ទោះជាយ៉ាងនេះក្តី ប្រទេសកម្ពុជា នៅតែជាប្រទេសប្រភព ប្រទេសគោលដៅ និងប្រទេសឆ្លងកាត់សម្រាប់បុរស ស្ត្រី និងកុមារដែលត្រូវបានជួញដូរ ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មដដែល ។ ស្ត្រី និងកុមារីជនជាតិវៀតណាមមួយចំនួនត្រូវបានជួញដូរឆ្លងកាត់ប្រទេសកម្ពុជា ដើម្បីកេងប្រវ័ញ្ចនៅក្នុងអាជីវកម្មផ្លូវភេទនៅក្នុងប្រទេសអាស៊ីដទៃទៀត ។

កុមារត្រូវបានជួញដូរទៅកាន់ប្រទេសថៃ និងវៀតណាម ដើម្បីសុំទាន អង្គាសប្រាក់ លក់ដូរតាមចិញ្ចើមថ្នល់ និងលក់ផ្កា ។ ជាញឹកញាប់ កុមារត្រូវធ្លាក់ទៅក្នុងបំណុលដែលតម្រូវអោយសុំទាន ឬលក់ ឬក៏កុមារទាំងនោះបង្កើត

ជាផ្នែកមួយនៃក្រុមអ្នកសុំទានមានលក្ខណៈចាត់តាំង ។ ស្ត្រី និងកុមារ ត្រូវបានជួញដូរទៅកាន់ប្រទេសម៉ាឡេស៊ី និងថៃដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្មដោយបង្ខំនៅក្នុងរោងចក្រ ឬធ្វើជាអ្នកបម្រើតាមផ្ទះ ចំណែកឯបុរស ត្រូវបានជួញដូរដើម្បីកេងប្រវ័ញ្ចពលកម្មដោយបង្ខំនៅក្នុងវិស័យកសិកម្ម នេសាទ និងសំណង់ ។ ប្រទេសកម្ពុជា គឺជាប្រទេសគោលដៅសម្រាប់ពួកអ្នកទេសចរផ្លូវភេទកុមារ ហើយមានរបាយការណ៍កាន់តែច្រើនដែលថាបុរស ជនជាតិអាស៊ីជាច្រើនបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាដើម្បីរួមភេទជាមួយកុមារីព្រហ្មចារីមិនទាន់គ្រប់អាយុ ។

ជនរងគ្រោះដោយសារការជួញដូរមនុស្សជាពិសេស ជនដែលត្រូវជួញដូរដើម្បីកេងប្រវ័ញ្ចផ្លូវភេទបានប្រឈមមុខ នឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ រួមមានដូចជាមេរោគអេដស៍/ជំងឺអេដស៍ជាដើម ។ ក្នុងករណីខ្លះ ជនរងគ្រោះត្រូវបានឃុំខ្លួន និងទទួលរងការរំលោភបំពានទៅលើរូបកាយ និងស្មារតីពីសំណាក់ពួកជនជួញដូរ ម្ចាស់ផ្ទះបន និងអតិថិជន ។

អ្នកជួញដូរមនុស្សក្នុងស្រុក ធ្វើការនៅតំបន់ភូមិសាស្ត្រតូចៗជាក់លាក់ និងដើរតួនាទីជាឈ្មួញកណ្តាលសម្រាប់ បណ្តាញជួញដូរធំៗ ។ មានជំនឿថាក្រុមឧក្រិដ្ឋកម្មចាត់តាំង ទីភ្នាក់ងាររកការងារធ្វើ និងមេខ្យល់រៀបចំអាពាហ៍ពិពាហ៍ មានការចូលរួមក្នុងកម្រិតណាមួយនៅក្នុងឧក្រិដ្ឋកម្មនេះផងដែរ ។ ជនជួញដូរបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីទទួលបានជនរងគ្រោះ ។ ក្នុងករណីជាច្រើន ជនរងគ្រោះ ត្រូវបានអូសទាញដោយការសន្យាផ្តល់/រកការងារស្របច្បាប់ ឬឯកសារធ្វើដំណើរជាដើម ។ ក្នុងករណីផ្សេងទៀត អ្នកស្គាល់គ្នា មិត្តភក្តិ និងសមាជិកគ្រួសារ បានលក់ជនរងគ្រោះ ឬទទួលប្រាក់ចំពោះការផ្តល់ជំនួយក្នុងការបោកប្រាស់ជនរងគ្រោះ ។ កុមារ តូចៗភាគច្រើនជាកុមារី ជារឿយៗត្រូវបានឪពុកម្តាយទីទ័លក្របើប្រើប្រាស់ជាវត្ថុបញ្ចាំដើម្បីសងបំណុល ។ កុមារត្រូវទទួលខុសត្រូវសងបំណុល និងការប្រាក់កម្ចី ។ របាយការណ៍ឆ្នាំ២០០៧ របស់អង្គការ ទេសន្តរប្រវេសន៍អន្តរជាតិបានថ្លែងថាកុមារបម្រើតាមផ្ទះ ជាពិសេសកុមារដែលត្រូវបានប្រើប្រាស់ជាវត្ថុបញ្ចាំ ឬ ដាក់ជាចំណងបំណុលកាន់តែងាយទទួលរងការជួញដូរ និងធ្លាក់ខ្លួនចូលទៅក្នុងសកម្មភាពអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទ ។

ច្បាប់តម្រូវអោយផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ ទៅ២០ឆ្នាំ ចំពោះជនណាដែលត្រូវជាប់ទោសពីបទលក់-ទិញ ឬដោះដូរអនីតិជនអាយុក្រោម ១៨ឆ្នាំ ។ ទណ្ឌកម្មត្រូវជាប់ពន្ធនាគាររយៈពេល១៥ឆ្នាំ ចំពោះការជួញដូរបុគ្គលអាយុ១៨ឆ្នាំ ឬលើសនេះ ។ យោងតាមនាយកដ្ឋានប្រឆាំងនឹងការជួញដូរមនុស្ស និងការពារអនីតិជនរបស់នគរបាលជាតិ នគរបាលបានស៊ើបអង្កេតការជួញដូរមនុស្សចំនួន ៣៨ករណីនៅអំឡុងឆ្នាំនេះ ។ ការស៊ើបអង្កេតបាននាំអោយមានការចាប់ខ្លួនជនល្មើសចំនួន ៦៣នាក់ ។ ទោះជាយ៉ាងនេះ អង្គការមិនមែនរដ្ឋាភិបាលបានបន្តរាយការណ៍អំពីសមត្ថភាពនៅមានកម្រិត និងកង្វះធនធាន សម្រាប់អនុវត្តច្បាប់ និងការខ្វះមន្ត្រីរដ្ឋាភិបាលដើម្បីចាត់វិធានការលើមុខសញ្ញាជួញដូរមនុស្ស ។

ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌ មានទំនួលខុសត្រូវចម្បងដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។ រដ្ឋាភិបាលបានបញ្ចូលក្រុមការងារថ្នាក់ជាតិរបស់ខ្លួនជាមួយស្ថាប័នត្រួតពិនិត្យជាន់ខ្ពស់មួយ ដើម្បីបង្កើតគណ:កម្មាធិការថ្នាក់ជាតិតែមួយ ដែលជាស្ថាប័នសម្របសម្រួលអន្តរក្រសួងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។ មាននាយកដ្ឋានប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការពារអនីតិជន នៅក្នុងនគរបាលជាតិ និងផ្នែកជំនាញប្រយុទ្ធប្រឆាំងនឹងការជួញដូរក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃនៅគ្រប់ខេត្តក្រុងទាំងអស់ ។ ទោះបីជារដ្ឋាភិបាលបានចាប់ខ្លួន និងកាត់ទោសអ្នកជួញដូរមនុស្ស និងបន្តការគាំទ្ររបស់ខ្លួនចំពោះ កម្មវិធីទប់ស្កាត់ និងការពារតាមរយ:កិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេសនិងក្នុងស្រុក ព្រមទាំងអង្គការអន្តរជាតិយ៉ាងណាក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស របស់រដ្ឋាភិបាលនៅតែបន្តជួបឧបសគ្គដោយសារអំពើពុករលួយ និងប្រព័ន្ធយុត្តិធម៌ទន់ខ្សោយដែរ ។ អ្នកសង្កេត ការណ៍អំពីការជួញដូរមួយចំនួននៅក្នុងប្រទេស មានជំនឿថាមន្ត្រីពង្រឹងច្បាប់ មន្ត្រីតុលាការ និងមន្ត្រីរដ្ឋាភិបាល មួយចំនួនបានទទួលសំណូកដែលសម្រួលដល់ការការជួញដូរផ្លូវភេទ និងការជួញដូរមនុស្ស ។

នៅខែមិនា តុលាការកំពូលបានតំកល់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍កាលពីខែសីហា ដែលបន្ថយទោសជាប់ពន្ធនាគាររបស់ជនល្មើសរួមភេទជាមួយកុមារជនជាតិបែកហ្ស៊ីឈ្មោះPhilippe Dessart ពី ១៨ឆ្នាំមកត្រឹម ៣ឆ្នាំស្របតាមច្បាប់ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សថ្មី ទោះបីជាជនល្មើស Dessart បានប្រព្រឹត្តបទឧក្រឹដ្ឋរំលោភបំពានកុមារកាលពីឆ្នាំ២០០៦ ក្តី ។ យោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយបានអោយដឹងថា ជនល្មើស Dessart បានបង់សំណងដល់ជនរងគ្រោះ ហើយក្រោយមកទៀតជនរងគ្រោះបានបដិសេធមេធាវីរបស់អង្គការមិនមែនរដ្ឋាភិបាលនោះ ។ នៅខែមេសា ជនល្មើស Dessart ត្រូវបានដោះលែង ក្រោយពីបានជាប់ពន្ធនាគាររយ:ពេលបីឆ្នាំ ហើយក្រោយមកទៀតបានផ្លាស់មករស់នៅជាមួយគ្រួសាររបស់ជនរងគ្រោះ និងរៀបការជាមួយម្តាយជនរងគ្រោះ ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានអំពាវនាវអោយរដ្ឋាភិបាលបណ្តេញលោក Dessart ចេញពីប្រទេសដែលច្បាប់អនុញ្ញាតអោយធ្វើដូច្នេះ ក្នុងករណីទោសព្រហ្មទណ្ឌ ។ នៅថ្ងៃទី២៣ ខែកញ្ញា រដ្ឋាភិបាលបានអះអាង ថាបានចាប់បញ្ជូនលោក Dessart ចេញពីប្រទេស កាលពីសប្តាហ៍កន្លងទៅរួចរាល់ហើយ ។

ក្រសួងមហាផ្ទៃបានរាយការណ៍អំពីការកាត់ទោសលើបណ្តឹងជួញដូរមនុស្សចំនួនពីរករណី។ របាយការណ៍ដែលគ្មានការអះអាងរបស់តុលាការក្រុងភ្នំពេញ បានលើកឡើងថា មានការកាត់ទោសចំនួន១០ករណីចំពោះជនល្មើសជួញដូរមនុស្សនៅអំឡុងឆ្នាំនេះ ។ នគរបាល មន្ត្រីតុលាការ និងចៅក្រម ជារឿយៗ មិនបានបំបែកជនរងគ្រោះពីជនល្មើសឡើយនៅអំឡុងពេលបង្ក្រាប ចាប់ខ្លួន និងជំនុំជម្រះក្តី ។ ក្នុងករណីខ្លះ មន្ត្រីបានប្រព្រឹត្តមិនគប្បីចំពោះជនរងគ្រោះ ។

នៅខែកញ្ញា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានអនុម័តគោលនយោបាយស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយការជួញដូរ និងកំណត់បទដ្ឋានអប្បបរមាថ្នាក់ជាតិមួយផ្សេងសម្រាប់ការគាំពារជនរងគ្រោះពីការជួញដូរ ។ អង្គការមិនមែនរដ្ឋាភិបាលនានានៅតែបន្តផ្តល់ជំនួយភាគច្រើនបំផុតដល់ជនរងគ្រោះ ។ រដ្ឋាភិបាលបានចូលរួមក្នុងនាមជាដៃគូប្រកបដោយសុឆន្ទៈ នៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះមួយចំនួន ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការចូលរួមចំណែករបស់រដ្ឋាភិបាល ត្រូវជួបឧបសគ្គជាច្រើនដោយសារធនធានមានកម្រិត ។ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់សេវាពិនិត្យជនរងគ្រោះដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារការជួញដូរ។ ជនរងគ្រោះខ្លះ ត្រូវបានលើកទឹកចិត្តដោយអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងមហាផ្ទៃអោយដាក់ ពាក្យបណ្តឹងប្រឆាំងនឹងជនល្មើស ប៉ុន្តែទោះជាយ៉ាងនេះកិច្ចការពារជនរងគ្រោះគឺជាបញ្ហាមួយ ហើយត្រូវបានដឹងថាជនរងគ្រោះមួយចំនួនបានទទួលរងការបំភិតបំភ័យអោយបោះបង់រឿងក្តីរបស់ខ្លួន ។ ការរើសអើងពីសង្គមចំពោះស្ត្រីដែលធ្វើការជាស្ត្រីពេស្យាជាជនរងគ្រោះនៃការបៀតបៀនផ្លូវភេទ ឬជាជនរងគ្រោះនៃការជួញដូរផ្លូវភេទ ធ្វើអោយជនរងគ្រោះមានការលំបាកនឹងធ្វើសមាហរណកម្មទៅក្នុងគ្រួសារ សហគមន៍ និងសង្គមវិញ ។

ច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សពុំមានចែងបទប្បញ្ញត្តិការពារជនរងគ្រោះបរទេស ពីការចោទប្រកាន់ក្រោមច្បាប់អន្តោប្រវេសន៍ឡើយ ប៉ុន្តែ នៅអំឡុងឆ្នាំនេះ ពុំមានរបាយការណ៍អំពីករណីជនរងគ្រោះពីការជួញដូរមនុស្សដែលត្រូវចាត់ទុកជាជនអន្តោប្រវេសន៍ខុសច្បាប់ឡើយ ។ ជាញឹកញាប់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលធ្វើការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ បានធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសថៃ វៀតណាម និងម៉ាឡេស៊ី នូវជនរងគ្រោះជាកុមារ និងមនុស្សពេញវ័យចំនួន៩៩២នាក់ ព្រមទាំងអ្នកដទៃទៀតដែលងាយក្លាយជាជនរងគ្រោះ និងបានធ្វើសមាហរណកម្មអ្នកទាំងនោះទៅក្នុងក្រុមគ្រួសារវិញ ។

ទាំងរដ្ឋាភិបាល និងម្ចាស់ជំនួយអន្តរជាតិ មានកម្មវិធីផ្សេងៗដើម្បីទប់ស្កាត់ពលកម្មកុមារ ឬរំដោះកុមារចេញពីពលកម្ម ។ ប្រទេសកម្ពុជា ជាប្រទេសហត្ថលេខីនៃគំនិតផ្តួចផ្តើមការសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីទន្លេមេគង្គប្រឆាំង នឹងការជួញដូរមនុស្សដែលមានសកម្មភាពធានាអោយមានកិច្ចការពារផ្នែកច្បាប់ សង្គម និងសហគមន៍ដល់ជនរង គ្រោះដោយសារការជួញដូរ ពង្រឹងសមត្ថភាពពង្រឹងច្បាប់ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងកសាង ការឆ្លើយតបដ៏ទូលំទូលាយទាក់ទងនឹងក្រសួងដែលពាក់ព័ន្ធទាំងអស់ ។ ក្រសួងមួយចំនួនរួមទាំងក្រសួងកិច្ចការនារី និងក្រសួងទេសចរណ៍ជាដើម មានគំនិតផ្តួចផ្តើមប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សដើម្បីកាត់បន្ថយពលកម្ម កុមារ ។ ម្ចាស់ជំនួយនានាបានគាំទ្រកម្មវិធីប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ ដែលអនុវត្តដោយអង្គការពលកម្ម អន្តរជាតិ និងអង្គការអប់រំពិភពលោក ក្នុងចំណោមអង្គការ ដទៃទៀត ។

ក្រសួងសង្គមកិច្ចការ អតីតយុទ្ធជន និងយុវនីតិសម្បទាបានធ្វើការជាមួយមូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីកុមារ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាច្រើនដើម្បីគ្រប់គ្រងបណ្តាញតាមសហគមន៍ ទប់ស្កាត់ការជួញដូរមនុស្ស ។

របាយការណ៍អំពីការជួញដូរមនុស្សប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកមាននៅក្នុង វែបសាយត៍ ៖ www.state.gov/g/tip

**ជនពិការ**

នៅថ្ងៃទី២៩ ខែឧសភា រដ្ឋសភាបានអនុម័តច្បាប់ស្តីពីកិច្ចការពារ និងលើកស្ទួយសិទ្ធិជនពិការ ។ ច្បាប់ថ្មីនេះហាមឃាត់ការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ ។ ច្បាប់នេះបញ្ចូលជនមានជំងឺផ្លូវកសតិបញ្ញាទៅក្នុងនិយមន័យជនពិការ ហើយតម្រូវអោយអគារ និងសេវារដ្ឋាភិបាលទាំងអស់អាចប្រើប្រាស់បានដោយជនពិការ ។ នៅដំណាច់ឆ្នាំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាកំពុងតាក់តែងសេចក្តីព្រាងអនុក្រឹត្យដើម្បីគាំទ្រច្បាប់នេះ ដែលបានប្រកាសអោយប្រើដោយព្រះមហាក្សត្រ កាលពីខែកក្កដាកន្លងទៅនេះ ។

កម្មវិធីដែលអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗបាននាំមកនូវការកែលម្អជាច្រើននៅក្នុងប្រព្រឹត្តកម្ម និងការស្តារនីតិសម្បទារបស់ជនពិការ ប៉ុន្តែអ្នកទាំងនោះបានជួបប្រទះការរើសអើងជាច្រើនពីសង្គម ជាពិសេសក្នុងការទទួលការងារជំនាញ ។

ពុំមានការកម្រិតតាមច្បាប់ណាមួយចំពោះសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមកាព្វកិច្ចពលរដ្ឋឡើយ ប៉ុន្តែរដ្ឋាភិបាលមិនបានធ្វើកិច្ចខិតខំប្រឹងប្រែងរួមគ្នាណាមួយ ដើម្បីជួយដល់ជនពិការអោយក្លាយជាជនចូលរួមកាន់តែច្រើនក្នុងនាមជាពលរដ្ឋឡើយ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកទទួលខុសត្រូវរៀបចំគោលនយោបាយដើម្បីការពារសិទ្ធិជនពិការ ព្រមទាំងការស្តារនីតិសម្បទា និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ជនពិការ ។

**សញ្ជាតិ/ពូជសាសន៍/ជាតិពន្ធុភាគតិច**

សិទ្ធិរបស់ជនជាតិភាគតិច តាមច្បាប់សញ្ជាតិ មិនមានចែងច្បាស់លាស់នោះទេ ការការពារតាមរដ្ឋធម្មនុញ្ញ មានផ្តល់តែចំពោះ “ពលរដ្ឋខ្មែរ”  ប៉ុណ្ណោះ ។ ពលរដ្ឋជាជនជាតិដើមកំណើតចិននិងវៀតណាម មានចំនួនច្រើនជាងគេនៅក្នុងជាតិពន្ធុភាគតិច ។ ប្រជាពលរដ្ឋដើមកំណើតចិនត្រូវបានទទួលយកនៅក្នុងសង្គម ប៉ុន្តែការស្អប់ខ្ពើមនៅតែមានជាបន្តចំពោះជនជាតិដើមកំណើតវៀតណាម ដែលត្រូវបានពិនិត្យឃើញថា ជាការគម្រាមកំហែងចំពោះប្រទេសជាតិ និងវប្បធម៌ ។ ក្រុមមួយចំនួនរួមទាំងក្រុមនយោបាយផងដែរ នៅតែបន្តធ្វើសេចក្តីថ្លែងការណ៍

ខ្លាំងៗ ប្រឆាំងនឹងជនជាតិវៀតណាម ។ ពួកអ្នកទាំងនោះបានតវ៉ាអំពីការគ្រប់គ្រងនយោបាយទៅលើគណបក្សប្រជាជន កម្ពុជា ដោយរដ្ឋាភិបាលវៀតណាម ការទន្ទ្រានព្រំដែន និងបញ្ហាដទៃទៀត ដែលចាត់ទុកថា ជនជាតិវៀតណាម យ៉ាងហោចក៏ទទួលខុសត្រូវមួយចំណែកផងដែរ ។

**ជនជាតដើម**

ជារឿយៗ រដ្ឋាភិបាលព្រងើយកន្តើយចំពោះកិច្ចខិតខំប្រឹងប្រែងដោយសហគមន៍ជនជាតិដើមដើម្បីការពារដីធ្លីពីដូនតា និងធនធានធម្មជាតិរបស់ខ្លួន ។ ទោះបីជាច្បាប់ភូមិបាលឆ្នាំ២០០១ តម្រូវអោយមានការចុះបញ្ជីដីធ្លីរួមរបស់ជនជាតិដើមក៏ដោយ ក៏មានការអនុវត្តតិចតួចតែប៉ុណ្ណោះក្នុងការចុះកម្មសិទ្ធិដីធ្លីរួម ។ អង្គការមិនមែន រដ្ឋាភិបាលជាច្រើន បានអំពាវនាវអោយផ្អាក ការលក់ដី និងការធ្វើសម្បទានដី ដែលប៉ះពាល់សហគមន៍ ជនជាតិដើម ។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុក នានាមានភាពសកម្មក្នុងការអប់រំសហគមន៍ ជនជាតិដើមអំពីដំណើរការចុះបញ្ជីដីធ្លី និងផ្តល់តំណាងផ្នែកច្បាប់នៅក្នុងវិវាទផ្សេងៗ ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍អំពីការបាត់បងដីកសិកម្ម និងរបរចិញ្ចឹមជីវិត ដោយសារកំណើននៃការផ្តល់ដីសម្បទាន សេដ្ឋកិច្ចនៅលើជនជាតិដើម។ សមាជិកសកម្មផ្នែកសិទ្ធិជនជាតិដើមរបស់អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាលពីខែធ្នូថា ខ្លួនបានកត់ត្រាវិវាទដីធ្លីចំនួន១៤ ទាក់ទងនឹងក្រុមភាគតិចនៅអំឡុងឆ្នាំនេះ ដែលកើនឡើងពីចំនួន ៧ករណីនៅឆ្នាំ២០០៨ ។

ក្រុមហ៊ុន ខូវ ជូលីគ្រុប បានបន្តកាប់ឆ្ការដីនៅស្រុកពេជ្រដាខេត្តមណ្ឌលគិរី ដើម្បីធ្វើចំការកៅស៊ូ ដោយបានធ្វើកិច្ចការនេះ មុនពេលដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអនុញ្ញាតផ្តល់ដីសម្បទានសេដ្ឋកិច្ច សម្រាប់ធ្វើចំការនោះទៅទៀត ។ អ្នកភូមិជនជាតិភ្នងបានអះអាងថាជាម្ចាស់កម្មសិទ្ធិលើផ្នែកខ្លះនៃដីនោះ ហើយ ទាមទារអោយក្រុមហ៊ុនចាកចេញ ឬផ្តល់សំណង ។ ដៃគូរបស់ក្រុមហ៊ុន ខូវ ជូលីគ្រុប ដែលជាសាជីវកម្មចំការ កៅស៊ូបរទេស ហៅថា Socfin បានគ្រប់គ្រងលើចំការនោះ ហើយនៅដំណាច់ឆ្នាំនេះ តាមរបាយការណ៍កំពុងធ្វើការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមរបស់គម្រោងនេះ ។ អង្គការមិនមែនរដ្ឋាភិបាលមួយបានរកឃើញថា គម្រោងនេះនាំអោយមានការបាត់បង់ដីកសិកម្មជាលក្ខណៈប្រពៃណី ការផ្គត់ផ្គង់ទឹក និងព្រៃអារក្ស ហើយរារាំងការធ្វើដំណើរទៅសាលារៀនទៀតផង ។

ពុំមានការវិវឌ្ឍនៅក្នុងករណីវិវាទដីធ្លីនៅខែមេសា ឆ្នាំ២០០៨ ដែលប៉ះពាល់សមាជិកសហគមន៍ជនជាតិដើមនៅភូមិកក់ ឃុំតាលាវ ស្រុកអណ្តូងមាស ខេត្តរតនៈគិរីឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលនានា បានថ្លែងថារដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចទំហំ ១៧.០០០អេឃើ គ្របដណ្តប់លើដីមានវិវាទទៅអោយក្រុមហ៊ុនសម្រាប់ធ្វើចំការកៅស៊ូនៅឆ្នាំ២០០៦ ។ អង្គការមិនមែនរដ្ឋាភិបាលនានា បានរាយការណ៍ថា ភាគច្រើននៃតំបន់

នៅក្នុងដីសម្បទាននេះ អាចចុះបញ្ជីជាដីសហគមន៍ជនជាតិដើម ស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ បាន ។ សមាជិកសហគមន៍រងគ្រោះ មិនបានដឹងអំពីការធ្វើសម្បទានដីនោះឡើយ រហូតដល់ដីត្រូវបានកាប់ឆ្ការ ។

ករណីនៅខែឧសភា ឆ្នាំ២០០៨ ក្នុងខេត្តរតនៈគិរីដែលតាមរបាយការណ៍បានអោយដឹងថា អភិបាលខេត្តបានជួលដីដែលមានបញ្ចូលដីរបស់ជនជាតិដើម ដោយមិនបានពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមឡើយ ។ ក្រុមហ៊ុន វិនិយោគ BVB និងសមាជិកនៃសហគមន៍រងគ្រោះមួយ នៅឃុំយក្សឡោម បានយល់ព្រមចុះកិច្ចព្រមព្រៀងទៅវិញ ទៅមកមួយសម្រាប់ប្រើប្រាស់ដីនៅនេះខែសីហា ឆ្នាំ២០០៨ ។ កិច្ចព្រមព្រៀងនេះ អនុញ្ញាតអោយអ្នកភូមិបន្ត ធ្វើកសិកម្មនៅលើដីដែលបានកាប់ឆ្ការដោយស្របពេលជាមួយគ្នានេះ អភិរក្សដីព្រៃនៅក្នុងទីតាំងទំហំ ១.២៥០ អេយឹសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ ។ អ្នកភូមិនៅសហគមន៍ទីពីរ ប៉ាចុន បានបន្តរាយការណ៍ពីការទន្ទ្រានកាន់កាប់ពីសំណាក់ក្រុមហ៊ុនវិនិយោគ BVB និងឃុំយក្សឡោម ។

ពុំមានការវិវឌ្ឍន៍នៅករណីដីធ្លីឆ្នាំ២០០៧ អំពីមន្ត្រីខេត្តរតនៈគិរី រារាំងអ្នកភូមិជនជាតិដើមទំពួន មិនអោយបញ្ចុះសពនៅលើដីដែលបានត្រូវបានចាត់ទុកជាដីបញ្ចុះសពតាមប្រពៃណីរបស់ខ្លួន ចាប់តាំងពីឆ្នាំ១៩៧៩ ឬករណីរបស់ក្រុមគ្រួសារជនជាតិដើមចារ៉ាយ ដែលទាមទារអោយដកមន្ត្រីដែលត្រូវបានចោទប្រកាន់ថាមានការពាក់ព័ន្ធក្នុងការលក់ដោយក្លែងបន្លំនូវដីទំហំជាង ៣.០០០អេយឹ នៃដីរួមរបស់អ្នកភូមិទាំងនោះឡើយ ។

## ការរំលោភបំពានផ្នែកសង្គម ការរើសអើង និងអំពើហឹង្សាដោយផ្អែកលើចំណង់ផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ

គ្មានច្បាប់ដែលដាក់ទោសព្រហ្មទណ្ឌចំពោះការរួមភេទដូចគ្នាទេ ហើយក៏គ្មានការរើសអើងជាផ្លូវការចំពោះ សហគមន៍ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស បុគ្គលស្រឡាញ់ទាំងពីរភេទ និងបុគ្គលប្តូរភេទ (LGBT) ទេ ទោះបីជាការរើសអើង និងនិយមទម្លាប់មួយចំនួនផ្នែកសង្គមនៅតែមាន ជាពិសេសនៅតំបន់ជនបទ សហគមន៍ LGBT ឃើញមានយ៉ាងច្បាស់ និងមានភាពសកម្មនៅតាមតំបន់ទីក្រុង ជាពិសេសនៅទីក្រុងភ្នំពេញ និង ខេត្តសៀមរាប ។ មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនតូចដែលប្តេជ្ញាចិត្តធ្វើការបម្រើតម្រូវការរបស់ក្រុមបុគ្គល LGBT ដោយផ្តោតជាចម្បងទៅលើការផ្តល់តំហែទាំសុខភាព ។ កាលពីខែឧសភា មានក្រុមហ៊ុន និងអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួនបានរៀបចំពិធីបុណ្យមោទនភាពទីក្រុងភ្នំពេញប្រចាំឆ្នាំលើកទី៥ ជាព្រឹត្តិការណ៍ ដែលមានរយៈពេលមួយសប្តាហ៍ ដែលបង្ហាញអំពីសហគមន៍ LGBT ។

ពុំមានរបាយការណ៍អំពីការរើសអើងដោយសារអត្តសញ្ញាណផ្លូវភេទនៅក្នុងការងារ ភាពគ្មានប្រទេស ឬលទ្ធភាពទទួល ការអប់រំ ឬតំហែទាំសុខភាពឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ការរួមភេទដូចគ្នាជាទូទៅត្រូវបាន

គេមានការភ័យខ្លាច និងមានការសង្ស័យទៅលើ ហើយមានក្រុមគាំទ្រមួយចំនួនតូចប៉ុណ្ណោះ ដែលអាចរាយការណ៍អំពីករណីទាំងនេះ ។

មានរបាយការណ៍មួយចំនួនតូច ដែលបុគ្គលឯកជនបដិសេធមិនព្រមផ្តល់ការងារ ឬជួលអចលនទ្រព្យទៅអោយបុគ្គលដោយសារបញ្ហាអត្តសញ្ញាណផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ ។

## អំពើហិង្សា ឬការរើសអើងក្នុងសង្គម

គ្មានការរើសអើងជាផ្លូវការចំពោះអ្នកដែលឆ្លងមេរោគអេដស៍/ជំងឺអេដស៍នោះឡើយ ។ ការរើងអើងក្នុងសង្គម ចំពោះអ្នកឆ្លងមេរោគអេដស៍/ជំងឺអេដស៍ នៅតែជាបញ្ហានៅឡើយនៅតំបន់ជនបទ ប៉ុន្តែការរើសអើងត្រូវបានកាត់បន្ថយតាមរយៈកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍នានា ។

## ផ្នែកទី៧ ៖ សិទ្ធិកម្មករ

## ក. សិទ្ធិបង្កើតអង្គការ/សមាគម

ច្បាប់ការងារឆ្នាំ១៩៩៧ អនុញ្ញាតអោយកម្មករផ្នែកឯកជនបង្កើត និងចូលរួមសហជីពតាមការជ្រើសរើសរបស់ខ្លួនផ្ទាល់ ដោយពុំចាំបាច់មានការអនុញ្ញាតជាមុនឡើយ ។ ទោះបីមានភាពប្រសើរឡើងខ្លះៗក៏ដោយ ក៏ការអនុវត្តច្បាប់ការងារនៅមានលក្ខណៈទន់ខ្សោយនៅឡើយ ។ សមាជិកភាពនៅក្នុងសហជីពកម្មករ ឬសមាគមនិយោជិតមិនមែនជាកាតព្វកិច្ចឡើយ ហើយកម្មករមានសេរីភាពដកខ្លួនចេញពីអង្គភាពទាំងនេះបាន ទោះបីមានសហជីពមួយចំនួនតូចប៉ុនប៉ងបំភិតបំភ័យកម្មករដែលចង់ដកខ្លួនក៏ដោយ។ សហជីពអាចចងសម្ព័ន្ធភាពដោយសេរី ប៉ុន្តែច្បាប់មិនបាននិយាយច្បាស់លាស់អំពី សិទ្ធិចងសម្ព័ន្ធជាលក្ខណៈអន្តរជាតិឡើយ ។ ទោះបីជាច្បាប់នេះអនុវត្តចំពោះកម្មករបរទេសក៏ដោយ ក៏ច្បាប់នេះមិនអនុវត្តចំពោះ មន្ត្រីស៊ីវិល ដូចជាគ្រូបង្រៀន ចៅក្រម និងបុគ្គលិកយោធា ឬចំពោះកម្មករដែលស្ថិតនៅក្នុងផ្នែកក្រៅផ្លូវការឡើយ ។ បុគ្គលិកនៅក្នុងឧស្សាហកម្មដឹកជញ្ជូនផ្លូវអាកាស និងផ្លូវទឹក គ្មានសិទ្ធិទទួលបានកិច្ចការពារពេញលេញពីច្បាប់នេះឡើយ ប៉ុន្តែមានសេរីភាពក្នុងការបង្កើតសហជីពបាន ។

កម្លាំងពលកម្មតិចជាង៣,៥ភាគរយ ដែលប៉ាន់ប្រមាណថាមានចំនួន៨,៨លាននាក់ ត្រូវបានរៀបចំបង្កើតឡើងជាសហជីព ។ សហជីពផ្តុំនៅក្នុងឧស្សាហកម្មសម្លៀកបំពាក់ និងទ្រនាប់ជើង ដែលមានប្រមាណជា៧០ ទៅ៨០ភាគរយ នៃកម្មករចំនួន ប្រហែល ២៧៨.៤០០នាក់ ជាសមាជិកសហជីព ។ សម្ព័ន្ធកម្មករទេសចរណ៍ និងសេវាកម្មកម្ពុជា បានរាយការណ៍ថា ខ្លួនតំណាងអោយអ្នកបម្រើការតាមសណ្ឋាគារ កាស៊ីណូ និងអាកាស

យានដ្ឋាន ប្រមាណជា ៣.៧៥០នាក់ ។ មានសហជីពលំដាប់រោងចក្រដែលបានចុះបញ្ជីជាង ១.៦០០ និងសម្ព័ន្ធ និងសមាគម កម្មករ ៤៨ ដែលភាគច្រើនមានទំនាក់ទំនងជាមួយរដ្ឋាភិបាល និងចំនួន៥ទៀត ឯករាជ្យ ។

សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA) ដែលបានចុះបញ្ជីជា “សមាគម” មួយ ដោយសារមានការហាមឃាត់ចំពោះសហជីពផ្នែកសាធារណៈនោះ តំណាងអោយគ្រូបង្រៀនចំនួន ៩.២៦៣នាក់ ក្នុងចំណោមគ្រូបង្រៀនក្នុងប្រទេសចំនួន ៩៨.៦៩០នាក់ ។ សំណើសុំដង្ហែរក្បួន (បាតុកម្ម) និង ការតវ៉ាដទៃទៀតរបស់ CITA ជាញឹកញាប់ត្រូវបានបដិសេធ ទោះបីជាយ៉ាងណាក៏ដោយក៏សហជីពនេះរាយការណ៍ថា គ្មានការជ្រៀតជ្រែកដោយ ផ្ទាល់របស់រដ្ឋាភិបាលនៅក្នុងសកម្មភាពប្រចាំថ្ងៃឡើយ ។

សមាគមផ្នែកសាធារណៈ និងសមាគមរាជការស៊ីវិលឯករាជ្យ កម្ពុជា (CICA) តំណាងអោយមន្ត្រីរាជការមកពីក្រសួង មន្ទីរខេត្ត និងក្រុមប្រឹក្សាឃុំ-សង្កាត់ ចំនួន១.១២៩នាក់ ក្នុងចំណោម មន្ត្រីរាជការស៊ីវិលចំនួនប្រមាណជា ១៨៤.០០០នាក់ នៅទូទាំងប្រទេស ។

សមាជិក CITA ខ្លះមានការភ័យខ្លាចថា ការមានទំនាក់ទំនងជាមួយសមាគមគ្រូបង្រៀន អាចរារាំងដល់ឱកាសឡើងឋានៈការងាររបស់ខ្លួន ។ មេដឹកនាំរបស់ CICA បានចោទប្រកាន់ថា ការភ័យខ្លាចចំពោះការបៀតបៀន ឬការទម្លាក់មុខតំណែង គឺជាកត្តារារាំងមន្ត្រីរាជការស៊ីវិលមិនអោយចូលរួមក្នុងសមាគម ។

គ្មានការវិវឌ្ឍន៍ក្នុងករណីធ្វើឃាតមេដឹកនាំសហជីព ឈ្មោះ ហ៊ី វុទ្ធី ឡើយ កាលពីឆ្នាំ ២០០៧ ។ ការស៊ើបអង្កេតនៅតែបើកចំហនៅដំណាច់ឆ្នាំនេះ ។

នៅថ្ងៃទី១៨ ខែកុម្ភៈ តុលាការឧទ្ធរណ៍ បានតម្កល់ទុកសាលក្រម ឆ្នាំ ២០០៥ កាត់ទោសលើ ថាច់ សាវេត ចំពោះការធ្វើឃាតមេដឹកនាំសហជីព ឈ្មោះ រស់ សុវណ្ណារេត នៅឆ្នាំ២០០៤ ។ លោក ថាច់ សាវេត បានប្តឹងឧទ្ធរណ៍ទៅ កាន់តុលាការកំពូល (សូមមើលផ្នែក ១.ង) ។

នៅថ្ងៃទី១៧ ខែសីហា តុលាការឧទ្ធរណ៍បានសម្រេចអោយធ្វើការស៊ើបអង្កេតឡើងវិញចំពោះរឿងក្តីធ្វើឃាតកាលពីឆ្នាំ២០០៤ លើមេដឹកនាំសហជីពឈ្មោះ ជា វិជ្ជា ។ នៅខែធ្នូ ឆ្នាំ២០០៨ តុលាការកំពូល បានដោះលែងបណ្តោះអាសន្ន ជនសង្ស័យទាំងពីរនាក់ ដែលត្រូវបានកាត់ទោសពីបទព្រហ្មទណ្ឌ (សូមមើលផ្នែក ១.ង) ។

ច្បាប់ការងារមានចែងអំពីសិទ្ធិធ្វើកូដកម្ម និងការពារកូដករពីការវាយតប ។ ច្បាប់ចែងថា កូដកម្មអាចប្រព្រឹត្តទៅបានតែក្នុងករណីក្រោយពីបានបំពេញលក្ខខណ្ឌតម្រូវមួយចំនួនប៉ុណ្ណោះ ដូចការដែលវិធីសាស្ត្រដោះស្រាយវិវាទដទៃទៀតមិនបានទទួលជោគជ័យ (ដូចជាការចរចារ ការផ្សះផ្សា ឬការដោះស្រាយ ដោយអាជ្ញាកណ្តាលជាដើម) ការបោះឆ្នោតដោយសម្ងាត់ជ្រើសរើស សមាជិកភាពសហជីព និងការជូនដំណឹង ជាមុនរយៈពេល

ប្រាំពីរ ថ្ងៃទៅកាន់និយោជក ព្រមទាំងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) ។ ពុំមានច្បាប់ដែល ហាមឃាត់ចំពោះការធ្វើកូដកម្មដោយមន្ត្រីរាជការស៊ីវិល អ្នកបម្រើការនៅផ្នែកសាធារណៈ ឬកម្មករក្នុងសេវាកម្ម សំខាន់ៗឡើយ ។

MOLVT បានរាយការណ៍ថាមានកូដកម្មចំនួន ៩០ បានកើតមានឡើងនៅតំបន់ក្រុងភ្នំពេញនៅអំឡុងឆ្នាំនេះ ។ សមាគមរោងចក្រកាត់ដេរកម្ពុជា បានរាយការណ៍ថាមានកូដកម្មចំនួន ៥៧ ដងនៅទូទាំងប្រទេស ។ អ្នកសង្កេតការណ៍អន្តរជាតិ និយោជក និងមេដឹកនាំសហជីពជាច្រើនបានយល់ស្របគ្នាថាស្ទើរគ្រប់កូដកម្មទាំងអស់ មិនបានបំពេញលក្ខខណ្ឌច្បាប់មុនពេលធ្វើកូដកម្មឡើយ ។ ទោះបីមានសហជីពខ្លះបាន តវ៉ាចំពោះការខ្វះការចូលរួមរបស់ MOLVT ក៏ MOLVT បានដោះស្រាយវិវាទចំនួនប្រមាណជា ៥០ភាគរយកន្លងមកដែរ ។

រដ្ឋាភិបាលបានអនុញ្ញាតអោយកូដកម្មភាគច្រើនបំផុតធ្វើឡើងនៅតាមរោងចក្រ ប៉ុន្តែបដិសេធសំណើរបស់កម្មករសុំដើរជាក្បួនតវ៉ានៅក្រៅតំបន់រោងចក្រ ។ អន្តរាគមន៍របស់នគរបាលនៅក្នុងកូដកម្ម មានលក្ខណៈតិចតួចបំផុត និងមានការកម្រិតព្រំដែន ទោះបីជាក្នុងករណីមានការខូចខាតទ្រព្យសម្បត្តិកើតមានឡើងក៏ដោយ ។

នៅថ្ងៃទី២២ ខែមករា មានកម្មករពីរនាក់ រងរបួសនៅអំឡុងពេលកូដកម្មមួយ ដោយកម្មករជាង ៣០០០នាក់របស់រោងចក្រ Yung Wah នៅក្នុងខេត្តកណ្តាល ។ បាតុកម្មនេះកើតឡើងក្រោយពីថៅកែរោងចក្រ បានប្រាប់កម្មករថា ពួកគេនឹងមិនបានទទួលប្រាក់រង្វាន់ជាទម្លាប់ចំនួន ២០០.៥០០រៀល (ប្រហែល ៥០ដុល្លារ) សម្រាប់ពិធីបុណ្យចូលឆ្នាំថ្មីឡើយ ។ នាយរងនគរបាលខេត្តកណ្តាលម្នាក់ បានអះអាងថា មន្ត្រីរបស់លោកបានប្រើកម្លាំងបន្តិចបន្តួចបំផុតដើម្បីបង្ក្រាបបាតុករ ។

នៅថ្ងៃទី០៩ ខែកុម្ភៈ មានកម្មករប្រមាណជា ៩៥នាក់ មកពីរោងចក្រ Van Lida នៅក្រុងភ្នំពេញ បានធ្វើកូដកម្មមួយ ព្រមទាំងបានយកគ្រឿងបរិក្ខារមួយចំនួនធ្វើជារបស់ផ្ទាល់ខ្លួន ក្រោយពីបានដឹងថាថៅកែបរទេសបានចាកចេញពីប្រទេសដោយមិនបានបើកប្រាក់ខែអោយពួកគេនោះ ។

នៅថ្ងៃទី២០ ខែឧសភា មានកម្មករជាង១.០០០នាក់ មកពីរោងចក្រ Sangwoo នៅខេត្តកំពង់ស្ពឺ បានប៉ះទង្គិចជាមួយក្រុមនគរបាលនៅអំឡុងពេលធ្វើកូដកម្មមួយដើម្បីតវ៉ាអំពីលក្ខខណ្ឌការងារ ។ នៅថ្ងៃទី២១ ខែឧសភា កូដករ និងក្រុមនគរបាលបានគប់ដុំថ្មដាក់គ្នាទៅវិញទៅមក ព្រមទាំងមានបាញ់កាំភ្លើងផងដែរ ។ ពុំមានរបួសធ្ងន់ធ្ងរកើតមានឡើយ ។

ទោះបីជាមានបទប្បញ្ញត្តិច្បាប់ការពារកូដករពីការវាយតបក៏ដោយ ក៏មានរបាយការណ៍គួរអោយជឿទុកចិត្តថា កម្មករត្រូវបានបណ្តេញពីការងារ ដោយសារមូលហេតុទោសធ្ងន់ធ្ងរ ក្រោយពីបានរៀបចំ ឬចូលរួមកូដកម្ម ។ ទោះបីជាកូដកម្មភាគច្រើនខុសច្បាប់ក៏ដោយ ក៏ការចូលរួមនៅក្នុងកូដកម្មខុសច្បាប់ផ្ទាល់ មិនអាចជាហេតុផល

ដែលអាចទទួលយកបានដោយស្របច្បាប់សម្រាប់ការបណ្តេញកម្មករពីការងារឡើយ ។ ក្នុងករណីមួយចំនួន និយោជកបានគាបសង្កត់អោយកូដករទទួលយកសំណងឬលាលែងពីការងាររបស់ខ្លួន។ មានវិធីសាស្រ្តដោះស្រាយបញ្ហាដែលអាចមានមួយចំនួនទាក់ទងនឹងការបណ្តេញពីការងារដូចពោលមកនេះ ។ ទោះបី ជាយ៉ាងណាក៏ដោយ គ្មានវិធីសាស្រ្តណាមួយមានប្រសិទ្ធិភាពគួរអោយកត់សំគាល់ឡើយ ។ MOLVT អាចចេញ បញ្ជាអោយមានការទទួលកម្មករអោយចូលបម្រើការងារឡើងវិញ ប៉ុន្តែជារឿយៗ បទបញ្ជាទាំងនោះ ញុះញង់ អោយថៅកែរោងចក្រខិតខំគាបសង្កត់កម្មករអោយចុះហត្ថលេខាជាថ្នូរនឹងដំណោះស្រាយមួយ ។ វិវាទរួម ដូចជា ក្នុងករណីមាននិយោជិតច្រើនត្រូវបានបណ្តេញពីការងារ អាចត្រូវបានបញ្ជូនទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីសម្រេច ។ ភាគីទាំងឡាយអាចជ្រើសរើសថាតើសេចក្តីសម្រេចរបស់អាជ្ញាកណ្តាលជាប់កាតព្វកិច្ច ឬមិនជាប់ កាតព្វកិច្ច ។ ប្រសិនបើគ្មានភាគីណាមួយជំទាស់ចំពោះការសម្រេចរបស់អាជ្ញាកណ្តាល នៅក្នុងរយៈពេលប្រាំបីថ្ងៃ នៃការចេញសេចក្តីសម្រេចរបស់អាជ្ញាកណ្តាលទេនោះ សេចក្តីសម្រេចត្រូវភ្ជាប់កាតព្វកិច្ចជាស្វ័យប្រវត្តិ។ វិវាទបុគ្គលអាចត្រូវនាំយកទៅកាន់តុលាការ ទោះបីជាប្រព័ន្ធតុលាការ លម្អៀង ឬគ្មានតម្លាភាពក៏ដោយ ។ សហជីពមួយចំនួនបានទទូចសុំអោយរដ្ឋាភិបាលធ្វើការពង្រីកតួនាទីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបញ្ចូល វិវាទផលប្រយោជន៍បុគ្គល និងរួម ព្រមទាំងជំរុញអោយការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមាន លក្ខណៈភ្ជាប់កាតព្វកិច្ច ។

នៅថ្ងៃទី០១ ខែឧសភា សម្ព័ន្ធសហជីពកម្ពុជា រួមជាមួយសម្ព័ន្ធកម្មករកម្ពុជា បានដឹកនាំការដង្ហែរក្បួនដើម្បីអំពាវនាវអោយមានការបង្កើតតុលាការងារឯករាជ្យនិងឥតលម្អៀង ដូចមានចែងនៅក្នុងច្បាប់ការងារឆ្នាំ១៩៩៧ ។

**ខ. សិទ្ធិរៀបចំអង្គការសមាគម និងអនុសញ្ញារួម** (The right to organize and bargain collectively)

ច្បាប់មានចែងអំពីសិទ្ធិរៀបចំអង្គការសមាគម និងអនុសញ្ញារួម ប៉ុន្តែការពង្រឹងសិទ្ធិទាំងនេះ របស់រដ្ឋាភិបាល មិនមានភាពស៊ីសង្វាក់គ្នាឡើយ ។ អនុសញ្ញារួមបានកើតមានឡើងនៅក្នុងឧស្សាហកម្មកាត់ដេរ និងសណ្ឋាគារ និងជាមួយកម្មករជាប់កិច្ចសន្យានៅអាកាសយានដ្ឋានអន្តរជាតិចំនួនពីរ ។

មានអនុសញ្ញារួមចំនួន ១៣១ ត្រូវបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅអំឡុងឆ្នាំនេះ ។ ទោះជាយ៉ាងនេះក្តី អនុសញ្ញារួមទាំងនេះមិនមែនជាកិច្ចព្រមព្រៀងដែលមានលក្ខណៈទូលំទូលាយឡើយ ប៉ុន្តែ គ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញដែលលើកឡើងត្រឹមតែពីរបីចំណុចអំពីបញ្ហាពាក់ព័ន្ធនឹងប្រាក់ឈ្នួលប៉ុណ្ណោះ ។

មានបទប្បញ្ញត្តិមួយចែងអំពីនីតិវិធីដើម្បីអនុញ្ញាតអោយសហជីពបង្ហាញថា ខ្លួនជាតំណាងកម្មករ ដើម្បីអនុសញ្ញារួម ។ បទប្បបញ្ញត្តិនេះ ក៏មានកំណត់ផងដែរ អំពីលក្ខខណ្ឌតម្រូវចំពោះនិយោជក និងសហជីពពាក់ព័ន្ធនឹងអនុសញ្ញារួមនិងផ្តល់កិច្ចការពារបន្ថែមចំពោះមេដឹកនាំសហជីពពីការបណ្តេញចេញពីការងារ។ ច្បាប់ការងារ

តម្រូវអោយសហជីពកម្មករ និងអង្គការនិយោជក រៀបចំលក្ខខន្តិកៈ និងបញ្ជីឈ្មោះមន្ត្រី តំកល់ទុកនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ទីស្នាក់ការទំនាក់ទំនងការងារទទួលខុសត្រូវសម្របសម្រួលដំណើរការចុះបញ្ជី និងផ្តល់វិញ្ញាបនប័ត្រដល់សហជីពដែលមាន “ភាពជាតំណាងខ្ពស់បំផុត” (Most representative status) ដែលផ្តល់សិទ្ធិអោយ សហជីពមួយធ្វើជាតំណាងកម្មករភាគច្រើនបំផុតនៅក្នុងសហគ្រាសមួយ ដើម្បីតំណាងអោយកម្មករទាំងអស់នៅ ក្នុងគ្រឹះស្ថាននោះ ។ រដ្ឋាភិបាលបានចាប់ផ្តើមពិនិត្យឡើងវិញនូវ ដំណើរ ការផ្តល់វិញ្ញាបនប័ត្ររបស់ខ្លួន ដោយមាន ការគាំទ្រពីសំណាក់អង្គការអន្តរជាតិនានា និងបេសកកម្មការទូត ។ នៅខែមេសា ឆ្នាំ២០០៨ អាជ្ញាធរបាន ចេញសេចក្តីជូនដំណឹងថ្មីស្តីពីភាពជាតំណាងខ្ពស់បំផុត ដោយរៀបរាប់ លម្អិតអំពីនីតិវិធីស្នើសុំ បដិសេធ និងរៀបចំ ការបោះឆ្នោត ។ កត្តានេះនាំអោយមានការកែលម្អគួរអោយកត់ សម្គាល់នៅក្នុងនីតិវិធីភាពជាតំណាងខ្ពស់បំផុត ដូចមានភស្តុតាងបញ្ជាក់ដោយកំណើនការផ្តល់ វិញ្ញាបនប័ត្រ ចំនួន៤០០ ។

ការពង្រឹងសិទ្ធិបង្កើតអង្គការសមាគម និងសេរីភាពរួចផុតពីការរើសអើងប្រឆាំងនឹងសហជីពមិនមានលក្ខណៈ ស៊ីសង្វាក់គ្នាឡើយ ។ អំពើរើសអើងប្រឆាំងនឹងសហជីព ដោយនិយោជក ជារឿយៗ ប្រព្រឹត្តទៅដោយគ្មានការ ផ្តន្ទាទោស ។ ការអនុវត្តសិទ្ធិ ដោយរដ្ឋាភិបាល ត្រូវរំខានដោយកង្វះឆន្ទៈនយោបាយ និងដោយទំនាក់ទំនងហិរញ្ញវត្ថុ និងនយោបាយដ៏ច្របូកច្របល់ក្នុងចំណោមនិយោជក និងមេដឹកនាំសហជីព ។ រដ្ឋាភិបាលក៏ទទួលរងនូវកង្វះធនធាន រួមទាំងការបណ្តុះបណ្តាល អធិការកិច្ចការងារ ដែលមានបទពិសោធន ម្យ៉ាងដោយសារ រដ្ឋាភិបាលមិនបានផ្តល់ប្រាក់បៀវត្សរ៍គ្រប់គ្រាន់ដល់មន្ត្រីផងដែរ ។ ជារឿយៗ ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ បានធ្វើការសម្រេចដោយគាំទ្រនិយោជិត ប៉ុន្តែកម្រប្រើប្រាស់អំណាចស្របច្បាប់របស់ខ្លួន ដើម្បីដាក់ ទណ្ឌកម្មដល់និយោជកដែលរំលោភបញ្ជារបស់ខ្លួនណាស់ ផ្ទុយទៅវិញបែរជាបញ្ជូនករណីជាច្រើនទៅអោយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

មានរបាយការណ៍ដែលអាចជឿទុកចិត្តបាន អំពីការបៀតបៀនសហជីព រួមមានដូចជាការបណ្តេញមេដឹកនាំ សហជីពពីការងារនៅតាមរោងចក្រកាត់ដេរ និងសហគ្រាសដទៃទៀត ។ នៅអំឡុងឆ្នាំនេះ មានមេដឹកនាំសហជីព ប្រមាណជា ៣០នាក់ ត្រូវបានបណ្តេញ ឬព្យួរការងារ ដោយគ្មានមូលហេតុ ។ មេដឹកនាំសហជីពឯករាជ្យ និងប្រឆាំងសំខាន់ៗ ត្រូវបានរាយការណ៍ថាបានទទួលការគម្រាមកំហែងដោយហឹង្សាលាក់មុខ ។ មេដឹកនាំ សហជីពពីរនាក់ដែលមានទំនាក់ទំនងជាមួយសហជីពសេរីកម្មករនៃព្រះរាជណាចក្រកម្ពុជា បានទទួលរងរបួស ដោយសារឆ្មាំសន្តិសុខរោងចក្រម្នាក់ទៀត ទទួលការរងរបួសដោយបុរសមិនស្គាល់អត្តសញ្ញាណពីរនាក់ និងពីរនាក់ ផ្សេងទៀតរងការគម្រាមកំហែង ។ មេដឹកនាំសហជីពឯករាជ្យ និងគាំទ្ររដ្ឋាភិបាលទាំងពីរនាក់រងរបួសដោយជន ដៃដល់មិនស្គាល់អត្តសញ្ញាណ ។ នៅក្នុងករណីចំនួនបួន មេដឹកនាំសហជីព ២៥នាក់ ទទួលរងការគម្រាមកំហែង ដោយការប្តឹងផ្តល់ ឬត្រូវបានប្តឹងពីបទបរិហារកេរ្តិ៍ ការភូតកុហកតុលាការ ការញុះញង់អោយកម្មករធ្វើកូដកម្ម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន និងប៉ុនប៉ងញុះញង់អោយកម្មករធ្វើការវាយប្រហារ ។ មានពេលជាច្រើន មេដឹកនាំសហជីពដែលត្រូវបណ្តេញចេញពីការងារ បានទទួលយកការដោះស្រាយជាសាច់

ប្រាក់ បន្ទាប់ពីបានតវ៉ា ដោយទទួលបរាជ័យទៅកាន់រដ្ឋាភិបាលអោយពង្រឹងច្បាប់តម្រូវអោយប្រគល់ការងារអោយខ្លួនវិញ ។ នៅពេល ខ្លះទៀត រដ្ឋាភិបាលបានលើកកម្ពស់សិទ្ធិការងារផងដែរ ។ ឧទាហរណ៍ នៅអំឡុងឆ្នាំនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានព្រមានជាផ្លូវការចំពោះក្រុមហ៊ុន ចំនួន៦៩១ អំពីការរំលោភច្បាប់ ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជូនវិវាទការងារដែលមិនទាន់បានដោះស្រាយទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការ ដោះស្រាយ ។ ក្រុមប្រឹក្សាកណ្តាលបានទទួល១៧៨ករណី មកពីទូទាំងប្រទេស (កើនពីចំនួន ១៥៩ករណីនៅឆ្នាំ ២០០៨) ដែលប្រមាណជា ៦៥ភាគរយត្រូវបានដោះស្រាយដោយជោគជ័យ ។

សហជីពបន្តទទួលបានកម្លាំងកាន់តែច្រើនប៉ុន្តែមិនអាចតំណាងអោយផលប្រយោជន៍របស់សមាជិកបានគ្រប់គ្រាន់ ទេ ដោយសារមានធនធាន ការបណ្តុះបណ្តាល និងបទពិសោធន៍មិនគ្រប់គ្រាន់ ។ ជាងនេះទៀត អំពើពុករលួយ តែងតែរុកគួនក្នុងជួរសហជីព និយោជក និងមន្ត្រីរដ្ឋាភិបាលដែលរារាំងដល់ទំនាក់ទំនងការងារស្របច្បាប់ ។ អំពើហឹង្សា ការបៀតបៀន និងការបំភិតបំភ័យរវាងសហជីពប្រជែងគ្នា កើតឡើងជាញឹកញាប់ ។ មេដឹកនាំ សហជីពមកពីមជ្ឈដ្ឋាននយោបាយ ត្អូញត្អែរថាសម្ព័ន្ធសហជីពយុវជនខ្មែរដែលគាំទ្ររដ្ឋាភិបាល ត្រូវបានគម្រាម កំហែង និងបៀតបៀនដោយកម្មករដែលមកពីសហជីពដទៃទៀត ។

នៅតាមរោងចក្រមួយចំនួន បុគ្គលដែលមានតំណែងនៅក្នុងថ្នាក់គ្រប់គ្រងទំនងជាបានបង្កើតសហជីពរបស់ខ្លួន ផ្ទាល់ គាំទ្រសហជីពដែលគាំទ្រថ្នាក់គ្រប់គ្រង ឬសម្រុះសម្រួលមេដឹកនាំសហជីពតាមរយៈការខិតខំប្រឹងប្រែង ដើម្បីធ្វើអោយខូចការងាររបស់អ្នកទាំងនោះ ។

ពុំមានច្បាប់ពិសេស ឬការលើកលែងពីច្បាប់ការងារធម្មតានៅក្នុងតំបន់ដំណើរការការនាំចេញ (ដែលហៅថាតំបន់ សេដ្ឋកិច្ចពិសេស) ឡើយ ។

**គ. ការហាមឃាត់ការងារដោយបង្ខំ ឬជាកាតព្វកិច្ច**

ច្បាប់ហាមប្រាមចំពោះការងារដោយបង្ខំ ឬជាកាតព្វកិច្ច ប៉ុន្តែ មានរបាយការណ៍ថាមានការអនុវត្តរបៀប នេះបានកើតមានឡើងស្ទើរតែទូទាំងវិស័យក្រៅផ្លូវការទាំងមូល ។ មានរបាយការណ៍ជាច្រើនអំពីការងារដោយបង្ខំ ដោយអ្នកបម្រើតាមផ្ទះ ។

**ឃ. ការហាមឃាត់ពលកម្មកុមារ និងអាយុអប្បបរមាសម្រាប់បំពេញការងារ**

ច្បាប់ការពារកុមារពីការកេងប្រវ័ញ្ចនៅកន្លែងធ្វើការ ប៉ុន្តែជាញឹកញាប់ការអនុវត្តនៅមានភាពទន់ខ្សោយនៅឡើយ ។ ច្បាប់បានកំណត់ថាអាយុ ១៥ឆ្នាំ គឺជាអាយុអប្បបរមាសម្រាប់បំពេញការងារ និងអាយុ១៨ឆ្នាំជាអាយុអប្បបរមាសម្រាប់បំពេញការងារដែលមានគ្រោះថ្នាក់ ។ ច្បាប់អនុញ្ញាតអោយកុមារអាយុចន្លោះពី១២

ទៅ១៥ឆ្នាំ ចូលរួមក្នុង “ការងារស្រាល” ដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និងមិនប៉ះពាល់ដល់ការសិក្សារបស់ខ្លួន ។ ផែនការសកម្មភាពជាតិប្រយុទ្ធនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (ឆ្នាំ២០០៨-២០១២) សំដៅកាត់បន្ថយចំនួនកុមារធ្វើការដែលមានអាយុចន្លោះ ៥-១៧ឆ្នាំ អោយនៅត្រឹម ១០,៦ភាគរយ នៅឆ្នាំ២០១០ និង ៨ភាគរយនៅត្រឹមឆ្នាំ២០១៥ ។

ពលកម្មកុមារមានច្រើននៅក្នុងការងារកសិកម្ម សិប្បកម្មឡឥដ្ឋ នេសាទ ឧស្សាហកម្មផ្លូវភេទ ការបម្រើតាមផ្ទះ និងនៅតាមចំការថ្នាំជក់ និងចំការកៅស៊ូ ។ ពលកម្មកុមារក៏ត្រូវបានរាយការណ៍ថាមាននៅក្នុងវិស័យផ្លូវការផងដែរ ប៉ុន្តែមានកម្រិតតិចតួចជាង ។ យោងតាមការសិក្សាមួយនៅឆ្នាំ២០០៦ ធ្វើឡើងដោយធនាគារពិភពលោក និង អង្គការដទៃទៀត បានរកឃើញថាមានកុមារសកម្មក្នុងវិស័យសេដ្ឋកិច្ចចំនួនជាង ៧៥០.០០០នាក់មានអាយុ ក្រោមបំពេញការងារអប្បបរមាដាច់ខាត ១២ឆ្នាំ និងកុមារបន្ថែមចំនួន ៥០០.០០០នាក់ទៀត (អាយុចន្លោះពី១២ ទៅ១៤ឆ្នាំ) កំពុងធ្វើសកម្មភាពសេដ្ឋកិច្ចធ្ងន់ធ្ងរ មានអាយុក្រោមអាយុអប្បបរមាដែលបានកំណត់សម្រាប់ការងារប្រភេទនេះ ។ យោងតាមរបាយការណ៍នេះ មានកុមារចំនួនជាង ២៥០.០០០នាក់ អាយុពី១៥ទៅ១៧ឆ្នាំ បាន ធ្វើការលើសពី ៤៣ម៉ោងក្នុងមួយសប្តាហ៍ ឬនៅក្នុងវិស័យដែលមានគ្រោះថ្នាក់ ។ អ្នកជំនាញការម្នាក់មកពីកម្មវិធី អន្តរជាតិលុបបំបាត់ពលកម្មកុមារនៃអង្គការពលកម្មអន្តរជាតិបានថ្លែងថា ចំនួនកុមារដែលធ្វើការនៅក្នុងលក្ខខណ្ឌ ការងារមានគ្រោះថ្នាក់បានកើនឡើងប្រមាណជា ៣០០.០០០ នាក់ នៅអំឡុងឆ្នាំនេះ ។ ចំនួនបីភាគបួននៃកុមារ សកម្មនៅក្នុងផ្នែកសេដ្ឋកិច្ច ស្ថិតនៅក្នុងវិស័យកសិកម្ម ១៥ភាគរយនៅក្នុងវិស័យពាណិជ្ជកម្ម ៥ភាគរយនៅក្នុង វិស័យផលិតកម្មខ្នាតតូច និង ២ភាគរយនៅក្នុងផ្នែកសេវាកម្ម ។

យោងតាមរបាយការណ៍មួយនៅឆ្នាំ២០០៧ បានរកឃើញថា មានកុមារបម្រើតាមផ្ទះសរុបចំនួន ២១.២៦៦នាក់ នៅក្នុងទីក្រុងភ្នំពេញ និងខេត្តចំនួនបី រួមមានបាត់ដំបង កំពង់ចាម និងសៀមរាប ។ ជាធម្មតាកុមារទាំងនេះ មិនបានចូលរៀន ធ្វើការជាច្រើនម៉ោងដោយពុំទទួលបានអត្ថប្រយោជន៍ផ្នែកសុខភាព និងទទួលបានប្រាក់ឈ្នួល បន្តិចបន្តួច ឬមិនបានទទួលប្រាក់ឈ្នួលឡើយ ។ នៅខែតុលា នគរបាលបានចាប់ខ្លួនឈ្មោះ មាស ណារី ជាគ្រូ បង្រៀនវិទ្យាល័យម្នាក់ និងប្តីរបស់គាត់ឈ្មោះ វ៉ា សារឿន ជាអតីតមន្ត្រីរាជការ ចំពោះការប្រព្រឹត្តយ៉ាងឃោរឃៅទៅលើកុមារដែលស្ថិតក្រោមអាណាព្យាបាលរបស់ខ្លួនជាកុមារីម្នាក់អាយុ១១ឆ្នាំដែលខ្លួនបានប្រើប្រាស់ ជាអ្នកបម្រើតាមផ្ទះ ។ កុមារីរូបនេះបានប្រាប់អ្នកស៊ើបអង្កេតថា នាងត្រូវបង្ខំអោយធ្វើការងារផ្ទះជាច្រើនឆ្នាំមក ហើយ ហើយត្រូវរំលោភបំពានជាញឹកញាប់ដោយប្តីប្រពន្ធនេះ រួមមានដូចជាការធ្វើទណ្ឌកម្មដោយដង្កាប់ វាយដុំដោយរំពាត់ខ្សែតី ឆក់ខ្សែភ្លើង និងដុតជាដើម ។

ពុំមានទិដ្ឋភាពផ្នែកច្បាប់ណាមួយ ដែលហាមឃាត់ពលកម្មកុមារត្រូវបានអនុវត្តអោយបានគ្រប់គ្រាន់នៅក្នុងផ្នែក ការងារផ្លូវការនេះឡើយ ។ ហើយក៏ពុំមាននិយោជកណាម្នាក់ ត្រូវបានកាត់ទោសចំពោះការរំលោភច្បាប់ប្រឆាំង នឹងពលកម្មកុមារដែរ ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទទួលខុសត្រូវចំពោះបញ្ហាពលកម្ម

កុមារ ទាំង នៅក្នុងវិស័យផ្លូវការ និងវិស័យក្រៅផ្លូវការនៃសេដ្ឋកិច្ច ប៉ុន្តែអធិការកិច្ចការងារមិនបានបំពេញតួនាទី នៅក្នុងវិស័យ ក្រៅផ្លូវការ ឬក្នុងការពង្រឹងច្បាប់នៅក្នុងឧស្សាហកម្មខុសច្បាប់ ដូចជារោងចក្រកាត់ដេរដែលមិនបានចុះបញ្ជី ដែលធ្វើប្រតិបត្តិការដោយគ្មានអាជ្ញាប័ណ្ណពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម ឡើយ ។ នៅក្នុងផ្នែកផ្លូវការ អធិការកិច្ចការងារបានធ្វើការត្រួតពិនិត្យជាប្រចាំទៅលើឧស្សាហកម្មមួយចំនួន ដូចជាផ្នែកផលិតសម្លៀកបំពាក់ (ដែលឧប្បត្តិហេតុនៃពលកម្មកុមារត្រូវបានព្រងើយកន្តើយ) ប៉ុន្តែនៅក្នុងឧស្សាហកម្មខ្លះដែលមានហានិភ័យពលកម្មកុមារខ្ពស់បំផុត អធិការកិច្ចយកចិត្តទុកដាក់តែទៅលើពាក្យបណ្តឹងតែប៉ុណ្ណោះ ។

រដ្ឋធម្មនុញ្ញហាមឃាត់ពលកម្មកុមារដោយបង្ខំ និងជាប់បំណុល ប៉ុន្តែពលកម្មកុមារដោយបង្ខំ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរ មួយនៅក្នុងឧស្សាហកម្មជួញដូរផ្លូវភេទ ជាពិសេសក្នុងចំណោមកុមារដែលមានអាយុពី ១៥ ទៅ១៨ឆ្នាំ ។ ទីភ្នាក់ងារពង្រឹងច្បាប់មិនបានប្រយុទ្ធនឹងពេស្យាចារកុមារអោយបានខ្ជាប់ខ្ជួន និងប្រកបដោយនិរន្តរភាពឡើយ ។ អំពើពុករលួយដ៏រីករាលដាល កង្វះតម្លាភាព ធនធានមិនគ្រប់គ្រាន់ និងកង្វះបុគ្គលិក នៅតែជាឧបសគ្គដែលត្រូវប្រឈមបំផុត ។

## ខ. លក្ខខណ្ឌការងារដែលអាចទទួលយកបាន

ច្បាប់តម្រូវអោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យកាត់ដេរ ផ្អែកតាមអនុសាសន៍ពីគណៈកម្មាធិការប្រឹក្សាការងារ ។ ពុំមានប្រាក់ឈ្នួលអប្បបរមាសម្រាប់ឧស្សាហកម្មណា ដទៃទៀតឡើយ ។ កម្មករកាត់ដេរត្រូវបានធានាប្រាក់ឈ្នួលអប្បបរមាស្មើនឹង ៥០ដុល្លារក្នុងមួយខែបូករួម ជាមួយនឹងប្រាក់ឧបត្ថម្ភក្នុងការរស់នៅយ៉ាងតិច ៦ដុល្លារ ។ ប្រាក់ឈ្នួលប្រចាំខែ បច្ចុប្បន្ន នៅក្នុងវិស័យកាត់ដេរ និងអាជីពដទៃទៀតមិនគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ដល់កម្មករ និងគ្រួសារប្រកបដោយជីវភាពសមរម្យឡើយ ទោះបី ជាប្រាក់ឈ្នួលនៅផ្នែកកាត់ដេរជាទូទៅ ខ្ពស់ជាងសេដ្ឋកិច្ចក្រៅផ្លូវការក៏ដោយ ។ និយោជកភាគច្រើននៅតាម រោងចក្រកាត់ដេរផ្តល់ប្រាក់ឈ្នួលដល់កម្មករអចិន្ត្រៃយ៍ ប៉ុន្តែកម្មករបណ្តោះអាសន្ន និងកម្មករប្រភេទដូចនេះ ដទៃទៀតជាញឹកញាប់ទទួលបានប្រាក់បៀវត្សរ៍តិចជាងនេះ ។

ច្បាប់មានចែងអំពីរយៈពេលធ្វើការប្រចាំសប្តាហ៍តាមបទដ្ឋានស្របច្បាប់ចំនួន ៤៨ម៉ោង មិនអោយលើសពី ៨ម៉ោងក្នុងមួយថ្ងៃឡើយ ។ ច្បាប់កំណត់អត្រា ១៣០ភាគរយនៃប្រាក់ឈ្នួលធ្វើការនៅពេលថ្ងៃ សម្រាប់វេនការងារនៅពេលយប់ និង ១៥០ភាគរយសម្រាប់ការងារបន្ថែមម៉ោងដែលត្រូវកើនឡើង ២០០ភាគរយ ប្រសិនបើការងារលើសម៉ោងនោះកើតមានឡើងនៅពេលយប់នៅថ្ងៃអាទិត្យ ឬនៅថ្ងៃឈប់សម្រាក ។ និយោជិត ត្រូវបានអនុញ្ញាតអោយធ្វើការលើសម៉ោងដល់ទៅពីរម៉ោងក្នុងមួយថ្ងៃ ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលមិនបាន ពង្រឹងបទដ្ឋាននេះប្រកបដោយប្រសិទ្ធភាពឡើយ ។ កម្មករបានរាយការណ៍ថា ការងារលើសម៉ោងច្រើនហួស កម្រិត

ហើយជួនកាលជាការចាំបាច់ដែលត្រូវតែធ្វើទៀតផង ។ ស្រដៀងគ្នានេះដែរ នៅក្រៅឧស្សាហកម្មកាត់ដេរ បទប្បញ្ញត្តិអំពីម៉ោងធ្វើការ កម្រនឹងត្រូវបានពង្រឹងណាស់ ។ ការងារបន្ថែមម៉ោង ដោយគ្មានការស្ម័គ្រចិត្ត នៅតែជាបញ្ហាមួយ ទោះបីជាការអនុវត្តនេះបានថយចុះនៅអំឡុងឆ្នាំនេះក៏ដោយ ។ និយោជកប្រើប្រាស់ការ បំភិតបំភ័យ ដើម្បីបង្ខំអោយនិយោជិតធ្វើការ ។ ជារឿយៗ កម្មករត្រូវប្រឈមនឹងការផាកពិន័យ ការបណ្តេញ ពីការងារ ឬការបាត់បង់ប្រាក់រង្វាន់ ប្រសិនបើកម្មករទាំងនោះបដិសេធមិនធ្វើការបន្ថែមម៉ោង ។

ច្បាប់ចែងថា កន្លែងធ្វើការត្រូវគោរពតាមបទដ្ឋានអនាម័យ និងសុវត្ថិភាព គ្រប់គ្រាន់ដើម្បីផ្តល់សុខមាលភាព ដល់កម្មករ ។ រដ្ឋាភិបាលបានអនុវត្តបទដ្ឋានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព នៅតាមទីកន្លែងមួយចំនួន មួយផ្នែកដោយសារខ្វះខាតខ្វះបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងបរិក្ខារ ។ នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាទីភ្នាក់ងារពង្រឹងច្បាប់ជាចម្បង ហើយនៅអំឡុងឆ្នាំនេះ នាយកដ្ឋានបានចេញសេចក្តីព្រមានចំនួន ៦៩១ អំពីការរំលោភច្បាប់ការងារដល់ក្រុមហ៊ុននានា ។ ទីភ្នាក់ងារនេះ ហាក់ដូចជាបានធ្វើអធិការកិច្ចដោយបុរេសកម្ម ប៉ុន្តែអំពើពុករលួយដ៏រីករាលដាលបានរាំងដល់ប្រសិទ្ធភាពនៃ អធិការកិច្ចទាំងនោះ ។ របួសការងារ និងបញ្ហាសុខភាព កើតមានឡើងជាញឹកញាប់ ។ រោងចក្រកាត់ដេរធំៗ ភាគច្រើនដែលផលិតសម្រាប់ទីផ្សារនៅប្រទេសអភិវឌ្ឍ បានបំពេញបានល្អគួរសមតាមបទដ្ឋានអនាម័យ និង សុវត្ថិភាពការងារ ដែលជាលក្ខខណ្ឌសម្រាប់ចុះកិច្ចសន្យាជាមួយអតិថិជនទិញផលិតផលរបស់ខ្លួន ។ លក្ខខណ្ឌ ការងារនៅតាមរោងចក្រខ្នាតតូចមួយចំនួន និងឧស្សាហកម្មតូចៗ មានលក្ខណៈទន់ខ្សោយ ហើយជារឿយៗ មិនបានបំពេញតាមបទដ្ឋានអន្តរជាតិទេ ។ ទណ្ឌកម្មមានចែងលម្អិតនៅក្នុងច្បាប់ ប៉ុន្តែគ្មានបទប្បញ្ញត្តិ ជាក់លាក់ណាមួយដើម្បីការពារកម្មករដែលតវ៉ាអំពី លក្ខខណ្ឌការងារដែលគ្មានសុវត្ថិភាព ឬគ្មានអនាម័យឡើយ ។ កម្មករមានសិទ្ធិដកខ្លួនចេញពីស្ថានភាពដែលមានគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពដោយមិនប៉ះពាល់ការងារ របស់ខ្លួនឡើយ ប៉ុន្តែអ្នកដែលធ្វើដូច្នេះអាចនឹងបាត់បង់ការងារ ។

នៅថ្ងៃទី១២ ខែតុលា កម្មករកាត់ដេរចំនួន ៤១៤នាក់ នៅរោងចក្រកាត់ដេរ Will Bes បានសន្លប់ និងត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យដើម្បីទទួលការព្យាបាល ។ កម្មករបាននិយាយថា សារធាតុគីមីដែលមានឥទ្ធិពលខ្លាំង ដែលត្រូវបានប្រើប្រាស់នៅក្នុងរោងចក្របណ្តាលអោយកម្មករសន្លប់ ។ បន្ទាប់ពីឧប្បត្តិហេតុនេះ បានកើតឡើង រោងចក្រត្រូវបានបញ្ជាអោយបិទទ្វារដើម្បីធ្វើការសម្អាត ។